## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

# សារណាបញ្ចប់ការសិក្សា

# ដំណើរការវិវត្តន៍នៃរបបសន្តិសុខសង្គម
# នៅប្រទេសកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១


តាក់តែងឡើង
និស្សិតឈ្មោះ **ស៊ីម លក្ខិណា**

សាស្ត្រាចារ្យណែនាំ
**លោកស្រី ឡុង ម៉ាទីឌី**


ថ្នាក់បរិញ្ញាបត្រ គ្រប់គ្រងធុរកិច្ច

ចូលសិក្សា ២០១៧

ជំនាន់ទី៥

ឆ្នាំសរសេរសារណា ២០២១

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ក្នុងនាមយើងខ្ញុំជានិស្សិតឈ្មោះ **ស៊ីម លក្ខិណា** ដែលជានិស្សិតកំពុងសិក្សាឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រគ្រប់គ្រងធុរកិច្ច នៃសាកលវិទ្យាល័យ **ភូមិន្ទនីតិសាស្រ្ត និងវិទ្យាលសាស្រ្តសេដ្ឋកិច្ច** សូមធ្វើការគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកឪពុក អ្នកម្តាយ** ដែលលោកទាំងពីរជាអ្នកមានគុណ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាកូនអស់ពីកម្លាំងកាយចិត្ត លោកបានខិតខំពុះពារគ្រប់ឧបសគ្គទាំងអស់ដើម្បីកូន ផ្តល់ភាពកក់ក្តៅក្នុងគ្រួសារ ជាពិសេសផ្តល់នូវដំបូន្មានប្រៀបប្រដៅល្អៗដែលប្រកបដោយព្រហ្មវិហារធម៌ដែលជាកត្តាជំរុញឱ្យកូនក្លាយជា កូនល្អ សិស្សល្អ មិត្តល្អ និងជាបុគ្គលល្អក្នុងសង្គមជាតិ។ លើសពីនេះលោកបានផ្គត់ផ្គង់រាល់ការចំណាយ ទៅលើសម្ភារៈ ព្រមទាំងថវិកា និងឱកាសឱ្យកូនបានសិក្សារៀនសូត្រ ដើម្បីក្រេបជញ្ជក់យកចំណេះដឹង ចំណេះធ្វើ ដើម្បីមានឱកាសក្លាយជា បុគ្គលដែលមានតម្លៃសម្រាប់ខ្លួនឯង គ្រួសារ និងសង្គមជាតិ។

**ឯកឧត្តមសាកលវិទ្យាធិការ** លោកលោកស្រី សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ដែលបានអនុញ្ញាត និងផ្តល់លទ្ធភាពឱ្យយើងខ្ញុំបានទទួលឱកាសក្នុងការចូលសិក្សានៅក្នុងសាកលវិទ្យាល័យ **ភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ។ លោក លោកស្រីសាស្រ្តាចារ្យ ព្រមទាំងបុគ្គលិទាំងអស់នៃសាកលវិទ្យាល័យ **ភូមិន្ទនីតីសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ព្រមទាំងបានផ្តល់នូវដំបូន្មានពាក្យពេជអប់រំប្រដៅ និងទស្សនៈទាន ជាច្រើនសម្រាប់ការសិក្សា និងការអភិវឌ្ឍន៍ខ្លួនក្លាយជាបុគ្គលដែលមានសមត្ថភាពមួយរូបក្នុងសង្គម។

ជាពិសេស លោកស្រីសាស្រ្តាចារ្យ **ឡុង ម៉ាមីឌី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំផ្តល់ជាយោបល់ល្អៗ និង ជួយកែសម្រួលនូវរបាយការណ៍ចុះកម្មសិក្សាមួយនេះចាប់ពីផ្តើម រហូតដល់បញ្ចប់បេសកម្មនៃសៀវភៅមួយក្បាលនេះបានយ៉ាងជោគជ័យ។

ឯកឧត្តមអគ្គនាយក **អ៊ុក សមវិទ្យា** ជាអគ្គនាយកដ្ឋាននៃបេឡាជាតិសន្តិសុខសង្គម និងលោកប្រធាននាយកដ្ឋានបញ្ជិកា និងភាគទាន ព្រមទាំងមន្ត្រីរាជការបុគ្គលិកទាំងអស់នៃអគ្គនាយកដ្ឋានបេឡាជាតិសន្តិសុខសង្គម ក្នុងទីស្នាក់ការកណ្តាលនៃអគ្គនាយកដ្ឋានដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចុះកម្មសិក្សា ព្រមទាំងផ្តល់ព័ត៌មាននិង ឯកសារផ្សេងៗដែលពាក់ព័ន្ធដល់យើងខ្ញុំ។ មន្ត្រីរាជការបុគ្គលិកទាំងអស់បានជួយជម្រុញ ជ្រោមជ្រែង លើកទឹកចិត្ត និងផ្តល់ជាគំនិតល្អៗ ក៏ដូចជាផ្តល់នូវភាពងាយស្រួលក្នុងកំឡុងពេលដែលយើងខ្ញុំបាននឹងកំពុងធ្វើការស្រាវជ្រាវ។

**រៀមច្បង**ជំនាន់មុនដែលបានបន្សល់ទុកនូវស្នាដៃល្អៗ ដែលជាឯកសារសម្រាប់និស្សិតជំនាន់ក្រោយយកមកធ្វើជាគម្រូ និងសម្រាប់ធ្វើការសិក្សាស្រាវជ្រាវ។

ជាចុងក្រោយយើងខ្ញុំសូមធ្វើការដឹងគុណពីសំណាក់មាតាបិតា ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង ឯកឧត្តមអគ្គនាយក លោកប្រធាននាយកដ្ឋាន លោក លោកស្រីសាស្រ្តាចារ្យ ព្រមទាំងបុគ្គលិកទាំងអស់ដែលបម្រើការ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និង

វិទ្យាសាស្ត្រសេដ្ឋកិច្ច ក៏ដូចជាមន្ត្រីរាជការ បុគ្គលិកនៅក្នុងបេឡាជាតិសន្តិសុខសង្គម ទាំងអស់ជួបប្រទះនូវសេចក្តីសុខ សេចក្តីចម្រើន ព្រមទាំងពុទ្ធពរទាំង បួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ផ្ដើមចេញពីទិដ្ឋភាពសង្គមនៃបណ្ដាប្រទេសនានា ក្នុងពិភពលោកក្នុងពេលបច្ចុប្បន្នបាន បង្ហាញឱ្យថាសេដ្ឋកិច្ចបានកំពុងតែវិវត្តន៍ឥតឈប់ឈរនូវចរន្តសេដ្ឋកិច្ចយ៉ាងខ្លាំងខ្លា ដោយប្រទេស នីមួយៗបានកំពុងអភិវឌ្ឍខ្លួន ដើម្បីសក្ដានុពល និងមានភាពរីកចម្រើនកាន់ខ្លាំងនឹងជឿនលឿន។ជាក់ ស្ដែងប្រទេសកម្ពុជា ដែលជាសមាជិកនៅក្នុងតំបន់អាស៊ានទាំងមូលបានរួមបញ្ចូលគ្នាដោយធ្វើសមា ហរណកម្មកាលពីចុងឆ្នាំ២០១៥ ដែលធ្វើសមាហរណកម្មនេះបានបើកឱកាសយ៉ាងទូលំទូលាយក្នុង ការអភិវឌ្ឍន៍ប្រទេសជាតិផងដែរ។ ការរួមបញ្ចូលនូវសេដ្ឋកិច្ចជាមួយបណ្ដាប្រទេស នៅអាស៊ានរបស់ ប្រទេសកម្ពុជា ក៏ទាមទារឱ្យប្រទេសធ្វើការអភិវឌ្ឍន៍ នូវវិស័យមួយចំនួនដូចជា វិស័យច្បាប់ផ្សេងៗ វិស័យអប់រំ វិស័យឧស្សាហកម្ម ព្រមទាំងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដើម្បីអភិវឌ្ឍន៍នូវវិស័យ ផ្សេងៗជាទៃទៀតក្នុងប្រទេសជាតិ។ យ៉ាងណាមិញ ក្នុងការអភិវឌ្ឍន៍ប្រទេសឱ្យមានការរីកចម្រើននោះ គឺនយោបាយជាតិគាំពារសង្គមនៃរបបសន្តិសុខសង្គម ក៏ជាកត្តាសំខាន់សម្រាប់ការជួយជម្រុញការ អភិវឌ្ឍន៍ គម្លាតអ្នកមាននឹងអ្នកក្រ ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យសុខាភិបាលរបស់ ប្រទេសឱ្យមានការរីកចម្រើនក្របកដោយដំណើរល្អប្រសើរផងដែរ។

យ៉ាងណាមិញ ក្នុងការអភិវឌ្ឍឱ្យមានការរីកចម្រើនទៅបាននោះ កត្តាគាំពារសង្គមពិតជាបាន ដើរតួនាទីយ៉ាងសំខាន់។ ដោយឡែកនយោបាយជាតិគាំពារសង្គម គឺជាវិធីសាស្ត្រក្នុងការកសាង ប្រព័ន្ធគាំពារសង្គមមួយដែលមានប្រសិទ្ធភាព និងចីរភាពហរិញ្ញវត្ថុ ដើម្បីបម្រើដល់គោលនយោបាយ កាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សឱ្យកាន់រឹងមាំ និងទូលំទូលាយ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ។ជា ទូទៅគោលនយោបាយជាតិគាំពារសង្គមត្រូវបានបែងចែកជាពីរគឺប្រព័ន្ធជំនួយសង្គម និងរបបសន្តិ សុខសង្គម តែកត្តាដែលសំខាន់ដែលជម្រុញ និងធានានិរន្តភាពនៃជីវភាពប្រជាជនក្នុងនោះរបបសន្តិ សុខសង្គមពិតជាមានតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញឱ្យ ប្រជាជនគ្រប់រូបចូលរួមសន្សំប្រាប់(ភាគ ទាន) ក្នុងមូលនិធិមួយដែលត្រូវប្រសិទ្ធនាមជាបេឡាជាតិសន្តិសុខសង្គម ដើម្បីការពារហានិភ័យពីការ ធ្លាក់ចូលក្នុងភាពក្រីក្រនៅពេលចាស់ជរា និងពេលមានតម្រូវការលើសេវាថែទាំសុខភាព ព្រមទាំងហា និភ័យផ្សេងៗទៀត ក្នុងកំឡុងពេលបម្រើការងារនូវគ្រឹះស្ថានសហគ្រាសឬ បម្រើការក្នុងស្ថាប័ន សាធារណៈទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជា។

លើសពីនេះយើងបានសម្លឹងឃើញថា របបសន្តិសុខសង្គមនៅកម្ពុជាពិតជាមានការរីកចម្រើន គួរឱ្យកត់សម្គាល់ទើប យើងខ្ញុំសម្រេចចិត្តធ្វើការស្រាវជ្រាវដោយចុះកម្មសិក្សាដោយផ្ទាល់នៅក្នុងអគ្គ នាយកដ្ឋានបេឡាជាតិសន្តិសុខសង្គម ក្រោមប្រធានបទមួយដែលស្ដីពី "**ដំណើរការវិវត្តន៍នៃ របបសន្តិសុខសង្គមនៅប្រទេសកម្ពុជា**" ដែលជាប្រធានបទមួយដែលអាចធ្វើការប្រៀបធៀប កំណើននៃការយល់ដឹងរបស់ប្រជាជនកម្ពុជាលើវិស័យមួយនេះ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមជឿជាក់ថាសារណាបញ្ចប់ច្បាប់នេះ និងផ្ដល់ជាសំណោរ ក៏ដូចជា គំនិតល្អៗ ដើម្បីបានជាឯកសារដែលមានប្រយោជន៍មួយជំនួយស្មារតីដល់សង្គមជាតិទាំងមូល ដើម្បី

ស្វែងយល់ឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតជាប្រធានបទដែល យើងខ្ញុំបានសិក្សាស្រាវជ្រាវច្បាប់នេះឡើង និងផ្តល់អត្ថប្រយោជន៍ដល់បណ្តានិស្សិតជំនាន់ក្រោយ ទុកជាឯកសារសម្រាប់ស្រាវជ្រាវបន្តទៀត។ ទោះបីជាឆ្លងកាត់ការត្រួតពិនិត្យ និងកែសម្រួលជាច្រើន ដំណាក់ការយ៉ាងណាក៏ដោយ ក៏មិនអាចចៀសផុតពីកំហុសឆ្លងនូវកង្វះខាត និងកំហុសខុសឆ្គងទាំងអត្ថន័យ និងអក្ខរាវិរុទ្ធដោយជៀសមិនផុតឡើយ។ ដូចនេះយើងខ្ញុំនឹងរងចាំទទួលការរិះគន់ ក្នុងន័យស្ថាបនាពីសំណាក់សាស្ត្រាចារ្យ មិត្តនិស្សិតគ្រប់រូប គ្រប់ជំនាន់ ដើម្បីបំពេញនូវកង្វះខាតទាំងឡាយ ដើម្បីកែលម្អបន្ថែមឆ្ពោះទៅរកការបង្កើនគុណភាព និងសុក្រឹតភាពនៃសារណាច្បាប់នេះ។

# មាតិកា

បញ្ជីដ្យាក្រាម ---------- vi
បញ្ជីរូបភាព ---------- vii
បញ្ជីឧបសម្ព័ន្ធ ---------- viii

# សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ---------- ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ---------- ៣
៣. គោលបំណងនៃការស្រាវជ្រាវ ---------- ៤
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ---------- ៤
៥. សារៈសំខាន់នៃការស្រាវជ្រាវ ---------- ៤-៥
៦. វិធីសាស្ត្រវិភាគនៃការស្រាវជ្រាវ ---------- ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ---------- ៦

# ជំពូកទី១
# រំលឹកទ្រឹស្តី

១.១. និយមន័យ ---------- ៨
១.១.១. ការវិវត្តន៍ ---------- ៨
១.១.២. បច្ចេកទេស ---------- ៨
១.១.៣. សេវាកម្ម ---------- ៨
១.១.៤. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ ---------- ៨
១.១.៤. យុទ្ធសាស្ត្រ ---------- ៨
១.២. ការប្រែប្រួល ---------- ៩
១.២.១. ការប្រែប្រួលនៃរបបសន្តិសុខសង្គមតាមបែបឌីជីថល ---------- ៩
១.២.២. ការប្រែប្រួលនៃអត្រាភាគទាន ---------- ៩
១.២.៣. ការប្រែប្រួលកត្តាប្រជាសាស្ត្រ ---------- ៩
១.៣. ប្រភេទនៃរបបសន្តិសុខសង្គម ---------- ១០
១.៣.១. សេវាកម្មនៃរបបសោធន ---------- ១០
១.៣.២. សេវាកម្មនៃផ្នែកថែទាំសុខភាព ---------- ១០
១.៣.៣. សេវាកម្មនៃផ្នែកហានិភ័យការងារ ---------- ១០
១.៣.៤. សេវាកម្មនៃនិកម្មភាពការងារ ---------- ១០
១.៣.៥. ការគ្រប់គ្រងលើហិរញ្ញវត្ថុ(ភាគទាន) ---------- ១១
១.៤.កម្មវត្ថុនៃរបបសន្តិសុខសង្គម ---------- ១១
១.៤.១.វដ្តនៃរបបសន្តិសុខសង្គម ---------- ១១

១.៤.២. គោលបំណងរបស់របបសន្តិសុខសង្គម -------------------------------------- ១១
១.៤.៣. ចក្ខុវិស័យរបស់របបសន្តិសុខសង្គម -------------------------------------- ១១
១.៤.៤. បេសកម្មរបស់របបសន្តិសុខសង្គម-------------------------------------- ១១

## ជំពូកទី២

## ស្ថានភាពទូទៅរបស់បេឡាជាតិសន្តិសុខសង្គម

២.១. ប្រវត្តិនៃបេឡាជាតិសន្តិសុខសង្គម--------------------------------------១២
២.១.១. ប្រវិត្តនៃការកកើតបេឡាជាតិសន្តិសុខសង្គម--------------------------------------១៣
២.១.២. ទីតាំងនៃបេឡាជាតិសន្តិសុខសង្គម --------------------------------------១៣
២.១.៣. ស្លាកសញ្ញា និងអត្ថន័យនៃបេឡាជាតិសន្តិសុខសង្គម--------------------------------------១៣
២.១.៤. ចក្ខុវិស័យ គោលបំណងរបស់បេឡាជាតិសន្តិសុខសង្គម -------------------------------------- ១៥
២.១.៤.១. ចក្ខុវិស័យរបស់បេឡាជាតិសន្តិសុខសង្គម-------------------------------------- ១៥
២.១.៤.២. គោលបំណងរបស់បេឡាជាតិសន្តិសុខសង្គម-------------------------------------- ១៥
២.២. បេសកម្មរបស់បេឡាជាតិសន្តិសុខសង្គម -------------------------------------- ១៥
២.៣. រចនាសម្ព័ន្ធ និងតួនាទីនៃបេឡាជាតិសន្តិសុខសង្គម -------------------------------------- ១៦
២.៤. ដំណើរនៃការប្រត្តិបត្តិនៃរបបសន្តិសុខសង្គម -------------------------------------- ១៦
២.៤.១. ដំណើរវិវត្តន៍នៃផ្នែកហានិភ័យការងារ-------------------------------------- ១៦
២.៤.២. ដំណើរការវិវត្តន៍នៃផ្នែកថែទាំសុខភាព --------------------------------------១៧
២.៤.៣. ការជំរុញនឹងពន្លឿននៃផ្នែកសោធននិវត្តន៍ --------------------------------------១៧

## ជំពូកទី៣

## ប្រតិបត្តិការបច្ចេកទេសរបស់បេឡាសន្តិសុខសង្គម

៣.១. យន្តការនៃការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជា-------------------------------------- ១៨
៣.១.១. ការគ្រោងនឹងដំណើរការរបបសោធនក្នុងពេលខាងមុខ -------------------------------------- ១៨
៣.១.២. របបថែទាំសុខភាពដែលបានដំណើរការ-------------------------------------- ១៨
៣.១.២.១. របបថែទាំសុខភាព-------------------------------------- ១៨
៣.១.២.២.ដំណើរការអនុវត្តនៃរបបថែទាំសុខភាព-------------------------------------- ១៨
៣.១.៣. របបហានិភ័យការងារ-------------------------------------- ១៩
៣.១.៣.១. គ្រោះថ្នាក់ពេលធ្វើការ-------------------------------------- ១៩
៣.១.៣.២. គ្រោះថ្នាក់ពេលធ្វើដំណើរ -------------------------------------- ១៩
៣.១.៣.៣. ជំងឺវិជ្ជាជីវៈ --------------------------------------២០
៣.២. នីតិវិធីនៃការចុះបញ្ជិការសហគ្រាស គ្រឹះស្ថាន និងសមាជិក --------------------------------------២០
៣.២.១ ការចុះបញ្ជិការសហគ្រាស --------------------------------------២០
៣.២.២. ការចុះបញ្ជិការសមាជិក --------------------------------------២១

៣.២.២.១. ការចុះបញ្ជិការកម្មករនិយោជិកក្នុងប្រព័ន្ធ ---------------------------------២១
៣.២.២.២. ការចុះបញ្ជិការមន្ត្រីរាជការ និងអតីតមន្ត្រីរាជការនិងអតីតយុទ្ធជន--------២២
៣.២.២.៣. ផ្តល់វិញ្ញាបនប័ត្រជូនសហគ្រាសគ្រឹះស្ថាន --------------------------------២២
៣.២.២.៤. ការផ្តល់បណ្ណ័ជូនសមាជិក------------------------------------------------ ២៣
៣.៣. នីតិវិធីនៃការបង់ភាគទានសម្រាប់សមាជិក --------------------------------------------------- ២៣
៣.៣.១. អត្រាភាគទានសម្រាប់សមាជិកវិស័យឯកជន------------------------------------- ២៣
៣.៣.២. អត្រាភាគទានសម្រាប់សមាជិកវិស័យសាធារណៈ--------------------------------- ២៣
៣.៣.៣. ការអនុវត្តរបបសន្តិសុខសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការនិងអតីតយុទ្ធជន -------------------------------------------------------------------------------------------------------២៤
៣.៣.៤. បែបបទនៃការបង់ភាគទាន ------------------------------------------------------២៤
៣.៣.៥. បែបបទនៃការប្រកាសរបាយការណ៍កម្មករនិយោជិក--------------------------------២៥
៣.៣.៦. ទោស នឹងការពិន័យចំពោះការយឺតយ៉ាវ -------------------------------------------២៥
៣.៤. មូលដ្ឋានសុខាភិបាលសាធារណៈនឹងឯកជនដែលបានចុះកិច្ចព្រមព្រៀង---------------------២៦
៣.៤.១.កាតព្វកិច្ចមូលដ្ឋានសុខាភិបាល ---------------------------------------------------------២៦
៣.៤.២. មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង ------------------------------------២៦
៣.៥. បែបបទនៃការប្រើប្រាស់ និងទទួលបានតាវលិក ---------------------------------------------២៦
៣.៥.១. របបសោធន៍និវត្តន៍ ------------------------------------------------------------------------ ២៧
៣.៥.១.១. លក្ខខណ្ឌទទួលបានតាវលិកសោធន៍និវត្តន៍ ---------------------------------------២៨
៣.៥.១.១.១. លក្ខខណ្ឌទទួលបានតាវលិកសោធន៍ជរាភាព ---------------------------២៨
៣.៥.១.១.៣. លក្ខខណ្ឌទទួលបានតាវលិកសោធន៍ទុព្វភាព---------------------------២៨
៣.៥.១.១.៤. លក្ខខណ្ឌទទួលបានតាវលិកសោធន៍ឧត្តរជីវី ---------------------------២៨
៣.៥.១.១.៥. លក្ខខណ្ឌទទួលបានតាវលិកសោធន៍តាមរបបស្មគ្រចិត្ត ---------------២៨
៣.៥.១.១.៦. លក្ខខណ្ឌទទួលបានតាវលិកសោធន៍អយ្យកប្បញ្ញត្តិ --------------------២៩
៣.៥.២.របបថែទាំសុខភាព-----------------------------------------------------------------------២៩
៣.៥.២.១. លក្ខខណ្ឌទទួលបានតាវលិកនិងការប្រើប្រាស់របបថែទាំសុខភាព --------------២៩
៣.៣.១.២.១. លក្ខខណ្ឌក្នុងការប្រើប្រាស់សេវា ------------------------------------------២៩
៣.៣.១.២.២. មូលដ្ឋានសុខាភិបាលដែលភ្នាក់ងារ ប.ស.ស.ប្រចាំការ ----------------៣០
៣.៣.១.២.៣.មូលដ្ឋានសុខាភិបាលដែលគ្មានភ្នាក់ ប.ស.ស. ការប្រចាំការ បូករួមទាំងមន្ទីរពេទ្យឯកជន ------------------------------------------------------------------------៣០
៣.៥.២.៣. កំណត់ប្រភេទសេវាសម្រាប់សមាជិកក្នុងវិស័យឯកជន---------------------------៣១
៣.៥.២.៣.១. ការផ្តល់កញ្ចប់សម្រាប់សមាជិក ប.ស.ស. ------------------------------៣១
៣.៥.២.៣.២. សេវាដែលមិនរាប់បញ្ចូលក្នុងសេវាវេជ្ជសាស្ត្រ --------------------------៣១

៣.៥.២.៣.៣. ការកំណត់ប្រភេទជំងឺរ៉ាំរ៉ៃ ---------------------------------------------- ៣២
៣.៥.២.៣.៤. សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ------------------------------------- ៣៣
៣.៥.២.៣.៥. សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ និងសេវាបញ្ជូនសព -----------------៣៤
៣.៥.២.៣.៦. សេវាបង្ការសុខភាព ----------------------------------------------------៣៤
៣.៥.២.៣.៧.តាវលិកថែទាំសុខភាពសម្រាប់មន្ត្រីរាជសាធារណៈ ---------------------៣៥
៣.៥.២.៣.៨. សេវាស្តារនីតិសម្បទា ------------------------------------------------៣៥
៣.៥.២.៣.៩. ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់សមាជិកក្នុងវិស័យឯកជន--------------៣៥
៣.៥.២.៣.១០.ប្រាក់បំណាច់ពេលសម្រាប់មាតុភាពក្នុងវិស័យឯកជន ----------------៣៥
៣.៥.២.៣.១១. ប្រាក់ឧបត្ថម្ភរាជាភិបាលក្នុងវិស័យឯកជន-------------------------៣៦
៣.៥.២.៤. យន្តទូទាត់ថ្លៃថែទាំសុខភាព ---------------------------------------------- ៣៧
៣.៥.២.៤.១. ការទូទាត់តាមប្រភេទករណី--------------------------------------------៣៨
៣.៥.២.៤.២. ការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការសាធារណៈ -៣៩
៣.៥.៣. របបហានិភ័យការងារ--------------------------------------------------------៣៩
៣.៥.១. សេវាកម្មផ្នែកហានិភ័យការងារ -------------------------------------------------៣៩
៣.៥.២. លក្ខខណ្ឌក្នុងការប្រើប្រាស់សេវាហានិភ័យការងារ------------------------------៣៩
៣.៥.៣. ការផ្តល់ព័ត៌មានហានិភ័យការទៅកាន់ប.ស.ស. ------------------------------- ៤០
៣.៥.៤. ការអង្កេតហានិភ័យការងារ ------------------------------------------------- ៤០
៣.៥.៥. ការទាមទារតាវកាលិក ----------------------------------------------------- ៤០
៣.៥.១.ផ្តល់ការទូរទាត់ត្រឡប់ទៅវិញសម្រាប់ករណីសង្គ្រោះបន្ទាន់------------------ ៤១
៣.៥.២. ការផ្តល់ការថែទាំ និងការព្យាបាលវេជ្ជសាស្ត្រ-------------------------------- ៤១
៣.៥.៣.ការផ្តល់ប្រាក់ចំណាច់ជនរងគ្រោះ ------------------------------------------៤២
៣.៥.៤. ការផ្តល់តាវកាលិកអចិន្ត្រៃយ៍------------------------------------------------ ៤៤
៣.៥.៥. ការផ្តល់តាវកាលិកគ្រោះថ្នាក់ការងាររហូតបាត់បង់ជីវិត---------------------- ៤៥

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ------------------------------------------------------------------ ៤៨
២. ការផ្តល់អនុសាសន៍------------------------------------------------------------------ ៤៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| ក.ក.ជ | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | Council for Agricultural and Rural Development |
| ប.ស.ស. | បេឡាជាតិសន្តិសុខសង្គម | National Social security Fund |
| ប.ជ.ស | បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល | National Social security Fund for Civil Servants |
| ILO | អង្គការពលកម្មអន្តរជាតិ | International Labor Origination |
| បស | ប្រាក់ឈ្នួលសរុប | |
| បឈម | ប្រាក់ឈ្នួលមធ្យមជាប់ភាគទាន | |

# បញ្ជីតារាង

តារាងទី ១៖ ទីតាំងបេឡាជាតិសន្តិសុខសង្គម
តារាងទី ២៖ ឈ្មោះ និង និមត្តិសញ្ញារបស់បេឡាជាតិសន្តិសុខសង្គម

# បញ្ជីរូបភាព

រូបភាពទី ១៖ និមត្តិសញ្ញារបស់បេឡាជាតិសុខសង្គម
រូបភាពទី ២៖ វដ្តនៃដំណើរការរបស់របបនេះ

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១៖ ក្រុមបច្ចេកទេសនៃបេឡាសន្តិសុខសង្គម
ឧបសម្ព័ន្ធទី ២៖ ក្រុមបច្ចេកទេសនៃការគ្រប់គ្រងមូលនិធិសន្តិសុខសង្គម
ឧបសម្ព័ន្ធទី ៣៖ យន្តការផ្សព្វផ្សាយ និង បង្ការ
ឧបសម្ព័ន្ធទី ៤៖ កម្រងសំណួ

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ផ្តើមចេញពីភាពជោគជ័យនៃ ការអនុវត្តនូវគោលនយោបាយ "ឈ្នះ ឈ្នះ" របស់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក្នុងនោះបាន សមបង្ហាញឱ្យឃើញថា ប្រទេសជាតិទាំងមូលទទួលបានសន្តិភាពពេញលេញ ប្រកបដោយភាពឯកភាពជាតិ និងឯកភាពទឹកដីបានទាំងស្រុងចាប់តាំងពីឆ្នាំ១៩៩៨មកម្ល៉េះ។ ដែលធ្វើឱ្យមានការកែប្រែមុខមាត់ថ្មីនៃព្រះរាជាណាចក្រកម្ពុជា បានបង្ហាញឱ្យឃើញថាកម្ពុជាបាននឹង កំពុងបន្តបោះជំហានឥតឈប់ក្នុងឆាកអន្តរជាតិដែលបានសម្រេចនឹងនូវកំណើនសេដ្ឋកិច្ចខ្ពស់ និងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងបរិការណ៍អតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថេរភាពទាំងអស់បានឱ្យឃើញថានេះ ជាចំណុចមួយដែលទាក់ទងវិនិយោគទុនជាតិ និងអន្តរជាតិមកវិនិយោគទុនជាច្រើនគួរឱ្យកត់សម្គាល់ដែលជាចំណុចធ្វើឱ្យប្រមុខរាជរដ្ឋាភិបាលបាន នឹងបន្តការយកចិត្តទុកដាក់លើមន្ត្រីរាជការសាធារណៈ និងកម្មករនិយោជិកគ្រប់ទាំងវិស័យទាំងអស់នូវកម្ពុជា ចំពោះកិច្ចការគាំពារសង្គមដល់ប្រជាពលរដ្ឋខ្លួនតាមរយៈគោលនយោបាយជាតិគាំពារសង្គមដែល ក្នុងមានពីរប្រព័ន្ធគឺ ប្រព័ន្ធជំនួយសង្គម និងប្រព័ន្ធសន្តិសុខសង្គម។ដោយប្រើការបង្កើតច្បាប់ស្តីពីរបបសន្តិសុខសង្គមនូវកម្ពុជាដោយស្ថាបន័ប្រតិបត្តិនោះគឺបេឡាជាតិសន្តិសុខសង្គម។

បេឡាជាតិសន្តិសុខសង្គមដែលហៅកាត់ថា ប.ស.ស. គឺជាស្ថាប័នប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការលើរបបសន្តិសុខសង្គម ដូចមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់នេះ។ ប.ស.ស. ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម និងស្ថិតក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ។[1] ដើម្បីធានាបាននូវការយន្តទូទាត់សំណង និងសមភាពការងារផ្សេងៗដែលបានកើតឡើងចំពោះកម្មករនិយោជិកនៅឆ្នាំ ១៩៥៥ កម្ពុជាបានបង្កើតឱ្យមានរបបសន្តិសុខសង្គមសម្រាប់ធានាឱ្យបាន នូវសុខមាលភាពចំពោះកម្មករនិយោជិកនាសម័យនោះ ប៉ុន្តែរឿងដែលគួរឱ្យសោកស្តាយរបបទាំងនេះត្រូវបាន បំផ្លិចបំផ្លាញចោលទាំងស្រុងក្នុងរបបដ៏ខ្មៅងងឹតនោះគឺរបបប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ប្រជាពលរដ្ឋទទួលបានសេវាសុខាភិបាលដោយឥតគិតថ្លៃពីរដ្ឋ ហើយក្រោយពីការបោះឆ្នោតក្នុងកំឡុងឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើងជាថ្មីម្តងទៀត។ ដោយនាយកដ្ឋានមួយនេះមានភារកិច្ចទទួលខុសត្រូវអនុវត្តកិច្ចគាំពារសង្គម ដល់ប្រជាពលរដ្ឋក្នុងវិស័យឯកជន។ ដោយមានការយកចិត្តទុករបស់ប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទើបរដ្ឋាភិបាលបានសម្រេចបង្កើតឡើងច្បាប់ស្តីពី របបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារតាមរយៈច្បាប់នេះឈានដល់ការបង្កើតគ្រឹះស្ថានសាធារណៈមួយនេះឡើងនៅថ្ងៃទី០២ ខែមីនា ឆ្នាំ

[1] អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម,លេខ១៦ អនក្រ.បក,០២ មីនា ២០០៧, មាត្រា១។

២០០៧ ដោយអនុក្រឹត្យលេខ១៦ អនក្រ.កប ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម និងលេចចេញជារូបរាងជាផ្លូវការនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨។

ប៉ុន្តែដោយឃើញថាវិវត្តន៍ឥតឈប់នៃស្ថាប័នមួយនេះដែលស្របតាមរបបគាំពារសង្គមនៅកម្ពុជាការមានរីកចម្រើនឥតឈប់ឈរ ហើយបានបំពេញមុខងារជូនសមាជិកកាន់តែមានប្រសិទ្ធិភាពប្រកបដោយភាពស័ក្តសិទ្ធិ ទើបប្រមុខរដ្ឋាភិបាលបានបន្ថែមទៅការទទួលខុសត្រូវបន្ថែមទៀតទៅលើមន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។ដូច្នេះហើយទើបប្រមុខរដ្ឋាភិបាលបានសម្រេចចិត្ត ធ្វើវិសោធនកម្មច្បាប់ចាស់ក្នុងកំឡុងឆ្នាំ២០០២(យោងតាមមាត្រា១០៦ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម)ដែលច្បាប់នេះត្រូវប្រកាសចេញឱ្យប្រើប្រាស់ ជាផ្លូវការ នៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយព្រះរាជក្រមលេខ ០១៨ នស/រកម/១១១៩ ច្បាប់ស្តីពី របបសន្តិសុខសង្គម និងព្រះរាជក្រឹត្យលេខ ៥៨២ នស/រកត/០៥២០ ស្តីពីការបង្កើតគ្រឹះស្ថានរដ្ឋបាលដែលបានប្រកាសឱ្យប្រើថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ដែលប្តូរផ្លាស់ពីនាយកដ្ឋានបេឡាជាតិរបបសន្តិសុខសង្គម ទៅជាអគ្គនាយកដ្ឋានបេឡាជាតិសន្តិសុខសង្គមវិញ។ ក្នុងអនុវត្តនេះពិតជាបានរួមចំណែក ព្រមទាំងជួយសម្រាលបន្ទុកភាពក្រីក្រយ៉ាងសកម្មដល់កម្មករនិយោជិក និងសមាជិកទាំងអស់ពីភាពងាយធ្លាក់ចូលទៅក្នុងហានិភ័យនៃភាពក្រីក្រដែលងើបមិនរួច របស់សមាជិកទាំងអស់ផងដែរ។

លើសពីក្នុងស្ថានភាពបែបនេះបានជួយជម្រុញ នូវភាពរីកចម្រើនយ៉ាងខ្លាំងខ្លានៃផ្នែកសេដ្ឋកិច្ចជាតិ ដើម្បីធានាឱ្យបានលើផ្នែកសន្តិសុខសង្គមរបស់ប្រជាជន ដែលជាសមាជិកទាំងអស់របស់ ប.ស.ស. ព្រមទាំងរួមចំណែកដល់ការចែករំលែកលើការកាត់បន្ថយបន្ទុកនៃភាពក្រីក្រ និងសាមគ្គីធម៌របស់សង្គមទៀតផង។ បើទោះបីជាបេឡាជាតិសន្តិសង្គមមានតួនាទីយ៉ាងនេះហើយ ក៏មានការសហការពីគ្រឹះស្ថានសហគ្រាសសាធារណៈ និងឯកជនទាំងអស់មិនគួរគេចវេចពីការចុះបញ្ជិការ និងបង់ភាគទានមកកាន់ ប.ស.ស. ដោយសហគ្រាសគ្រឹះស្ថានទាំងនោះមិនចង់មានការចំណាយក្នុងការបង់ភាគទាន និងទាន់មានការយល់ដឹងច្បាប់ពី អត្ថប្រយោជន៍ក្នុងការចូលជាមួយសមាជិក ប.ស.ស. ពោលគឺពុំមានទំនុកចិត្តនៅឡើយ។ ចំណែកសមាជិកជាបុគ្គលិក ឬមន្ត្រីរាជការស៊ីវិលទាំងអស់មិនទាន់យល់ដឹងច្បាស់ពីការទទួលបានការតាវលិកហានិភ័យការងារ ថែទាំសុខភាព និងការព្យាបាលតាមបែបវេជ្ជសាស្ត្រនោះទេដែល ជាហេតុធ្វើឱ្យសមាជិកទាំងអស់នេះមានការខាតបង់ប្រយោជន៍ដែលទទួលបានការផ្តល់នូវតាវកាលិកជាច្រើនពីសំណាក់ ប.ស.ស.។

ជាក់ស្តែង បេឡាជាតិសន្តិសុខសង្គម ជាស្ថាប័នដែលបម្រើ និងគ្រប់ដណ្តប់លើការគ្រប់គ្រងនៃរបបសន្តិសុខសង្គមនូវកម្ពុជាដែលផ្តល់ដល់ការជួយទៅ ការព្យាបាលជំងឺដោយឥតគិតថ្លៃទៅលើទៅសមាជិកដែលបានទទួលរងគ្រោះដោយគ្រោះថ្នាក់ស្តីពីការងារ នៅពេលដែលខ្លួនធ្វើដំណើរទៅធ្វើដោយត្រង់ទៅកន្លែងធ្វើការ ឬគ្រោះថ្នាក់ចៃដន្យនៅពេលដែលកំពុងនឹងបម្រើការងារជូនស្ថាប័នខ្លួនផ្នែកហានិភ័យការងារបាននឹងដំណើរតាំងពីឆ្នាំ២០០៨មកម្ល៉េះ។ លើសពីស្ថាប័នមួយនេះបាននឹងបន្តគ្រប់គ្រងលើរបបថែទាំសុខភាពដែលសមាជិកបានអាចពិគ្រោះ នឹងព្យាបាលដោយឥតគិតថ្លៃនៅពេល

ដែលសមាជិករូបនោះមានជំងឺឬមានអាការៈណាមួយ នឹងកំពុងតែជំរុញនឹងដាក់ឱ្យដំណើរនៅរបប ប្រាក់សោធន ពេលដែលសមាជិកបានចុះបញ្ជិកាជាមួយនឹងរបបនេះហើយបាននឹងដែលកំណត់គ្រប់លក្ខខណ្ឌអាចប្រាក់សោធន នៅពេលដែលខ្លួនចូលនិវត្តន៍។ដោយមានដំណើរវិវត្តន៍នៃឈប់នៃរបប សន្តិសុខសង្គមនៅកម្ពុជា បានចូលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រយ៉ាងច្រើនគួរសម ព្រមទាំងពង្រឹងសមត្ថភាពរបស់ស្ថាប័នដើម្បីផ្តល់នូវសេវាកម្មយ៉ាងល្អដែលមានគុណភាព តម្លាភាពជូនសមាជិកខ្លួន និងជួយសម្រេចគោលដៅរបស់ស្ថាប័នប្រតិបត្តិករមួយនេះ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បេឡាជាតិសន្តិសុខសង្គមគឺជាចំណែកមួយដែលបានចូលរួមក្នុងការ ពង្រីកសក្តានុពលយ៉ាងខ្លាំងខ្លាដោយយោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ ដោយភាពបត់បែន និងច្នៃប្រឌិតខ្ពស់របស់ថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់របស់ ប.ស.ស. បាននឹងបន្តការផ្តល់ជាប្រយោជន៍ដល់សមាជិកខ្លួនដោយឥតឈប់ឈរជាងមួយសត្សវត្សន៍មកហើយ។ ការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំនៃសមាជិកបានធ្វើ ប.ស.ស. បានបោះជំហានទៅមុខក្នុងការធានាឱ្យបាននូវនិរន្តភាពការប្រើប្រាស់របស់សេវារបស់សមាជិកខ្លួនទើបមាន ការចុះកិច្ចព្រមព្រៀងជាមូលដ្ឋានសុខាភិបាលរដ្ឋ និងឯកជនជាច្រើនក្នុងប្រទេសកម្ពុជា។ កាលណាប្រទេសជាតិបាននឹងកំពុងរីកចម្រើនក្នុងវិស័យនេះបានធ្វើឱ្យមានការកត្តាជំរុញដល់ វិស័យសុខាភិបាលនៅក្នុងប្រទេសមួយនេះឱ្យកាន់តែមានការរីកចម្រើនជឿនលឿនទៅតាមនោះដែល។ ដែលនេះហើយបាននាំឱ្យមានជាបញ្ហាចោទជាសំណួរជាច្រើនទាក់ទងទៅ នឹងការវិវត្តន៍របស់បេឡាសន្តិសុខសង្គមនូវកម្ពុជា។ ក្នុងនោះផងដែលក្រុមយើងខ្ញុំបានយកសំណួរ ៣សំណួរមកធ្វើការចោលសួរ៖

- តើរបបសន្តិសុខសង្គមនូវកម្ពុជាបានបន្តផ្តល់គុណប្រយោជន៍អ្វីខ្លះ ទៅលើប្រជាពលរដ្ឋកម្ពុជានាពេលបច្ចុប្បន្ន?
- តើបេឡាជាតិសន្តិសុខសង្គមបានបន្តដំណើរការវិវត្តន៍ខ្លួនយ៉ាងដូចម្តេច ដែលបម្រើឱ្យសាធារណៈជនដែលជាសមាជិកអស់ទាំងអស់របស់ខ្លួននាពេល១ទសវត្សន៍ចុងក្រោយ?
- តើបេឡាជាតិសុខសង្គមបានជួបនូវបញ្ហាប្រឈម និងមានដំណោះស្រាយអ្វីខ្លះ ដើម្បីបំពេញជាប្រយោជន៍របស់សាធារណៈជនដែលជាសមាជិករបស់ខ្លួន?

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវនេះមាន៖

- ស្វែងយល់អំពីតួនាទីយ៉ាងលំអិតពីនៃប្រតិបត្តិកររបស់ ប.ស.ស.
- ស្វែងយល់ពីភាពបត់បែននៃការដំណើរនៃបច្ចេកទេសរបស់របបនេះ
- ស្វែងយល់ពីស្ថានភាពនៃដំណើរនៃការប្រតិបត្តិ នៃរបបនេះដើម្បីធានាបាននូវស្ថេរភាពដល់សមាជិក

- ស្វែងយល់ពីបញ្ហាប្រឈមរបស់ស្ថាប័នប្រតិបត្តិករនេះ នៃរបបនេះដើម្បីធានានូវស្ថេរភាពរបស់សមាជិក ដើម្បីបញ្ចៀសឱ្យបាននូវការបាត់បង់អត្ថប្រយោជន៍របស់ពួកគេ

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ផ្ដើមចេញពីការសិក្សាដ៏ស៊ីជម្រៅមួយជាក់លាក់ ការកំណត់ពីកម្រិតនៃព្រំដែនដើម្បីធ្វើការសិក្សាស្រាវជ្រាវ គឺពិតជាមានសារៈសំខាន់ណាស់។ ក្នុងទសវត្សន៍ចុងក្រោយនេះជាសម័យកាលដែលមានការរីកចម្រើនខ្លាំងនៃសេដ្ឋកិច្ចនានា ដែលនាំឱ្យបណ្ដាប្រទេសនានាលើសកលដែលមានការហ៊ុំព័ទ្ធទៅដោយការកើនឡើងខ្លាំងទំនិញ ដែលជាចំណុចសមបង្ហាញឱ្យថាសេដ្ឋកិច្ចលើបណ្ដាប្រទេសនានាមានការរីកចម្រើនឥតឈប់ឈរដែល ជាហេតុធ្វើឱ្យមានគម្លាតអ្នកមាននិងអ្នកក្រពិតជាមានការខុសគ្នាឆ្ងាយណាស់។ លើសនេះ ការគាំពារសន្តិសុខសង្គមលើបណ្ដាប្រទេសមួយពិតជាមានសារៈសំខាន់ដែលជួយធានានូវនិរន្តភាពសេដ្ឋកិច្ចគ្រួសារមិនថាបុគ្គលនូវវិស័យឯកជន ឬ បុគ្គលដែលជាមន្ត្រីរាជការសាធារណៈក៏ពិតត្រូវការ ការគាំពារនៃរបបសន្តិសុខសង្គមទៅសេវាថែទាំសុខភាព នឹងហានិភ័យការងារហើយក៏ពិតជាមានសារៈប្រយោជន៍ខ្លាំងណាស់ដែលជាហេតុនាំឱ្យ ក្រុមយើងខ្ញុំធ្វើការសម្រេចចិត្តលើកយកការសិក្សាស្រាវជ្រាវស្ដីពីប្រធានបទ៖ ”**ដំណើរការវិវត្តន៍នៃរបបសន្តិសុខសង្គមនៅប្រទេសកម្ពុជា**”។ ដូចដែលបានដឹងស្រាប់ហើយថាបេឡាជាតិសន្តិសុខសង្គមគឺជា ប្រភេទគ្រឹះស្ថានរដ្ឋបាលសាធារណៈដែលមានវិសាលភាពគ្របដណ្ដប់លើគ្រប់វិស័យ និង ការគាំពារឱ្យមានរបបសន្តិសុខសង្គមនូវកម្ពុជា។ តួយ៉ាងការប្រែប្រួលបទបញ្ញត្តិនិងកំណែទម្រង់និតិវិធីរដ្ឋបាលផ្សេងៗ។ល។ ក្នុងសម័យកាលដែលសេដ្ឋកិច្ចប្រទេសមានការប្រែប្រួលឥតឈប់ឈរនៃកំណើនសេដ្ឋកិច្ច និងនយោបាយប្រទេសតម្រូវឱ្យមានការលេចឡើងនូវបញ្ហាជាច្រើនដែលអាចនាំឱ្យមានកិច្ចគាំពារសង្គមផ្សេងៗ ទៅវិស័យឯកជននិងវិស័យសាធារណៈទៅលើការគាំពារសុខភាពសាធារណៈដែលចំណុចដែលមិនអាចខ្វះបាននោះឡើយ នូវរបបសន្តិសុខសង្គម ដែលក្រោមការដឹកនាំរបស់ថ្នាក់ដឹករបស់បេឡាជាតិសន្តិសុខសង្គមគ្រប់ជាន់ថ្នាក់។ ប៉ុន្តែអ្វីដែលយើងត្រូវបានកំណត់នូវដែនកំណត់នូវការសិក្សាស្រាវជ្រាវនោះមកត្រឹមតែ "ដំណើរការវិវត្តន៍នៃរបបសន្តិសុខសង្គមនៅប្រទេសកម្ពុជាក្នុងកំឡុង ឆ្នាំ២០១៦ដល់ឆ្នាំ២០១៨” តែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ជាការពិតណាស់ការសិក្សាស្រាវជ្រាវមួយ បើសិនមិនអាចស្វែងរកឃើញពីសារៈសំខាន់បាននោះទេ វាហាក់បីដូចជាឥតន័យខ្លឹមសារទាល់តែសោះ។ ដូច្នេះក្រោយពីយើងខ្ញុំបានសិក្សាស្រាវជ្រាវហើយ យើងខ្ញុំបានរំពឹងទុកនឹងអាចយកនូវដំណើរ និងប្រតិបត្តិការយ៉ាងឈ្លាសវៃទៅលើការទាញយកនូវបច្ចេកទេសមកប្រើប្រាស់ទៅលើមុខងារនៃប្រតិបត្តិបច្ចេកទេសមួយបានយ៉ាងច្បាស់លាស់។ ម្យ៉ាងវិញទៀតក្ដីសង្ឃឹមយ៉ាងមុតមាំជាងនេះទៅទៀតនោះ គឺការអាចប្រែក្លាយជាដឹងច្បាស់ពីឈោងចាប់ឱកាសដែលបានមកពីបច្ចេកទេសរបស់ ប.ស.ស. ផងដែរ។ក្រៅពីនេះទៀតយើងបានរំពឹងដែលថានឹងអាច៖

- ចំពោះស្ថាប័នពាក់ព័ន្ធ
  - អាចជួយដល់ស្ថាប័នដែលចាប់អារម្មណ៍ទៅលើ ប.ស.ស. អាចសិក្សាស្វែងយល់បានយ៉ាងស៊ីជម្រៅបន្ថែមទៀតទៅលើដំណាក់កាលនីមួយៗប្រតិបត្តិការរបស់ ប.ស.ស. កំពុងប្រើប្រាស់
  - អាចស្វែងយល់ពីដំណើរនៃបទពិសោធន៍នៃទទួលបាននូវបច្ចេកទេសដែល ប.ស.ស. ធ្លាប់បានឆ្លងកាត់ជាច្រើនឆ្នាំមកនេះ
  - អាចស្វែងយល់ពីផល
  - វិជ្ជមាន និងផលអវិជ្ជមាន នៃការប្រើប្រាស់បច្ចេកទេសរបស់ ប.ស.ស.
  - អាចស្វែងយល់ពីរបៀបដោះស្រាយបញ្ហាក្នុង ប.ស.ស. ជាបច្ចេកទេស។
- ចំពោះខ្លួនឯង
  - ពង្រឹងសមត្ថភាពនៃការសិក្សាស្រាវជ្រាវជាលក្ខណៈផ្លូវការបន្ថែមមួយកម្រិតទៀត
  - ស្គាល់ពីវិសាលភាព និងសេវាកម្មដែលមានភ្ជាប់ដោយបច្ចេកទេសទំនើបៗជាងមុនបន្ថែម
  - យល់ដឹងពីស្ថាប័នចម្រុះគាំពារសង្គមដែលមានលក្ខណៈស្តង់ដារដូចជា ប.ស.ស.
  - ស្គាល់ពីប្រតិបត្តិការ ការគ្រប់គ្រង និងការផ្តត់ផ្គង់សេវាកម្មគាំពារសង្គមដោយបច្ចេកទេសរបស់ ប.ស.ស. ។
- ចំពោះនិស្សិត មិត្តអ្នកអាន និងអ្នកស្រាវជ្រាវដទៃទៀត
  - បង្កើនឯកសារឱ្យរឹតតែសម្បូរបែបបន្ថែមទៀត
  - អាចឱ្យនិស្សិតជំនាន់ក្រោយធ្វើការសិក្សាស្រាវជ្រាវបន្តទៀតដោយមានភាពងាយស្រួល។

## ៦. វិធិសាស្ត្រនៃការសិក្សាស្រាវជ្រាវ

### ក. ប្រភេទនៃវិធីសាស្ត្រក្នុងការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវរបស់អត្ថបទសិក្សាស្រាវជ្រាវមួយនេះ គឺប្រើប្រាស់ស្រាវជ្រាវតាមបែបគុណភាព (Qualitive Research Approach)។វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព គឺជាប្រភេទការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រសង្គមដោយត្រូវការ និងធ្វើការប្រមូលទិន្នន័យដែលមិនមែនជាលេខ (Non numerical Data)។ ហើយវិធីសាស្ត្រស្រាវជ្រាវមួយនេះមានគោលបំណងព្យាយាមស្រាយអត្ថន័យចេញពីក្នុងសង្គមតាមរយៈការសិក្សាទៅលើប្រជាជនឬទីកន្លែងដែលជ្រើសរើសក្នុងការស្រាវជ្រាវ។

ការជ្រើសរើសយកវិធីសាស្ត្របែបគុណភាពនេះ ក៏ដោយសារតែប្រធានបទទាមទារឱ្យមានការបកស្រាយច្បាស់លាស់ទៅលើបាតុភូត ឬស្ថានភាពដែលកើតមានឡើងនៅក្នុងការសម្រេចចិត្តហើយត្រូវការវិភាគយ៉ាងស៊ីជម្រៅទៅលើបញ្ហាដែលបានកើតឡើង ដែលបញ្ហាទាំងអស់នោះមិនអាចយកនូវតួលេខបាន។ជាងនេះទៅទៀត ទើបយើងខ្ញុំមានគោលបំណងចង់ដឹងឱ្យកាន់តែច្បាស់លាស់អំពីហេតុផល គំនិត និងការជម្រុញផ្សេងៗនៃបញ្ហា ឬបាតុភូត។ ដូច្នេះហើយការប្រើប្រាស់វិធីសាស្ត្រស្រាវតាមបែបគុណភាពមានភាពសុក្រឹត្យនឹងត្រឹមដោយយើងខ្ញុំអាចយក អត្ថបទនានា សៀវភៅ ឬស្រង់ទិន្នន័យតាមអ៊ីនធើណេតដែលពាក់ព័ន្ធនឹងប្រធានបទយកលំអិតទន្និន័យដែលមិនអាចក្លែងបាន។

### ខ. ការប្រមូលទិន្នន័យ

ចំពោះទិន្នន័យដែលយើងលើកយកមកធ្វើការស្រាវជ្រាវនេះ គឺមិនត្រឹមតែជា ទិន្នន័យបន្ទាប់បន្សំ (Secondary Data) មួយប្រភេទតែប៉ុណ្ណោះដែលបានត្រូវគេស្គាល់ថាជាវិធីសាស្ត្របន្ទាប់បន្សំនៃការប្រមូលទិន្នន័យ (Secondary methods of data collection) ដែលជាទិន្នន័យប្រមូលដោយនរណាម្នាក់មុន ហើយមិនមានការពាក់ព័ន្ធជាមួយ នឹងអត្ថបទសិក្សាស្រាវជ្រាវដែលប្រើប្រាស់ទិន្នន័យទាំងនោះ ដោយបានប្រមូលទិន្នន័យទាំងនេះត្រូវបាន អ្នកសិក្សាស្រាវជ្រាវផ្សេងទៀតយកប្រើប្រាស់ក្លាយទៅជាទិន្នន័យបន្ទាប់បន្សំដោយវាខុសគ្នាពី ទិន្នន័យចម្បង(Primary Data) ដែលជាទិន្នន័យទាំងឡាយដែលទទួលបានដល់ដៃអ្នកស្រាវជ្រាវដំបូងដោយខ្លួនគាត់ផ្ទាល់(Ajayi 2017)។

ការប្រមូលទិន្នន័យរបស់អត្ថបទស្រាវជ្រាវមួយនេះត្រូវបានប្រមូលចេញពីសៀវភៅ អត្ថបទសិក្សាស្រាវជ្រាវករណីសិក្សាផ្សេងៗ ក្នុងទម្រង់ជាឯកសារជារបាយការណ៍១០ឆ្នាំចុងក្រោយរបស់ ប.ស.ស. សៀវភៅដែលនិយាយពីគោលនយោបាយគាំពារសង្គម ច្បាប់នៃស្ដីការងារ ច្បាប់នៃរបបសន្តិសុខសង្គម(ផ្នែកសោធន ផ្នែកថែទាំសុខភាព និងហានិភ័យការងារ) ឯកសារផ្សេងៗតាមប្រព័ន្ធអ៊ីនធើណេត។ យ៉ាងណាមិញនៅក្នុងការជ្រើសរើសនូវទិន្នន័យយកមកប្រើប្រាស់នៅអត្ថបទសិក្សាស្រាវជ្រាវនេះ គឺត្រូវបានឆ្លងកាត់ការចម្រាញ់ជាច្រើនលើក ដោយធ្វើការជ្រើសរើសតែទិន្នន័យ ឬអត្ថបទដែលពាក់ព័ន្ធទាំងឡាយណាដែលមានតម្លៃឬអាចបន្ថែមទម្ងន់នៅក្នុងការសិក្សាស្រាវជ្រាវមួយនេះប៉ុណ្ណោះ។

### គ. វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបានគឺ តាមរយៈការស្រាវជ្រាវតាមបណ្ដាឯកសារនានា និងតាមរយៈការស្រាវជ្រាវនៅតាមបណ្ដាញអ៊ីនធើណេត ដោយផ្ដោតទៅលើការវិភាគអំពីប្រព័ន្ធទូទៅនៃដំណើរវិវត្តន៍របបសន្តិសុខសង្គម ដែលនៅក្នុងវិស័យឱ្យគាំពារសង្គមនូវក្នុងកម្ពុជា។ ជាមូលដ្ឋានក្នុងការវិភាគវែកញែក និងផ្ដល់ជាសេចក្ដីសន្និដ្ឋានឡើងគឺ តាមរយៈការប្រើប្រាស់ក្នុងប្រព័ន្ធសន្តិសុខសង្គមដែលកំពុងអនុវត្តនៅប្រទេសកម្ពុជា ដែលអាចផ្ដល់ជាទិន្នន័យគ្រប់គ្រាន់ ហើយបន្ទាប់មកក៏ធ្វើការបង្ហាញថាទិន្នន័យ និងតារាងដែលបានទាញយកមកដាក់ក្នុងខ្លឹមសារនៃអត្ថបទសិក្សានេះ ហើយដែលអាចផ្ដល់ជាការអធិប្បាយអំពីលទ្ធផលនីមួយៗបាន។

## ៧. រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

នៅក្នុងសារណាបញ្ចប់ការសិក្សានេះគឺ យើងបានបែងចែកជាបួនជំពូកសំខាន់ៗរួមមានដូចខាងក្រោម៖

**ជំពូកទី ១៖** នៅជំពូកនេះគឺយើងផ្ដោតសំខាន់ទៅលើរំលឹកទ្រឹស្ដី ព្រមទាំងរៀបរាប់លម្អិតអំពីប្រភេទនៃរបបមួយចំនួន ការប្រែប្រួលនៃស្ថាប័នប្រតិបត្តិករ និងដំណើរការវិវត្តន៍របស់ប្រព័ន្ធសន្តិសុខសង្គមដោយក្នុងនោះយើងបានយកទាំងគុណសម្បត្តិ និងគុណវិបត្តិមួយចំនួនមកធ្វើការបកស្រាយផងដែរ។

**ជំពូកទី ២៖** គឺយើងសិក្សាទៅលើស្ថានភាពទូទៅរបស់បេឡាជាតិសន្តិសុខសង្គម ដំណើរវិវត្តន៍របស់បេឡាជាតិមកដល់ពេលបច្ចុប្បន្ននេះ ចក្ខុវិស័យ បេសកម្មរបស់បេឡាជាតិ គុណតម្លៃ និងសិក្សាទៅលើទីតាំងនានាក្នុងរាជធានីខេត្តរបស់បេឡាជាតិសន្តសុខសង្គមនៅក្នុងប្រទេសកម្ពុជា។

**ជំពូកទី ៣៖** នៅក្នុងជំពូកនេះគឺ យើងបានធ្វើការសិក្សាស្រាវជ្រាវទៅប្រតិបត្តិការ ការប្រើប្រាស់បច្ចេកទេសនានា របស់បេឡាជាតិសន្តិសុខសង្គម នៅក្នុងប្រទេសកម្ពុជា ឥទ្ធិពលនៃបច្ចេកទេសនៅក្នុងប្រទេសកម្ពុជាទៅលើបេឡាជាតិសន្តិសុខសង្គម ដែលក្នុងនោះក៏មានចេញនូវលទ្ធផលនៃការស្រាវជ្រាវទាំងបញ្ហាប្រឈម និងអត្ថបទប្រយោជន៍ដែលកើតចេញពីបច្ចេកទេសលើប្រព័ន្ធសន្តិសុខសង្គមផងដែរ។

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១. និយមន័យ

### ១.១.១. ការវិវត្តន៍

គឺជារបៀបដែលភាវៈរស់ផ្លាស់ប្តូរ និងអភិវឌ្ឍន៍ក្នុងរយៈពេលវែង ដែលជាដំណើរកការផ្លាស់ប្តូរព្រមទាំងអភិវឌ្ឍន៍បន្តិចម្តង។

### ១.១.២. បច្ចេកទេស

គឺជាការអនុវត្តជាក់ស្តែងជាពិសេស ឧស្សាហកម្ម ការប្រើប្រាស់ការរកឃើញវិទ្យាសាស្ត្រ។ ទាក់ទងនឹងចំណេះដឹងម៉ាស៊ីន ឬវិធីសាស្ត្រដែលប្រើក្នុង វិទ្យាសាស្ត្រ និង ឧស្សាហកម្ម។

### ១.១.៣. សេវាកម្ម

គឺជាប្រព័ន្ធរដ្ឋាភិបាល ឬអង្គការឯកជនដែលទទួលខុសត្រូវ ចំពោះប្រភេទសកម្មភាពជាក់លាក់មួយឬសម្រាប់ការផ្តល់អ្វីដែលមនុស្សត្រូវការ។[2]

### ១.១.៤. ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិ

ច្បាប់ គឺជាបទបញ្ញត្តិដែលកំណត់ដោយរដ្ឋ ដែលមានភាពទៀងទាត់ត្រឹមត្រូវសម្រាប់ឲ្យពលរដ្ឋក្នុងសង្គមនីមួយៗត្រូវតែគោរពតាម និងជាបណ្តាវិធាន គតិយុត្តសម្រាប់គ្រប់គ្រង និងដឹកនាំប្រទេស។ ច្បាប់នៃសង្គមនីមួយៗ អាចមានភាពផ្សេងៗគ្នាទៅតាមភាពជាក់ស្តែងរបស់សង្គមនោះ។

បទប្បញ្ញត្តិ គឺការកំណត់តួនាទីរបស់ភាគីពាក់ព័ន្ធនឹងរបបថែទាំសុខភាពសង្គម កំណត់នីតិវិធីនៃការគ្រប់គ្រងហិរញ្ញវត្ថុ ប្រភពហិរញ្ញវត្ថុនិងអត្រាភាគទាន នីតិវិធីសម្រាប់កំណត់កញ្ចប់អត្ថប្រយោជន៍ និងកិច្ចការពារអតិថិជន ជាដើម។[3]

### ១.១.៤. យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រគោលដៅគឺ ជាកត្តាចម្បងក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យដែលមានលក្ខណៈទូលំទូលាយ ដើម្បីកំណត់ឱ្យច្បាស់ដើម្បីត្រៀមខ្លួនក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយនានានឹងកើតឡើងជាបន្តបន្ទាប់ ព្រមទាំងតភ្ជាប់ប្រព័ន្ធគ្រប់គ្រង នឹងចុះបញ្ជីជារួមសម្រាប់គ្រួសារក្រីក្រនិងងាយរងគ្រោះ។[4]

---

[2] គេហទំព័រ A process for mastering security evolution in the development lifecycle | SpringerLink ថ្ងៃទី០៧ ខែមិនា ឆ្នាំ២០១៥

[3] ក្នុងជំពូកទី៣ នៃប្រព័ន្ធសន្តិសុខសង្គមនៃសៀវភៅក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦ដល់ឆ្នាំ២០២៥) ឯកសារទទួលបានពីទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។

[4] ក្នុងជំពូកទី៣ នៃប្រព័ន្ធសន្តិសុខសង្គមនៃសៀវភៅក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦ដល់ឆ្នាំ២០២៥) ឯកសារទទួលបានពីទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។

## ១.២. ការប្រែប្រួល

### ១.២.១. ការប្រែប្រួលនៃរបបសន្តិសុខសង្គមតាមបែបឌីជីថល

ប្រព័ន្ធសន្តិសុខសង្គមធ្វើការឆ្លើយតបនៃការស្ទង់មតិនេះទាក់ទាញ ការយកចិត្តទុកដាក់ចំពោះផលប៉ះពាល់នៃសេដ្ឋកិច្ចឌីជីថលទៅលើសង្គមប្រព័ន្ធសន្តិសុខនៅអាមេរិក។ នៅទូទាំងទ្វីបអាមេរិកវាមិនច្បាស់ទេថាជាអ្វីផលប៉ះពាល់នៃការបង្កើនស្វ័យប្រវត្តិកម្មនិងមនុស្សយន្ត នឹងមានសម្រាប់តំបន់ផ្សេងៗគ្នាទីផ្សារការងារ។ ទោះយ៉ាងណាក៏ដោយហានិភ័យនៃការបង្ខូចទ្រង់ទ្រាយទីផ្សារការងារគឺពិតប្រាកដ។ ទាក់ទងនឹងផលប៉ះពាល់ខាងក្រៅលទ្ធផលបង្ហាញថាការផ្លាស់ប្តូរទីផ្សារការងារនិងការកើនឡើងនៃទម្រង់ការងារដែលមិនមានស្តង់ដារអាចបំផ្លាញមូលដ្ឋានហិរញ្ញប្បទាននៃការរួមចំណែកសន្តិសុខសង្គមកម្មវិធី។ ក្នុងន័យនេះកម្មវិធីសន្តិសុខសង្គមជាច្រើននៅក្នុងតំបន់នឹងបន្តពឹងផ្អែកយ៉ាងខ្លាំងលើធនធានសារពើពន្ធ។ វាត្រូវបានគេរំពឹងទុកថាតម្រូវការនិងការរំពឹងទុករបស់បុគ្គលធានារ៉ាប់រងនិងអ្នកទទួលផលនឹងផ្លាស់ប្តូរ។ជាការឆ្លើយតបកម្មវិធី សន្តិសុខសង្គមត្រូវតែវិវត្ត។ទាក់ទងទៅនឹងផលប៉ះពាល់ផ្ទៃក្នុងនៃសេដ្ឋកិច្ចឌីជីថលទៅលើរដ្ឋបាលសន្តិសុខសង្គម។ បញ្ហាប្រឈមអាទិភាពគឺតម្រូវការធ្វើស្វ័យប្រវត្តិកម្មដំណើរការអាជីវកម្ម។ អាទិភាពផ្សេងទៀតគឺ អភិវឌ្ឍន៍ សមត្ថភាពធនធានមនុស្សដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការការងា រការអនុម័តគំរូនៃការផ្តល់សេវាកម្មថ្មីនិងការកំណត់អត្តសញ្ញាណនិងការវិនិយោគលើបច្ចេកវិទ្យាថ្មីៗ និងប្រព័ន្ធប្រតិបត្តិការ។[5]

### ១.២.២. ការប្រែប្រួលនៃអត្រាភាគទាន

ការប្រែប្រួលនៃអត្រាភាគទានសម្រាប់របបសន្តិសុខសង្គមទាំងអស់ ត្រូវសិក្សាផ្អែកទៅលើផ្អែកមួយដែលដាក់ឱ្យដំណើរមុនគេដើម្បីយកមកពិគ្រោះយោបល់ជាសាធារណៈ ដើម្បីទទួលបានការគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងអស់ ទាំងស្ថាប័នរាជរដ្ឋាភិបាល តំណាងនិយោជក តំណាងនិយោជិត និងតំណាងប្រជាជនទូទៅ ដើម្បីកំណត់យកភាពជាក់លាក់នៃអត្រាភាគទាននេះឬធ្វើការតម្លើងអាត្រាភាគទានដោយកំណត់លើប្រាក់ចំណូលរបស់ប្រជាពលរដ្ឋដែលមានសមត្ថភាពអាចបម្រើការងាររបាន។[6]

### ១.២.៣. ការប្រែប្រួលកត្តាប្រជាសាស្រ្ត

សមិទ្ធិផលទាំងនេះបានទទួលបានក្នុងបរិបទនៃស្ថិរភាពនយោបាយ និងសង្គម និងឆ្លុះបញ្ចាំងពីភាពជោគជ័យនៃគោលនយោបាយកំណែទម្រង់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ដោយអនុវត្តលើយន្តការសេដ្ឋកិច្ចទីផ្សារ ការទាញយកឧត្តមភាពប្រៀបពីការប្រកួតប្រជែង និងតាមរយៈពេលការបង្កើតបរិដ្ឋានអំណោយផលសម្រាប់ការវិនិយោគ។

[5] សៀវភៅ TEN GLOBAL CHALLENGES FOR SOCIAL SECURITY ប្រទេស AMERICAS ឆ្នាំ២០១៧ ជំពូកសេចក្តីផ្តើម

[6] ក្នុងជំពូកទី៣ នៃប្រព័ន្ធសន្តិសុខសង្គមនៃសៀវភៅក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦ដល់ឆ្នាំ២០២៥) ឯកសារទទួលបានពីទីស្តីការគណៈរដ្ឋមន្រ្តី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧ ដែលយកទិន្នន័យមកសមាជិកសន្តិសុខសង្គមនៅតំបន់អាស៊ាន។

ការធ្លាក់ចុះនៃអត្រាក្រីក្រ និងមេគុណវិសមភាពនៃការប្រើប្រាស់ជាក់ស្តែងឡើង ទន្ទឹមនឹងការរីកចម្រើននៃទីផ្សារការងារនៃសកលលោក។ ការរីកចម្រើននៃវិស័យឯកជន និងពិពិធកម្មសេដ្ឋកិច្ចបានស្រូបយកកម្លាំងពលកម្មកាន់តែច្រើនឡើងជាលំដាប់ចេញពីវិស័យផលិតកម្មប្រពៃណី ជាពិសេសវិស័យកសិកម្ម ទៅកាន់វិស័យកម្មន្តសាលកម្ម ឧស្សាហកម្ម និងសេវាកម្មសាកល។

## ១.៣. ប្រភេទនៃរបបសន្តិសុខសង្គម

បេឡាជាតិរបបសន្តិសុខសង្គមគឺ ជាទីភ្នាក់ងាររដ្ឋាភិបាលប្រទេសទាំងមូលដែលទទួលខុសត្រូវចំពោះការប្រមូលភាគទានការរក្សាសុវត្ថិភាពការវិនិយោគប្រកបដោយការទទួលខុសត្រូវ និងការបែងចែកប្រាក់ចូលនិវត្តន៍របស់និយោជិតទាំងផ្នែកផ្លូវការនិង ក្រៅផ្លូវការនៃសេដ្ឋកិច្ចប្រទេសមួយដែលជា ការចូលរួមទាំងនិយោជកនិងនិយោជិតគឺជាកាតព្វកិច្ចក្នុងបង់ភាគទាន។ មូលនិធិនេះគឺជាមូលនិធិសោធននិវត្តន៍និងមូលនិធិទ្រទ្រង់ក្នុងការថែរក្សាសុខភាពព្រមទាំងសុខាមាភាពគ្រួសារ។[7]

### ១.៣.១. សេវាកម្មនៃរបបសោធន

របបប្រាក់សោធននិវត្តន៍ជាតិ (NPS) គឺជាប្រព័ន្ធប្រាក់សោធននិវត្តន៍ដែលបានកំណត់ដោយស្ម័គ្រចិត្តគ្រប់គ្រងនិងគ្រប់គ្រងដោយអាជ្ញាធរបញ្ញត្តិកម្មនិងអភិវឌ្ឍន៍ (Development) មូលនិធិសោធននិវត្តន៍ (PFRDA) ដែលបង្កើតឡើងដោយច្បាប់រដ្ឋសភារបស់ប្រទេសមួយ។[8]

### ១.៣.២. សេវាកម្មនៃផ្នែកថែទាំសុខភាព

របបថែទាំសុខភាព គឺជាការរៀបចំរបស់ស្ថាប័នរដ្ឋាភិបាល និងធនធានដែលផ្តល់សេវាថែទាំសុខភាពដើម្បីបំពេញតម្រូវការពិនិត្យ និងពិគ្រោះសុខភាពរបស់ប្រជាជនគោលដៅ។[9]

### ១.៣.៣. សេវាកម្មនៃផ្នែកហានិភ័យការងារ

របបថែទាំសុខភាព គឺជាការរៀបចំរបស់ស្ថាប័នរដ្ឋាភិបាល និងធនធានដែលផ្តល់សេវាថែទាំសុខភាពដើម្បីបំពេញតម្រូវការពិនិត្យ និងពិគ្រោះសុខភាពរបស់ប្រជាជនគោលដៅ។[10]

### ១.៣.៤. សេវាកម្មនៃនិកម្មភាពការងារ

របបនិកម្មភាពការងារ គឺសំដៅដល់វេលាបុគ្គលជាសមាជិក ប.ស.ស. មិនមានសកម្មភាពការងារដែលមានប្រាក់ចំណូលឬទំនេរពីការងារដោយសសារការបញ្ចប់កិច្ចសន្យា ហើយសាមីជនបានស្វះស្វែងរកការងាររយៈពេលមួយស្របតាមការកំណត់នៃច្បាប់ឬបទប្បញ្ញត្តិបន្ទាប់ពីនិកម្មភាព។[11]

---

[7] ដកស្រង់ចេញគេហទំព័រ https://en.wikipedia.org/wiki/National_Social_Security_Fund_(Kenya)#History ប្រទេស Kenya កែប្រែនៅថ្ងៃទី១៣ ខែមេសា ២០២១

[8] ដកស្រង់ចេញគេហទំព័រ https://en.wikipedia.org/wiki/Pension_fund ប្រទេសអាមេរិកកែប្រែនៅថ្ងៃទី១៦ខែសីហាឆ្នាំ២០២១

[9] ដកស្រង់ចេញគេហទំព័រ https://en.wikipedia.org/wiki/Health_system_ កែប្រែនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១

[10] ដកស្រង់ចេញគេហទំព័រ https://en.wikipedia.org/wiki/Health_system_ កែប្រែនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២១

[11] ក្នុងជំពូកទី៣ នៃប្រព័ន្ធសន្តិសុខសង្គមនៃ សៀវភៅក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦ដល់ឆ្នាំ២០២៥) ឯកសារទទួលបានពីទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។

### ១.៣.៥. ការគ្រប់គ្រងលើហិរញ្ញវត្ថុ( សាធារណៈ)

ហិរញ្ញវត្ថុ គឺជាសាខានៃសេដ្ឋកិច្ចដែលសិក្សាពីសកម្មភាពសេដ្ឋកិច្ចរបស់ស្ថាប័នមួយឬ ច្រើន ដែលអនុវត្តដោយបុគ្គលក្រុមហ៊ុនអង្គការឬអង្គភាពសាធារណៈ។[12]

## ១.៤.កម្មវត្ថុនៃរបបសន្តិសុខសង្គម[13]

### ១.៤.១.ចក្ខុនៃរបបសន្តិសុខសង្គម

កម្រិតនៃសកលលោកបាន ការការពារសន្តិសុខសង្គមនៅកម្រិតខ្ពស់គ្រប់ពេលវេលា និងការធានារ៉ាប់រងបានបន្តកើនឡើងជាលំដាប់។ ផ្ដោតលើការប្ដេជ្ញាចិត្តផ្នែកនយោបាយដ៏ល្អនិង ឧត្តមភាពនៅក្នុងរដ្ឋបាលសន្តិសុខសង្គមកំពុងផ្លាស់ប្ដូរជីវិតនិង បង្កើតសង្គមទាំងមូលក្នុងតំបន់នៃពិភពលោក។

### ១.៤.២. គោលដៅរបស់របបសន្តិសុខសង្គម

សហគមន៍សាកល នៃអ្នកជំនាញផ្នែកសន្តិសុខសង្គម ដែលបង្កើតឡើងសមាជិកនៃសមាគមសន្តិសុខសង្គមអន្តរជាតិ (ISSA) ប្ដេជ្ញាចិត្តទ្រទ្រង់និង ពង្រីកការការពារសន្តិសុខសង្គមបន្ថែមទៀតស្របតាមគោលបំណងនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព របស់អង្គការសហប្រជាជាតិសម្រាប់ឆ្នាំ ២០៣០ គោលបំណងដែលមានមហិច្ឆតាយើងត្រូវស្វែងយល់ឱ្យបានច្បាស់អំពីបញ្ហាប្រឈមដែលយើងជួបនិងអភិវឌ្ឍន៍។

### ១.៤.៣. ចក្ខុវិស័យរបស់របបសន្តិសុខសង្គម

ធានាផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។

### ១.៤.៤. បេសកម្មរបស់របបសន្តិសុខសង្គម

ផ្តល់សេវាកម្មផ្នែកសន្តិសុខសង្គម ប្រកបដោយតម្លាភាព គណនេយ្យភាព និងទាន់ពេលពេលវេលា សម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ក្នុងគោលដៅជួយសម្រាលការលំបាកនានា នៅពេលជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀត ដូចជាជំងឺ និងមាតុភាពជាដើម។

---

[12]ដកស្រង់ចេញគេហទំព័រ https://km.wikipedia.org/wiki កែប្រែនៅថ្ងៃសុក្រ ទី១០ ខែកុម្ភៈ ឆ្នាំ២០១៧

[13] សៀវភៅ TEN GLOBAL CHALLENGES FOR SOCIAL SECURITY ប្រទេស AMERICAS ឆ្នាំ២០១៧ ជំពូកទី១

# ជំពូកទី២

# ស្ថានភាពទូទៅរបស់បេឡាជាតិសន្តិសុខសង្គម

## ២.១. ប្រវត្តិនៃបេឡាជាតិសន្តិសុខសង្គម

### ២.១.១. ប្រវិត្តនៃការកកើតបេឡាជាតិសន្តិសុខសង្គម

សន្តិសុខសង្គមត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៥៥ យោងតាមព្រះរាជក្រឹត្យលេខ៥៥ និង៣០៦។តែគួរឲ្យសោកស្តាយកំឡុងពេលរបប ប្រល័យ ពូជសាសន៍ (១៩៧៥-១៩៧៩) សន្តិសុខសង្គមនេះត្រូវបានបំផ្លាញចោលទាំងស្រុង។ពីឆ្នាំ១៩៧៩ ដល់ ១៩៩៣ ប្រជាជនបានទទួលសេវាថែទាំសុខភាពដោយ ឥតគិតថ្លៃ។បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើង។ នាយកដ្ឋាននេះទទួលខុសត្រូវការរៀបចំទាំងអស់នៃប្រកាសសម្រាប់ ការអនុវត្តកិច្ចគាំពារសន្តិសុខសង្គមដល់ប្រជាជនដែលធ្វើការក្នុងវិស័យឯកជន។ជាលទ្ធផលការកែប្រែបទប្បញ្ញត្តិស្តីពីច្បាប់ការងារឆ្នាំ១៩៩២ដែលជាច្បាប់ការងារ កម្ពុជា បច្ចុប្បន្នដែលអនុម័តក្នុងឆ្នាំ១៩៩៧ ត្រូវបានអនុវត្តដោយនាយកដ្ឋានការងារ(ថ្មីៗនេះប្តូរទៅជាអគ្គនាយកដ្ឋានការងារ)។បន្ទាប់ពីនោះមក ច្បាប់សន្តិសុខសង្គម ត្រូវបានអនុម័តដោយសភា នៅខែកញ្ញា ឆ្នាំ២០០២ ដែលថ្មីៗត្រូវបានគេស្គាល់ថាច្បាប់របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃ ច្បាប់ស្តីពីការងារ។ អនុក្រឹត្យស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមត្រូវបានអនុម័ត នៅឆ្នាំ២០០៧ ដែលបង្កើតឡើងដើម្បីជំនួសនាយកដ្ឋានសន្តិសុខសង្គម។ប.ស.ស. ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងផ្នែកកិច្ចគាំពារសន្តិសុខសង្គមឱ្យស្របទៅតាមច្បាប់សន្តិសុខសង្គមជាតិ និង បទប្បញ្ញត្តិសន្តិសុខសង្គមអនុលោមតាមអនុក្រឹត្យ។ ក្រោយពីការរៀបចំដ៏ធំទូលាយនេះ ប.ស.ស. ត្រូវបានដំណើរការនៅចុងឆ្នាំ២០០៨ ។

អនុលោមតាមច្បាប់ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ស្ថានភាពរីកចម្រើននៃសេដ្ឋកិច្ចជាតិ និងការធ្វើសមាហរណកម្មក្នុងតំបន់ បេឡាជាតិរបបសន្តិសុខសង្គម បាននិងកំពុងត្រៀមខ្លួនតាមរយៈការរៀបចំពង្រីក ពង្រឹង និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួនបន្ថែមទៀត ដោយបានរៀបចំនូវផែនការយុទ្ធសាស្ត្ររយៈពេលប្រាំឆ្នាំនេះឡើង ដែលមានចក្ខុវិស័យ និងបេសកកម្មដ៏ច្បាស់លាស់ ក្នុងការអនុវត្តផ្នែកសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងទាន់ពេលវេលាសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារឱ្យទទួលបាននូវសេវាសន្តិសុខសង្គម នៅពេលដែលពួកគាត់ជួបប្រទះនូវយថាភាពផ្សេងៗ មានជាអាទិ៍ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ ឬពេលជួបប្រទះយថាភាពផ្សេងៗទៀតដូចជាជំងឺ និងមាតុភាពជាដើម។

ក្នុងស្ថានភាពដែលប្រទេសកម្ពុជាមានការរីកចម្រើនលើគ្រប់វិស័យ ការធានាផ្នែកសន្តិសុខសង្គមមានសារៈសំខាន់ខ្លាំងណាស់ ដោយបានផ្តល់នូវការគាំពារចំពោះប្រជាជនកម្ពុជានិយាយជារួម និងនិយាយដោយឡែកសម្រាប់កម្មករនិយោជិត ដែលបម្រើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ដោយផ្អែកលើទស្សនាទាននៃការចែករំលែក និងគោលការណ៍សាមគ្គីធម៌ក្នុងសង្គមធានាបាននូវសន្តិ

សុខ ប្រាក់ចំណូល ពោលគឺមានន័យថា តាមរយៈការធានាផ្នែកសន្តិសុខសង្គម គ្មានសមាជិកសង្គមណាម្នាក់ធ្លាក់ទៅក្នុងហានិភ័យនៃភាពក្រីក្រ ដោយមិនអាចងើបរួចបានឡើយ។ម្យ៉ាងទៀតគោលនយោបាយសន្តិសុខសង្គម ក៏រួមចំណែកយ៉ាងសំខាន់ដល់គោល នយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគោលការណ៍នៃការចែករំលែកប្រាក់ចំណូល តាមខ្សែទទឹង និងខ្សែបណ្តោយ គឺមានន័យថា អ្នកមានប្រាក់ចំណូលខ្ពស់ជួយដល់អ្នកមានប្រាក់ចំណូលទាប អ្នកមានសុខភាពល្អ ជួយដល់អ្នកមានជំងឺ ជនពិការ ឬ អ្នកដែលទទួលរងនូវគ្រោះថ្នាក់ផ្សេងៗ ជនមានវ័យក្មេងជួយដល់ជនចាស់ជរា ដែលការនេះធ្វើឲ្យមនុស្សក្នុងសង្គមទាំងមូល ទទួលបាននូវភាពកក់ក្តៅក្នុងជីវភាពរស់នៅ ធានារក្សាបានស្ថិរភាព និងភាពសុខដុមរមនានៅក្នុងសង្គម។

ដើម្បីលើកកម្ពស់សុខុមាលភាពសង្គម ដោយការធានាឱ្យបាននូវសន្តិសុខប្រាក់ចំណូលរួមចំណែកកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ស្ថិរភាពសង្គម ប.ស.ស បានអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងាររួមមាន៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធនគ្រោងអនុវត្តនៅពេលឆាប់ៗខាងមុខនេះ។ ឈរលើការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពប្រកបដោយ ជោគជ័យ និងធានាឱ្យមានភាពសង្គតិភាពក្នុងការគាំពារសង្គមទាំងវិស័យឯកជន និងមន្ត្រីរាជការ ក្នុងវិស័យសាធារណៈ រាជរដ្ឋាភិបាលបានប្រគល់ភារកិច្ចឱ្យប.ស.ស ជាអ្នករៀបចំ និងគ្រប់គ្រងការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ សម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនចាប់ពី ឆ្នាំ២០១៧តទៅ។[14]

### ២.១.២. ទីតាំងនៃបេឡាជាតិសន្តិសុខសង្គម

បេឡាជាតិសន្តិសុខសង្គមមានទីតាំងស្ថិតនៅ ភូមិ បន្ទាស្អិត សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ និងមានសាខានៅតាមខេត្តក្រុងខណ្ឌតាមការចាំបាច់។[15]

### ២.១.៣. ស្លាកសញ្ញា និងអត្ថន័យនៃបេឡាជាតិសន្តិសុខសង្គម

ស្លាកសញ្ញាសម្គាល់នេះមានខ្លឹមសារ និងអត្ថន័យដូចខាងក្រោម៖

- មានរាងមូល រាងមូលព័ទ្ធដោយកួរស្រូវរាងស្វែងក្របីពណ៌ទឹកមាស រូបរាងខាងក្នុងមានរូបមនុស្សប្រុស-ស្រី នៅខាងក្នុងកងចក្រ និងគម្របពណ៌ទឹកសមុទ្ររាងជាពាក់កណ្តាលរង្វង់។នៅលើផ្ទៃគម្របកងចក្រមានអក្សរ"ប.ស.ស." និង"NSSF"។ ព័ទ្ធជុំវិញកងចក្រមានផ្ដុំតួអក្សររាងជារង្វង់ដាក់ថា "បេឡាជាតិសន្តិសុខសង្គម" និង "National Social Security Fund"

[14] ដកស្រង់ចេញពី Website (http://www.nssf.gov.kh/default/) របស់បេឡាជាតិសុខសន្តិសង្គម ឆ្នាំ២០១៩ (ភ្នំពេញ)

[15] អនុក្រឹត្យលេខ ០១អនក្រ.កបចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

❖ ក្បួរស្រូវពណ៌ទឹកមាសមាន ៩ថ្នាក់ តំណាងនូវតារាកាលិកទាំងប្រាំបួន ដែលចែងក្នុងបទដ្ឋានអន្តរជាតិស្តីពីសន្តិសុខសង្គម

❖ អក្សរបេឡាជាតិសន្តិសុខសង្គម និង National Social Security Fund ពណ៌ទឹកសមុទ្ររាងជារង្វង់ តំណាងឈ្មោះគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានបេសកម្មក្នុងការគ្រប់គ្រង និងចាត់ចែងរបបសន្តិសុខសង្គមសម្រាប់បុគលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះ

❖ ពាក់កណ្តាលរង្វង់គ្របកងចក្រពណ៌ទឹកសមុទ្រ ដែលមានអក្សរ ប.ស.ស. និង NSSF ពណ៌ស តំណាងនូវការការពារហានិភ័យសង្គម ចំពោះបុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះ

❖ រូបកងចក្ររាងពាក់កណ្តាលរង្វង់ពណ៌ទឹកសមុទ្រ តំណាងនូវការចូលរួមនៃវិស័យសាធារណៈ និងវិស័យឯកជន។រីឯកាំកងចក្រចំនួន១១ តំណាងនូវសមាសភាពក្រុមប្រឹក្សាភិបាលនៃបេឡាជាតិសន្តិសង្គមទាំង១១រូប

❖ រូបមនុស្សប្រុស ស្រីស្ថិតនៅក្នុងកងចក្រតំណាងនូវបុគ្គលនៃវិស័យសាធារណៈ និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រព្រមទាំងអ្នកបម្រើក្នុងផ្ទះដែលត្រូវទទួលបានការការពារពីរបបសន្តិសុខសង្គមតាមច្បាប់។[16]

[16] ប្រកាសលេខ ២១៦/២០ ក.ប/ប្រ.ក.ប.ស.ស. ស្តីពី ការអនុញ្ញាតឲ្យប្រើប្រាស់និមិត្តសញ្ញាសម្គាល់ប.ស.ស. ចុះថ្ងៃទី១ ខែកក្កដាឆ្នាំ២០២០

## ២.១.៤. ចក្ខុវិស័យ គោលបំណងរបស់បេឡាជាតិសន្តិសុខសង្គម[17]

### ២.១.៤.១. ចក្ខុវិស័យរបស់បេឡាជាតិសន្តិសុខសង្គម

ចក្ខុវិស័យរបស់ ប.ស.ស. គឺដើម្បីក្លាយជាអង្គភាពនាំមុខគេ ក្នុងការផ្តល់ឱ្យនូវសេវាសន្តិសុខសង្គម។

### ២.១.៤.២. គោលបំណងរបស់បេឡាជាតិសន្តិសុខសង្គម

- រៀបចំ និង គ្រប់គ្រងរបបសន្តិសុខសង្គមយោងតាមបទប្បញ្ញត្តិ នៃច្បាប់ដែលបានបង្កើតរបបសន្តិសុខសង្គមនេះសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។
- ធានាការផ្តល់តាវកាលិកដល់សមាជិកប.ស.ស (ជនដែលបានធានារ៉ាប់រង) ក្នុងគោលបំណងផ្តល់ឲ្យសមាជិកនូវសន្តិសុខប្រាក់ចំណូលក្នុងករណីដែលសមាជិករូបនោះ មានយថាភាពមួយចំនួនដូចជា៖ ជរាភាព ទុព្វលភាព មរណភាព ហានិភ័យការងារ និងគ្រោះថ្នាក់មួយចំនួនទៀត។
- ប្រមូលភាគទានពីសមាជិក និងនិយោជកទាំងអស់។
- ជួយសម្រួល និងរៀបចំបទប្បញ្ញត្តិនៃសេវាសង្គម និងសុខភាពជូនសមាជិកទាំងអស់។
- សហប្រតិបត្តិការជាមួយអង្គការនានាដែលទាក់ទងទៅនឹង៖
  - អប់រំ និងផ្សព្វផ្សាយយុទ្ធសាស្ត្រក្នុងការការពារហានិភ័យការងារ
  - និង ផ្សព្វផ្សាយវិធានការស្តីពីសុខភាព និងសុវត្ថិភាពនៅកន្លែងធ្វើការ។
  - សហប្រតិបត្តិការជាមួយនឹងអង្គការពាក់ព័ន្ធដើម្បីសិក្សា និងស៊ើបអង្កេតជំងឺវិជ្ជាជីវៈ។
  - គ្រប់គ្រងការវិនិយោគនៃមូលនិធិសន្តិសុខសង្គម។[18]

## ២.២. បេសកម្មរបស់បេឡាជាតិសន្តិសុខសង្គម

បេសកកម្មរបស់ប.ស.ស គឺដើម្បីបម្រើសេវាកម្មផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាពដល់សមាជិកទាំងអស់ដែលបានចុះបញ្ជិកាទាន់ពេលវេលាដើម្បីជួយបន្ធូរបន្ថយបន្ទុកក្នុងសង្គម និងជួយលើកកម្ពស់ស្ថិរភាពសង្គម។

- **ការប្តេជ្ញាចិត្តរបស់យើង**

▪ ការផ្តល់ជូននូវសន្តិសុខសង្គមជាមូលដ្ឋានសម្រាប់ប្រជាជនទាំងអស់ដែលកំពុងធ្វើការនៅក្នុងប្រទេសកម្ពុជា។

▪ បំលាស់ប្តូរនៃការសន្សំសំចៃក្នុងស្រុកសម្រាប់អភិវឌ្ឍជាតិ។

▪ លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសារៈប្រយោជន៍នៃសន្តិសុខសង្គម។

[17] ព្រះរាជក្រម នស/រកម/១១១៩/០១៨ ច្បាប់ស្តីពីរបបសន្តិសុខសង្គម ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ជំពូកទី១

- លើកកម្ពស់ការទទួលខុសត្រូវជាសមូហភាព។

❖ **តម្លៃស្នូល**

- សុច្ចរិតភាព
- តម្លាភាព
- ប្រសិទ្ធភាព និងប្រសិទ្ធផល។

## ២.៣. រចនាសម្ព័ន្ធ និងតួនាទីនៃបេឡាជាតិសន្តិសុខសង្គម[19]

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល និង ជានិតិបុគ្គលសាធារណៈ មានស្វ័យភាពផ្នែកហិរញ្ញវត្ថុ ដែលមានបេសកកម្ម បម្រើសេវាផ្នែកសាធារណៈរដ្ឋបាល មានលក្ខណៈសង្គមស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ និង អាណាព្យាបាល ហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ប.ស.ស ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃអនុក្រឹតលេខ ១៦ អនក្រ-បក ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើត ប.ស.ស ក៏ស្ថិតនៅក្រោមបទប្បញ្ញត្តិនៃ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ។




ii

## ២.៤. ដំណើរនៃការប្រត្តិបត្តិនៃរបបសន្តិសុខសង្គម

### ២.៤.១. ដំណើរវិវត្តន៍នៃផ្នែកហានិភ័យការងារ

អនុលោមតាម ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះទី០២ ខែមីនា

[19] ដកស្រង់ចេញពី Website (http://www.nssf.gov.kh/default/) របស់បេឡាជាតិសុខសន្តិសង្គម ឆ្នាំ២០១៩ (ភ្នំពេញ)

ឆ្នាំ២០០៧ ស្តីពីការបង្កើត ប.ស.ស. ទទឹមនឹងនេះ ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ ដែលជាជំហានទី១ ត្រូវបានដាក់ឱ្យអនុវត្តតាំងពីខែវិច្ឆិកា ឆ្នាំ ២០០៨ រហូតមកដល់បច្ចុប្បន្ននេះ បាននិងកំពុងចូលរួមចំណែកលើកកម្ពស់សុវត្ថិភាព និងសុខភាពនៅកន្លែងការងារ។

### ២.៤.២. ដំណើរការវិវត្តន៍នៃផ្នែកថែទាំសុខភាព

ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពនេះ ជាការអនុវត្តជំហានទី២ ត្រូវបានដាក់ចេញនៅក្នុង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ហើយត្រូវបង្កើតឡើងដោយអនុក្រឹត្យលេខ០១ អនក្រ.បកចុះថ្ងៃទី០៦ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំ សុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅ ក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ។ ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព គឺជា យន្តការពីរដែលត្រូវមានសង្គតិភាពនឹងគ្នា ដោយសារសុខភាពរបស់កម្មករនិយោជិតមិនអាចទទួលត្រឹមតែការគាំពារផ្នែកជំងឺ ឬគ្រោះថ្នាក់ដែលបណ្តាលមកពី ការងារប៉ុណ្ណោះទេ ប៉ុន្តែត្រូវមានការគាំពារចំពោះជំងឺ ឬគ្រោះថ្នាក់ទូទៅដែលមិនមានពាក់ព័ន្ធនឹងការងារផងដែរ។ ភាពផ្សារភ្ជាប់នៃការអនុវត្តរបបសន្តិសុខសង្គម ទាំងពីរផ្នែកនេះជាទំនាក់ទំនងដែលមានឥទ្ធិពលទៅវិញទៅមក និងផ្តល់នូវភាពពេញលេញក្នុងការគាំពារសុខភាពកម្មករនិយោជិត។ ផ្នែកនេះបាននិងកំពុង ចូលរួមចំណែកលើកកម្ពស់សុខភាពកម្មករនិយោជិត និងផ្តល់ការបង្ការជំងឺទូទៅ។

### ២.៤.៣. ការជំរុញនីខពន្លឿននៃផ្នែកសោធននិវត្តន៍

ក្រៅពីការកែទម្រង់របបសោធនសាធារណៈ រដ្ឋាភិបាល នឹងសិក្សាអំពីលទ្ធភាពក្នុងការរៀបចំដាក់ឱ្យដំណើរការរបបសោធនសម្រាប់វិស័យឯកជន ដែលស្ថិតនៅក្រោមច្បាប់ស្តីពីការងារ។របបនេះបាននឹងត្រូវធ្វើសមាហរណកម្មឱ្យស្ថិតនៅក្រោមប្រព័ន្ធគ្រប់គ្រងរួម និងមានសង្គតិភាពជារបបសោធនសាធារណៈ។ រាជរដ្ឋាភិបាល នឹងធ្វើការប្រឹក្សាយោបល់ជាមួយតំណាងនិយោជក និងតំណាងនិយោជិត ដើម្បីកំណត់អត្រាភាគទាន និងតាវកាលិកឱ្យមានលក្ខណៈសមស្រប និងអាចទទួលយកបាន។[20]

20

# ជំពូកទី៣

# ប្រតិបត្តិការបច្ចេកទេសរបស់បេឡាសន្តិសុខសង្គម

## ៣.១. យន្តការនៃការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជា

### ៣.១.១. ការគ្រោងនឹងដំណើរការរបបសោធនក្នុងពេលខាងមុខ

របបសោធន គឺសំដៅដល់កម្មករនិយោជិកឬ មន្ត្រីរាជការស៊ីវិល ដែលធ្លាក់ចូលក្នុងជរាភាព ទុព្វលភាព ឬមរណៈភាពរបស់មេគ្រួសារដែលទទួលបានបៀវត្សរ៍នៅពេលដែលខ្លួនពុំមានលទ្ធភាពប្រកបការងារឬ មានអាយុលើសពី៦០ឆ្នាំ។ដែលក្នុងត្រូវបែងចែកជា ប្រាំផ្នែក មានដូចជា របបសោធន៍ជរាភាព របបសោធន៍ទុព្វភាព របបសោធន៍ឧត្តរជីវី របបសោធន៍តាមរបបស្មគ្រ័ចិត្ត របបសោធន៍អយ្យកប្បញ្ញាត្តិ ហើយរបបនេះគ្រោងនឹងដាក់ដំណើរការក្នុងឆ្នាំ២០២១ ប៉ុន្តែដោយសារស្ថានភាពរីករាលដាលដោយកូវីតទើបត្រូវមានការពន្យាពេល។

### ៣.១.២. របបថែទាំសុខភាពដែលបានដំណើរការ

#### ៣.១.២.១. របបថែទាំសុខភាព

ថែទាំសុខភាព គឺជារបបគាំពារសង្គមមួយដែលធានារ៉ាប់រងចំពោះសមាជិក ប.ស.ស ដែលមានបញ្ហាសុខភាព ឬគ្រោះថ្នាក់ដែលមិនពាក់ព័ន្ធនឹងហានិភ័យការងារ នឹងត្រូវផ្តល់សេវាបង្ការសុខភាព តាវកាលិកព្យាបាល និងថែទាំវេជ្ជសាស្ត្រ និងទទួលបានប្រាក់ដំណាច់ប្រចាំថ្ងៃសម្រាប់រយៈពេលនៃការផ្អាកការងារដោយការព្យាបាលជំងឺ ឬ ការសម្រាកមាតុភាពសម្រាប់កម្មរនិយោជិត។

#### ៣.១.២.២.ដំណើរការអនុវត្តនៃរបបថែទាំសុខភាព

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពបានចាប់ផ្តើមអនុវត្តពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០១៦ ចំពោះកម្មករនិយោជិត នៃសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាក្នុងផ្នែកថែទាំសុខភាព និងត្រូវបានអនុវត្តតាមដំណាក់កាល។ ក្នុងដំណាក់ដំបូងអនុវត្តចំពោះសមាជិកប.ស.ស.ដែលបានចុះបញ្ជិកាផ្នែកថែទាំសុខភាព ជនរងគ្រោះថ្នាក់ការងារដែលបាត់បង់សមត្ថភាពអចិន្ត្រៃយ៍ និងឧត្តរជីវី (ប្រពន្ធ ឬប្តី) និងកូននៅក្នុងបន្ទុកផ្ទាល់ នៃសាមីជនជាសមាជិក ប.ស.ស ដែលទទួលមរណភាពដោយហានិភ័យការងារ។ បន្ទាប់មកត្រូវអនុវត្តចំពោះអ្នកនៅក្នុងបន្ទុកនៃសមាជិក ប.ស.ស ដែលរួមមានប្រពន្ធ ឬប្តី និងកូន។[21] ការអនុវត្តរបបនេះត្រូវចាប់ផ្តើមចេញពី សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងភូមិសាស្ត្រ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ។ ប៉ុន្តែបច្ចុប្បន្នរបបនេះបានពង្រីកដែនអនុវត្តរបស់ខ្លួនមកតាមបណ្តាលខេត្តមួយចំនួនបន្ថែមទៀតរួមមាន ខេត្តកំពង់ឆ្នាំង ខេត្ត បន្ទាយមានជ័យ ខេត្ត សៀមរាប ខេត្ត ព្រះសីហនុ និងខេត្ត ស្វាយរៀង។ ចំពោះសហគ្រាស គ្រឹះស្ថានដែល ប.ស.ស. ពុំទាន់បានចុះបញ្ជិកាក្នុងផ្នែកថែទាំសុខភាព ត្រូវបន្តអនុវត្តអនុសញ្ញារួមបទបញ្ជាផ្ទៃក្នុងស្របតាមបទ

[21] ប្រកាសស្តីពី ការកំណត់ដំណាក់កាល និងកាលបរិច្ឆេទនៃការអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព,លេខ ០៩៣/១៩ ក.ប/ប្រ.ក, ០៧ មីនា ២០១៦, ប្រការ ៥។

ប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ រហូតដល់មានការចុះបញ្ជិកាជាផ្លូវការពីបេឡាជាតិរបបសន្តិសុខសង្គម។ ចំណែករបបសន្តិសុខសង្គមផ្នែកថែទាំងសុខភាពសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធវិញ គឺប.ស.ស មានតួនាទីគ្រប់គ្រង និងចុះបញ្ជីកម្មករនិយោជិត និងបើកប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូនជូនដល់កម្មករនិយោជិតក្រៅប្រព័ន្ធតែប៉ុណ្ណោះ[22]។ ចំណែកតាវកាលិកថែទាំសុខភាពសម្រាប់ពួកគាត់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ[23]។ ចំពោះរបបថែទាំសុខភាពសម្រាប់មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន (មានចែងក្នុងមាត្រា ៣នៃព្រះរាជក្រឹត្យលេខ០៧៨ នស/រកត/០២១៧ ) ប.ស.ស បានដាក់ដំណើរការជាផ្លូវការនៅថ្ងៃ ទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៧ ដោយព្រះរាជក្រឹត្យលេខ ០៧៨ នស/រកត/០២១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីរាជការសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ និងអតីតយុទ្ធជន។

### ៣.១.៣. របបហានិភ័យការងារ

សន្តិសុខសង្គមផ្នែកនិភ័យការងារ គឺជារបបធានារ៉ាប់រងចំពោះសមាជិក ប.ស.ស ដែលជួបគ្រោះថ្នាក់ការងារ ។ គ្រោះថ្នាក់ការងារ សំដៅដល់គ្រោះថ្នាក់ដែលរួមមាន គ្រោះថ្នាក់ពេលធ្វើការ គ្រោះថ្នាក់ពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ។[24]

#### ៣.១.៣.១. គ្រោះថ្នាក់ពេលធ្វើការ

ត្រូវចាត់ទុកជាហានិភ័យការងារ សំដៅដល់គ្រោះថ្នាក់កើតឡើងដោយចៃដន្យ និងភ្លាមៗក្នុងពេលធ្វើការងារ ដោយធ្វើការងារ ឬនៅកន្លែងធ្វើការងារដោយមូលហេតុទាក់ទង នឹងកំហុសជនរងគ្រោះ ឬគ្មានកំហុសក៏ដោយដែលបណ្តាលឱ្យជនរងគ្រោះទទួលរងរបួសស្នាមជាយថាហេតុ។[25]

#### ៣.១.៣.២. គ្រោះថ្នាក់ពេលធ្វើដំណើរ

ត្រូវចាត់ទុកជាហានិភ័យការងារ សំដៅទៅដល់គ្រោះថ្នាក់កើតឡើងពេលធ្វើដំណើរនៅលើកំណាត់ផ្លូវត្រង់រវាងលំនៅឋាន និងកន្លែងធ្វើការងារក្នុងចិរវេលាសមស្រប។ អធិការសន្តិសុខសង្គz

---

22 ប្រកាសអន្តរក្រសួងស្តីពី ការអនុវត្តថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន, លេខ ៤០៤ ក.ប/ប្រ.ក.ប.ស.ស,១១ តុលា ២០១៧, ប្រការ ៥ ។

23 ប្រកាសដដែល,ប្រការ ៦ ។

24 ច្បាប់ស្តីពីការងារ, លេខ០១ ជស/រកម/០៣៩៧, ១៣ មីនា ១៩៩៧, មាត្រា ២៤៨។

25 ច្បាប់ស្តីរបបសន្តិសុខសង្គម (ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមនិយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម), លេខ ០១៨ នស/រកម/១១១៩, ០២ វិច្ឆិកា ២០១៩, ទំព័រ ២។

មានឆន្ទានុសិទ្ធិក្នុងការចាត់ទុកគ្រោះថ្នាក់ពេលធ្វើដំណើរជាហានិភ័យការងារ ដោយផ្អែកលើហេតុផលជាក់ស្តែងដែលទទួលបានពីការអង្កេតលើករណីគ្រោះថ្នាក់នីមួយៗ។[26]

#### ៣.១.៣.៣. ជំងឺវិជ្ជាជីវៈ

ត្រូវចាត់ទុកជាហានិភ័យការងារ សំដៅដល់សភាពនៃរោគសមុដ្ឋាន ឬការកើតរោគដែល ពាក់ព័ន្ធ នឹងការអនុវត្តការងារក្នុងមុខរបរណាមួយជាកំណត់ ពោល គឺរោគ ឬជំងឺដែលមានទំនាក់ទំនងផ្ទាល់ជាមួយនឹងកត្តានានានៃការងារមានជាអាទិ៍ កំលុងពេលធ្វើការងារ កន្លែងធ្វើការងារ របៀបធ្វើការងារ សារធាតុ ឬវត្ថុធាតុប្រើប្រាស់ក្នុងផលិតកម្ម បរិយាកាសនៃកន្លែងធ្វើការជាដើម ដែលអាចធ្វើឱ្យកើតរោគ ឬជំងឺ ទោះបីក្នុងកំលុងពេលធ្វើដែលសាមីជនកំពុងបំពេញការងារ ឬមុខរបរ ឬក្រោយកំលុងពេលដែលលែងបំពេញការងារ ឬមុខរបរបទាំងនោះក្តី។ ជំងឺទូទៅទោះបីកើតនៅកន្លែងធ្វើការក៏ដោយ ក៏មិនត្រូវបានចាត់ទុកជាហានិភ័យការងារទេ។[27]

## ៣.២. នីតិវិធីនៃការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងសមាជិក

### ៣.២.១ ការចុះបញ្ជិកាសហគ្រាស

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដែលនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន របស់ខ្លួននៅក្នុងបេឡាជាតិរបបសន្តិសុខសង្គម។ ការចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន និយោជក ឬអ្នកតំណាងអាចទៅចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន របស់ខ្លួននៅស្នាក់ការកណ្តាល ប.ស.ស (រាជធានីភ្នំពេញ) ឬតាមសាខាខេត្ត/ខណ្ឌ។ សហគ្រាស គ្រឹះស្ថាន ដែលកំពុងដំណើរការ និងមិនទាន់បានចុះបញ្ជិកានៅ ប.ស.ស ត្រូវមានកាតព្វកិច្ចចុះបញ្ជិការយៈពេលយ៉ាងយូរ ៣០ ថ្ងៃ។ ចំណែកសហគ្រាស គ្រឹះស្ថានដែលបើកដំណើរការថ្មីត្រូវមានកាតព្វកិច្ចមកចុះបញ្ជិកានៅ ប.ស.ស យ៉ាងយូរ ៣០ ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមបើកសហគ្រាស គ្រឹះស្ថាន។[28]

- ទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ឬហៅថាទម្រង់ "១.០១"
- វិញ្ញាបនបត្របញ្ជិកាពាណិជ្ជកម្មដែលចេញដោយក្រសួងពាណិជ្ជកម្ម
- ប័ណ្ណប៉ាតង់
- លិខិតតួបករណ៍គតិយុត្តសមមូល

---

[26] ច្បាប់ស្តីរបបសន្តិសុខសង្គម (ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរបបsសន្តិសុខសង្គមនិយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម), លេខ ០១៨ នស/រកម/១១១៩, ០២ វិច្ឆិកា ២០១៩, ទំព័រ ៣។

[27] ច្បាប់ស្តីរបបសន្តិសុខសង្គម (ឧបសម្ព័ន្ធនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមនិយមន័យនៃវាក្យសព្ទដែលប្រើនៅក្នុងច្បាប់ស្តីពីរបបសន្តិសុខសង្គម), លេខ នស/រកម/១១១៩/០១៨, ០២ វិច្ឆិកា ២០១៩, ទំព័រ ៣ និងទំព័រ៤។

[28] ប្រកាសស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ,លេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស, ១០ វិច្ឆិកា ២០១៧, ប្រការ ៥។

- របាយការណ៍ស្តីពីចំនួនកម្មករនិយោជិត
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់និយោជក និងអ្នកតំណាង[29]
- ប្លង់ទីតាំងសហគ្រាស គ្រឹះស្ថាន ។

### ៣.២.២. ការចុះបញ្ជិការសមាជិក

#### ៣.២.២.១. ការចុះបញ្ជិការកម្មករនិយោជិកក្នុងប្រព័ន្ធ

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចចុះបញ្ជិកាកម្មករនិយោជិតរបស់ខ្លួនមកក្នុង ប.ស.ស. យ៉ាងយូរយៈពេល ៣ (បី) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទអនុញ្ញាតឱ្យចូលធ្វើការ[30] ។ការចុះបញ្ជិកាកម្មករនិយោជិតនេះនិយោជកអាចចុះបញ្ជិកាតាមរយៈ Offline Registration និងតាមរយៈ Online Registration។ ការចុះបញ្ជិកាតាមរយៈ Offline Registration គឺ ប.ស.ស. បានចាត់ចែងក្រុមការងាររបស់ខ្លួន ចុះទៅធ្វើប័ណ្ណ ប.ស.ស ជូនពួកគាត់ដល់សហគ្រាស តាមរយៈការស្នើសុំរបស់និយោជកដើម្បីជួយសម្រួលដល់សង្វាក់ផលិតកម្មរបស់សហគ្រាស។ ចំណែកឯការចុះបញ្ជិកាតាមរយៈ Online Registration គឺនិយោជកត្រូវបញ្ជូនកម្មករនិយោជិតរបស់ខ្លួនមកធ្វើប័ណ្ណប.ស.ស នៅស្នាក់ការកណ្តាលប.ស.ស (រាជធានីភ្នំពេញ) ឬសាខាខេត្ត/ខណ្ឌ។ ម៉្យាងទៀតចំពោះកម្មករនិយោជិតដែលធ្លាប់បានធ្វើប័ណ្ណ ប.ស.ស រួចហើយ ដោយមិនចាំបាច់មកចុះបញ្ជិកាម្តងទៀតនោះទេ គឺពួកគាត់គ្រាន់តែយកប័ណ្ណប្រគល់ឱ្យខាងរដ្ឋបាល សហគ្រាស គ្រឹះស្ថាន ដែលខ្លួនចូលបម្រើការងារដើម្បីឱ្យរដ្ឋបាលបញ្ចូលលេខអត្តសញ្ញាណ១៥ខ្ទង់ របស់កម្មករនិយោជិតចូលទៅក្នុងប្រព័ន្ធអេឡិចត្រូនិច ឬហៅថា (ទម្រង់ E-form) ដើម្បីបង់ភាគទានមក ប.ស.ស។

❖ **បែបបទ នឹងនីតិវិធីនៃការចុះបញ្ជិកាកម្មករនិយោជិតនៅ ប.ស.ស រួមមាន៖**

- ទម្រង់សលាប័ត្រព័ត៌មានកម្មករនិយោជិត ឬហៅថាទម្រង់ "១.០២"
- បំពេញសលាប័ត្រព័ត៌មានកម្មករនិយោជិត
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ
- លិខិតឆ្លងដែនសម្រាប់តែកម្មករនិយោជិតបរទេស
- បន្ទាប់មកកម្មករនិយោជិតត្រូវយកសំណុះឯកសារទៅជួបមន្ត្រី ឬបុគ្គលិកចុះបញ្ជិកា
- មន្ត្រី ឬបុគ្គលិក ចុះបញ្ជិកាពិនិត្យមើលលើសំណុំឯកសាររួចហើយ វាយបញ្ចូលទន្និន័យរបស់កម្មករនិយោជិតចូលទៅក្នុងប្រព័ន្ធចុះបញ្ជិកា ដើម្បីផ្តល់លេខអត្តសញ្ញាណ ១៥ ខ្ទង់ ដែលជាលេខសម្គាល់របស់កម្មករនិយោជិតម្នាក់ៗ បន្ទាប់មកមានការស្កេនម្រាមមេដៃ នឹងថតរូប។

---

[29] ប្រកាសស្តីពីបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងរបបឡជាតិរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ,លេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស, ១០ វិច្ឆិកា ២០១៧, ប្រការ ៦។

[30] ប្រកាសដដែល, ប្រការ ៧។

ក្នុងករណីប័ណ្ណសមាជិក ប.ស.ស ខូចឬបាត់ ម្ចាស់ប័ណ្ណត្រូវមកស្នើសុំចេញប័ណ្ណថ្មី (ទុតិយតា) នៅស្នាក់ការ ប.ស.ស ឬសាខាខេត្ត/ខណ្ឌ។ ម្យ៉ាងទៀតប្រសិនបើកម្មករនិយោជិតបានធ្លាប់ខ្ញុំឯកសារគ្នា (សំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណ) និង ប.ស.ស បានចេញប័ណ្ណខុសឈ្មោះ ឬអក្សរឡាតាំង និងលេខអត្តសញ្ញាណប័ណ្ណ គឺកម្មករនិយោជិតត្រូវមកប្តូរប័ណ្ណ ប.ស.ស នៅស្នាក់ការកណ្តាល ឬតាមសាខាខេត្ត/ខណ្ឌ ឱ្យបានត្រឹមត្រូវតាមឯកសារដើមរបស់ខ្លួន ដើម្បីកុំឱ្យបាត់បង់អត្ថប្រយោជន៍ដែលខ្លួនត្រូវទទួលបានពី ប.ស.ស ស្របតាមច្បាប់ជាធរមាន។

### ៣.២.២.២. ការចុះបញ្ជិការមន្រ្តីរាជការ និងអតីតមន្ត្រីរាជការនិងអតីតយុទ្ធជន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវមានកាតព្វកិច្ចចុះបញ្ជិកាកម្មករនិយោជិតរបស់ខ្លួនមកក្នុង ប.ស.ស យ៉ាងយូររយៈពេល ៣ (បី) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទអនុញ្ញាតឱ្យចូលធ្វើការ។[31] ការចុះបញ្ជិកាកម្មករនិយោជិតនេះនិយោជកអាចចុះបញ្ជិកាតាមរយៈ Offline Registration និងតាមរយៈ Online Registration ។ ការចុះបញ្ជិកាតាមរយៈ Offline Registration គឺ ប.ស.ស បានចាត់ចែងក្រុមការងាររបស់ខ្លួន ចុះទៅធ្វើប័ណ្ណ ប.ស.ស ជូនពួកគាត់ដល់សហគ្រាស តាមរយៈការស្នើសុំរបស់និយោជកដើម្បីជួយសម្រួលដល់សង្វាក់ផលិតកម្មរបស់សហគ្រាស។ ចំណែកឯការចុះបញ្ជិកាតាមរយៈ Online Registration គឺនិយោជកត្រូវបញ្ជូនកម្មករនិយោជិតរបស់ខ្លួនមកធ្វើប័ណ្ណប.ស.ស នៅស្នាក់ការកណ្តាលប.ស.ស (រាជធានីភ្នំពេញ) ឬសាខាខេត្ត/ខណ្ឌ។ ម្យ៉ាងទៀតចំពោះកម្មករនិយោជិតដែលធ្លាប់បានធ្វើប័ណ្ណ ប.ស.ស រួចហើយ ដោយមិនចាំបាច់មកចុះបញ្ជិកាម្តងទៀតនោះទេ គឺពួកគាត់គ្រាន់តែយកប័ណ្ណប្រគល់ឱ្យខាងរដ្ឋបាល សហគ្រាស គ្រឹះស្ថាន ដែលខ្លួនចូលបម្រើការងារដើម្បីឱ្យរដ្ឋបាលបញ្ចូលលេខអត្តសញ្ញាណ១៥ខ្ទង់ របស់កម្មករនិយោជិតចូលទៅក្នុងប្រព័ន្ធអេឡិចត្រូនិច ឬហៅថា (ទម្រង់ E-form) ដើម្បីបង់ភាគទានមក ប.ស.ស។

### ៣.២.២.៣. ផ្តល់វិញ្ញាបនប័ត្រជូនសហគ្រាសគ្រឹះស្ថាន

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្តល់លេខអត្តសញ្ញាណសម្រាប់ សហគ្រាស គ្រឹះស្ថាននីមួយៗបន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ។ សហគ្រាស គ្រឹះស្ថានមួយ ត្រូវទទួលបានលេខអត្តសញ្ញាណតែមួយគត់ ដែលឱ្យឈ្មោះថា "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន"។ ប.ស.ស. ត្រូវផ្តល់ "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនទៅសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការួច ហើយវិញ្ញាបនបត្រនេះចាំបាច់ត្រូវមានចុះលេខ "អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" និងកាលបរិច្ឆេទចុះបញ្ជិកា។ និយោជកត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថានរបស់ខ្លួន។[32]

---

[31] ប្រកាសដដែល, ប្រការ ៧។

[32] ប្រកាសស្តីពី បញ្ជិកាសហគ្រា គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ,លេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស, ១០ វិច្ឆិកា ២០១៧, ប្រការ ៩។

#### ៣.២.២.៤. ការផ្ដល់បណ្ណជូនសមាជិក

បេឡាជាតិរបបសន្តិសុខសង្គម ត្រូវផ្ដល់លេខអត្តសញ្ញាណសម្រាប់ សហគ្រាស គ្រឹះស្ថាននីមួយៗបន្ទាប់ពីទទួលបានទម្រង់ "បញ្ជិកាសហគ្រាស គ្រឹះស្ថាន" ។ សហគ្រាស គ្រឹះស្ថានមួយ ត្រូវទទួលបានលេខអត្តសញ្ញាណតែមួយគត់ដែលឱ្យឈ្មោះថា "វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន"។ ប.ស.ស. ត្រូវផ្ដល់"វិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន" ជូនទៅសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិការួច ហើយវិញ្ញាបនបត្រនេះចាំបាច់ត្រូវមានចុះលេខ "អត្តសញ្ញាណសហគ្រាស គ្រឹះស្ថាន" និងកាលបរិច្ឆេទចុះបញ្ជិកា។ និយោជកត្រូវដាក់តាំងវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន នៅនឹងការិយាល័យបើកប្រាក់ឈ្នួលរបស់សហគ្រាស គ្រឹះស្ថានរបស់ខ្លួន។[33]

## ៣.៣. នីតិវិធីនៃការបង់ភាគទានសម្រាប់សមាជិក

### ៣.៣.១. អត្រាភាគទានសម្រាប់សមាជិកវិស័យឯកជន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជិកា សហគ្រាស គ្រឹះស្ថានរបស់ខ្លួន ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពមកក្នុងបេឡាជាតិរបបសន្តិសុខសង្គមរួចហើយត្រូវមានកាព្វកិច្ចបង់ភាគទានផ្នែកសន្តិសុខសង្គមទាំងពីរនេះ តាមការជូនដំណឹងរបស់បេឡាជាតិរបបសន្តិសុខសង្គម។ អត្រាភាគទានដែលនិយោជកត្រូវមានកាតព្វកិច្ចបង់ គឺ ផ្នែកហានិភ័យការងារស្មើនឹង ០,៨ ភាគរយ នៃប្រាក់ឈ្នួលមធ្យមក្នុងលំដាប់ថ្នាក់នៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតមុនកាត់ពន្ធ និងភាគទានផ្នែកថែទាំសុខភាពស្មើនឹង ២,៦ ភាគរយ នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទាននៃប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតមុនកាត់ពន្ធ។[34]

### ៣.៣.២. អត្រាភាគទានសម្រាប់សមាជិកវិស័យសាធារណៈ

ភាគទាននៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ ជាបន្ទុករួមគ្នារវាងរដ្ឋ និងសាមីជន។ អត្រាភាគទាននេះ ត្រូវកំណត់ស្មើនឹង ១(មួយ) ភាគរយនៃប្រាក់បៀវត្សមូលដ្ឋាន ឬប្រាក់កម្រៃប្រចាំខែរបស់មន្ត្រីសាធារណៈដែលក្នុងនោះ ៖

- ០,៥០ (សូន្យក្បៀសហាសិប) ភាគរយ ជាបន្ទុករបស់រដ្ឋ
- ០,៥០ (សូន្យក្បៀសហាសិប) ភាគរយ ជាបន្ទុករបស់សាមីជន[35]។

[33]ប្រកាសស្ដីពី បញ្ជិកាសហគ្រា គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ,លេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស, ១០ វិច្ឆិកា ២០១៧, ប្រការ ៩។

[34]ប្រកាសស្ដីពីការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់ ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព,លេខ ៤៤៩ ក.ប/ប្រ.ក ប.ស.ស,១០ វិច្ឆិកា ២០១៧, ប្រការ ៤ កថាខណ្ឌ ១,២។

[35] អនុក្រឹត្យស្ដីពីការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន, លេខ ៥៩ អនក្រ.បក, ០៨ ឧសភា ២០១៨, មាត្រា៥ ។

ចំណែកឯភាគទានសម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ជាបន្ទុករបស់សាមីជន។អត្រាភាគទាននេះ ត្រូវកំណត់ស្មើនឹង០,៥០ (សូន្យក្បៀសហាសិប) ភាគរយ នៃប្រាក់សោធនរបស់សាមីជន ដោយមិនរាប់បញ្ចូលប្រាក់បន្ទាប់បន្សំ ឬប្រាក់ឧបត្ថម្ភផ្សេងៗ។[36]

### ៣.៣.៣. ការអនុវត្តរបបសន្តិសុខសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវចាប់ផ្តើមបង់ភាគទានដំបូងត្រូវកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបានចុះបញ្ជិកាសហគ្រាស គ្រឹះស្ថាន ដែល ប.ស.ស បានចេញវិញ្ញាបនបត្របញ្ជិកាសហគ្រាស គ្រឹះស្ថាន។ ការប្រគល់វិញ្ញាបនបត្រនេះត្រូវមានបញ្ជាក់កាលបរិច្ឆេទដែលសហគ្រាស គ្រឹះស្ថានបានទទួលពី ប.ស.ស។ ការចាប់ផ្តើមបង់ភាគទានដំបូងសម្រាប់ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពចំពោះសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិការួចហើយ នោះ ប.ស.ស នឹងកំណត់ថ្ងៃខែ ដែលនិយោជកត្រូវបង់ភាគទានមកកាន់ ប.ស.ស ។ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវបង់ភាគទានផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពក្នុងពេលដំណាល់គ្នាសម្រាប់ខែនីមួយៗយ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ នៃខែបន្ទាប់[37]។ ចំពោះមន្ត្រីរាជការសាធារណៈក្រសួងមុខងារសាធារណៈត្រូវផ្តល់ទិន្នន័យមន្ត្រីរាជការសាធារណៈ និងទំហំថវិកាភាគទានតាមក្រសួងស្ថាប័នមក ប.ស.ស ជារៀងរាល់ខែ រីឯក្រសួង ស្ថាប័ន ឬអង្គភាព ដែលគ្រប់គ្រងផ្ទាល់លើមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនត្រូវផ្តល់ទិន្នន័យមន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន និងទំហំថវិកាភាគទានដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងមុខងារសាធារណៈមក ប.ស.ស ជារៀងរាល់ខែ។[38]

### ៣.៣.៤. បែបបទនៃការបង់ភាគទាន

និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន អាចបង់ភាគទានផ្ទាល់ចូលទៅក្នុងគណនីរបស់បេឡាជាតិរបបសន្តិសុខសង្គមដែលរួមមាន ធនាគារអេស៊ីលីដា ធនាគារកាណាឌីយ៉ា ក.អ ធនាគារឯកទេសរីង ធនាគារវឌ្ឍនៈអាស៊ីចំកាត់ (ABA BANK) និងក្រុមហ៊ុន លីហ្សរ ផេ ប្រ៉ូ ភីអិលស៊ី (លីហ្សរ ផេ លុយ)។ ប៉ុន្តែប្រសិនបើនិយោជកបង់តាមរយៈសេវាកម្មអ៊ីនធឺណែតប៊ែងឃីង ឬសេវាកម្មយូនីធី ការចំណាយលើសេវាកម្មនេះ គឺជាបន្ទុករបស់និយោជក។ បន្ទាប់មកនិយោជក ឬម្ចាស់សហគ្រាស

[36] អនុក្រឹត្យដដែល,មាត្រា ៥។

[37]ប្រកាសស្តីពីការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព,លេខ ៤៤៩ ក.ប/ប្រ.ក ប.ស.ស,១០ វិច្ឆិកា ២០១៧,ប្រការ ៥។

[38]អនុក្រឹត្យស្តីពីការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន, លេខ ៥៩ អនក្រ.បក, ០៨ ឧសភា ២០១៨, មាត្រា៧ ។,

គ្រឹះស្ថានត្រូវយកឯកសារដែលបានបង់ភាគទានបញ្ជូនដោយផ្ទាល់មក ប.ស.ស ឬសាខាប.ស.ស ខេត្ត/ខណ្ឌ ឬតាមរយៈសារអេឡិចត្រូនិច។

❖ **ឯកសារភ្ជាប់មក ប.ស.ស រួមមាន ៖**

- បញ្ជិកាកម្មករនិយោជិត (E-form)
- តារាងបើកបៀវត្ស (Payroll list)
- លិខិតប្រកាសបង់ភាគទាន
- លិខិតបញ្ជាក់ពីនិយោជក (Form B)
- បង្កាន់ដៃបង់ប្រាក់ពីធនាគារ (Bank slip) ។

បន្ទាប់មក ប.ស.ស ធ្វើការត្រួតពិនិត្យឃើញថាត្រឹមត្រូវហើយ មន្ត្រី ឬបុគ្គលិក ប.ស.ស នឹងចេញលិខិតបញ្ជាក់ការបង់ភាគទានជូនទៅនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានវិញ។[39]

### ៣.៣.៥. បែបបទនៃការប្រកាសរបាយការណ៍កម្មករនិយោជិត

រៀងរាល់ខែ និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់របាយការណ៍អំពីចំនួនកម្មករនិយោជិតទៅបេឡាជាតិរបបសន្តិសុខសង្គមយ៉ាងយូរបំផុតត្រឹមថ្ងៃទី ២០ នៃខែបន្ទាប់។ របាយការណ៍អំពីចំនួនកម្មករនិយោជិត ត្រូវបញ្ជាក់អំពីចំនួនកម្មករនិយោជិតទាំងអស់ដែលមាននៅក្នុងខែត្រូវរាយការណ៍។ របាយការណ៍អំពីចំនួនកម្មករនិយោជិតដែលត្រូវផ្តល់ជូនបេឡាជាតិរបបសន្តិសុខសង្គមអាចធ្វើតាម "ទម្រង់ក្រដាស" ឬ "ទម្រង់អេឡិចត្រូនិច" ដោយមានភ្ជាប់លិខិតបញ្ជូនចុះហត្ថលេខាដោយនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន។[40]

### ៣.៣.៦. ទោស និងការពិន័យចំពោះការយឺតយ៉ាវ

និយោជក ឬម្ចាសសហគ្រាស គ្រឹះស្ថាន ដែលខកខានមិនបានបង់ភាគទានតាមកាលបរិច្ឆេទដែលបានកំណត់ ឬមិនអនុវត្តកាតព្វកិច្ចរាយការណ៍ពីកម្មករនិយោជិតឱ្យបានត្រឹមត្រូវនោះ និយោជកត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ពី ១០ (ដប់) ដង ទៅ ៣០ (សាមសិប) ដង នៃប្រាក់ឈ្នួលយោងប្រចាំខែ។ ការពិន័យនេះត្រូវអនុវត្តស្មើនឹងចំនួនមនុស្ស ដែលនិយោជកបានប្រើប្រាស់ក្នុងលក្ខខណ្ឌផ្ទុយពីបទប្បញ្ញត្តិនៃច្បាប់។[41]

[39] ប្រកាសស្តីពីការកំណត់អត្រាភាគទានបែបបទ និងនីតិវិធីនៃការបង់ភាគទានសម្រាប់ផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាព,លេខ ៤៤៩ ក.ប/ប្រ.ក ប.ស.ស,១០ វិច្ឆិកា ២០១៧,ប្រការ ៧។

[40] ប្រកាសស្តីពី បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ,លេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស, ១០ វិច្ឆិកា ២០១៧, ប្រការ ១១។

[41] ច្បាប់ស្តីពីរបបសន្តិសុខសង្គម, លេខ ០១៨ នស/រកម/១១១៩, ០២ វិច្ឆិកា ២០១៩, មាត្រា ៩៨ ។

## ៣.៤. មូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជនដែលបានចុះកិច្ចព្រមព្រៀង

### ៣.៤.១.កាតព្វកិច្ចមូលដ្ឋានសុខាភិបាល

មូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវមានកាតព្វកិច្ចចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដោយអនុវត្តតាមទម្រង់កិច្ចព្រមព្រៀងដូចចែងក្នុង ឧបសម្ព័ន្ធ១ សម្រាប់មណ្ឌលសុខភាព ឧបសម្ព័ន្ធ២ សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត១ កម្រិត២ និងកម្រិត៣ និងឧបសម្ព័ន្ធ៣ សម្រាប់មន្ទីរពេទ្យជាតិ ហើយឧបសម្ព័ន្ធទាំងអស់នេះមានកំណត់ក្នុងប្រកាសអន្តរក្រសួងលេខ២៩១ ក.ប/ប្រក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៦ ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព។ ចំណែកមូលដ្ឋានសុខាភិបាលឯកជនអាចចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស បានលុះត្រាតែមានអាជ្ញាប័ណ្ណទទួលស្គាល់ដោយក្រសួងសុខាភិបាល និងត្រូវឆ្លងកាត់ការវាយតម្លៃលើកម្រិតសេវា និងគុណភាពសេវាពី ប.ស.ស។.[42]

### ៣.៤.២. មូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀង

ការចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលនេះ បេឡាជាតិរបបសន្តិសុខសង្គមបានបែងចែកជាពីរថ្នាក់ គឺថ្នាក់កណ្តាល និងថ្នាក់ខេត្ត ។ មូលដ្ឋានសុខាភិបាលថ្នាក់កណ្តាលដែលបានចុះកិច្ចព្រមព្រៀងផ្នែកហានិភ័យការងាររួមមាន មន្ទីរពេទ្យថ្នាក់ជាតិចំនួន ៥, មន្ទីរពេទ្យបង្អែកចំនួន ៦, មណ្ឌលសុខភាពចំនួន ១៣ និងមូលដ្ឋានសុខាភិបាលឯកជនចំនួន ៣១ រីឯថ្នាក់ខេត្តមាន មន្ទីរពេទ្យបង្អែក ចំនួន ៨៦ ,មណ្ឌលសុខភាពចំនួន ៨៥ និងមូលដ្ឋានសុខាភិបាលឯកជនចំនួន ៥០[43]។ ចំណែកមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ផ្នែកថែទាំសុខភាព ថ្នាក់កណ្តាលរួមមាន ថ្នាក់ជាតិចំនួន ៥ , មន្ទីរពេទ្យបង្អែកចំនួន ៨, មណ្ឌលសុខភាពចំនួន ៤២ និងមន្ទីរសុខាភិបាលឯកជនចំនួន ៤៩ រីឯថ្នាក់ខេត្តមានមន្ទីរពេទ្យបង្អែកចំនួន ១០៧ ,មណ្ឌលសុខភាពចំនួន ១,១៤៧ និងមូលដ្ឋានសុខាភិបាលឯកជនចំនួន ៨៤ ។ សរុបមូលដ្ឋានសុខាភិបាលដែលបានចុះព្រមព្រៀងជាមួយ ប.ស.ស ផ្នែកហានិភ័យការងារចំនួន ២៣៣ និងផ្នែកថែទាំសុខភាពចំនួន ១៣៩៣[44]។

## ៣.៥. បែបបទនៃការប្រើប្រាស់ និងទទួលបានតាវលិក

តាវកាលិកផ្នែកហានិភ័យការងារ ជាអត្ថប្រយោជន៍ដែល ប.ស.ស ធ្វើការផ្តល់ជូនដល់សមាជិករបស់ខ្លួននៅពេលជួបប្រទះ ជរាភាព ទុព្វលភាព មរណភាព និងហានិភ័យការងារ ដោយពួកគាត់នឹង

[42] ប្រកាសអន្តរក្រសួង ស្តីពីកិច្ចព្រមព្រៀងការប្រើប្រាស់ និងការផ្តល់សេវាសុខាភិបាលរវាងបេឡាជាតិរបបសន្តិសុខសង្គម និងមូលដ្ឋានសុខាភិបាលសម្រាប់ផ្នែកថែទាំសុខភាព,លេខ ២៩១ ក.ប/ប្រ.ក,២៥ កក្កដា ២០១៦,ប្រការ៣ ចំណុច ៣.១ និងចំណុច ៣.២។

[43] អ៊ុក សមវិទ្យា, *របាយការណ៍ស្តីពី លទ្ធផលការងារសម្រេចបាន ឆ្នាំ ២០១៩ និងទិសដៅអនុវត្តបន្តរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)*, គ្មានលេខ ( ភ្នំពេញ ៖ បេឡាជាតិរបបសន្តិសុខសង្គម, ០៦ មករា ២០២០), ៧ ។

[44]អ៊ុក សមវិទ្យា, *របាយការណ៍ស្តីពី លទ្ធផលការងារសម្រេចបាន ឆ្នាំ ២០១៩ និងទិសដៅអនុវត្តបន្តរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)*,គ្មានលេខ ( ភ្នំពេញ ៖ បេឡាជាតិរបបសន្តិសុខសង្គម, ០៦ មករា ២០២០), ១២។

ទទួលបានការធានារ៉ាប់រងពី ប.ស.ស តាមច្បាប់ជាធរមាន។ កម្មករនិយោជិតក្នុងប្រព័ន្ធ សំដៅដល់ជនគ្រប់ប្រភេទ និងគ្រប់សញ្ជាតិដែលបានចុះកិច្ចសន្យាយកកំរៃជាសាធារណៈ ឬឯកជន។ ហើយលក្ខណៈសម្បត្តិនៃកម្មករនិយោជិតមិនត្រូវគិតពីលក្ខន្តិកៈគតិយុត្តនៃនិយោជក ឬលក្ខន្តិកៈនៃកម្មករនិយោជិតព្រមទាំងមិនត្រូវគិតពីប្រាក់ឈ្នួលតិច ឬច្រើន។[45] ចំណែកសមាជិក ប.ស.ស ដែលជាមន្ត្រីរាជការ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ព្រមទាំងកម្មករនិយោជិតក្រៅប្រព័ន្ធ ពុំទាន់ទទួលបានរបបនេះនៅឡើយ ដោយសារតែ ប.ស.ស អនុវត្តជាជំហានៗ និងតាមផែនការយុទ្ធសាស្ត្រ។

របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព គឺជារបបធានារ៉ាប់រងសង្គម ជំហានបន្ទាប់របស់បេឡាជាតិរបបសន្តិសុខសង្គម បន្ទាប់ពីទទួលបានជោគជ័យលើការអនុវត្តជំហានទីមួយផ្នែកហានិភ័យការងារ។ តាវកាលិកផ្នែកថែទាំសុខភាព គឺជាអត្ថប្រយោជន៍ដែល ប.ស.ស ផ្តល់ជូនដល់សមាជិករបស់ខ្លួន ដូចជា សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ឬគ្រោះថ្នាក់ផ្សេងៗក្រៅពីហានិភ័យការងារ និងសម្រាកលំហែមាតុភាព ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗទៀត។

### ៣.៥.១. របបសោធន៍និវត្តន៍

ក្នុងអនុវត្តន៍ និងដាក់ដំណើរការរបបសន្តិសុខសង្គមផ្នែកសោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារតាមរយៈយន្តការ លក្ខខណ្ឌបែបបទនៃនីតិវិធីនៃការចុះបញ្ជី ការបង់ភាគទាន អត្រាភាគទាន អត្រាសមាច័យ ការទាមទារ និងការផ្តល់តាវលិក។[46]

របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលត្រូវបាន បង្កើតឡើងនៅពាក់កណ្តាលទសវត្ស ១៩៥០។ របបទាំងនេះត្រូវបានបាត់បង់ទាំងស្រុងក្នុងសម័យ ប៉ុល ពត។ មកដល់ដើមទសវត្ស ១៩៨០ របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំឡើងវិញ ក្រោមការឧបត្ថម្ភធនទាំងស្រុងពីរដ្ឋ។ ក្រោយមកការបង់បញ្ចប់សង្គ្រាមអនុក្រឹត្យត្រូវបានដំណើរការឡើងវិញដើម្បីសម្រួលដល់ការរបើប្រាក់សោធន ចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ ជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈដែលទទួលបានមុខតំណែងជាអ្នកនយោបាយ និងអ្នកនៅក្នុងបន្ទុក។[47]

---

[45] ប្រកាសស្តីពី បញ្ជិកាសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតក្នុងបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) សម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ,លេខ ៤៤៨ ក.ប/ប្រ.ក.ប.ស.ស, ១០ វិច្ឆិកា ២០១៧, ប្រការ ៤ ចំណុច ៣។

[46] អនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកសោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ,លេខ៣២អនក្រ.កប ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ជំពូកទី១ មាត្រា១

[47] អនុក្រឹត្យកែសម្រួលការអនុវត្តបើកប្រាក់សោធនចំពោះមន្ត្រីរាជការដែលជានិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈជនបាត់បង់សមត្ថភាពការងារ ជនពិការ និងគ្រួសារជនពលី គ្រួសារជនមរណៈ ដែលទទួលមុខតំណែងជាអ្នកនយោបាយ លេខ៤២ អនក្រ.កប,ចុះថ្ងៃទី២៥ ខែកញ្ញាឆ្នាំ ២០០៨ ប្រការ១។

### ៣.៥.១.១. លក្ខខណ្ឌទទួលបានតាវលិកសោធន៍និវត្តន៍

លក្ខខណ្ឌទទួលបានគឺតម្រូវឱ្យនិយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលប្រើប្រាស់កម្មករនយោជិតចាប់ពី១(មួយ)នាក់ ឡើងត្រូវមានកាតព្វកិច្ចចុះបញ្ជីក្នុង ប.ស.ស. ផ្នែកប្រាក់សោធនក្នុងរយៈពេលយ៉ាងយូរ៣០(សាមសិប)ថ្ងៃបន្ទាប់ពីអនុក្រឹត្យអនុក្រឹត្យជាធរមាន លើកលែងតែសហគ្រាស គ្រឹះស្ថានដែលបានចុះបញ្ជីក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងហានិភ័យរួចហើយ។ ទម្រង់និងបែបបទ នៃការចុះបញ្ជិការសហគ្រាស គ្រឹះស្ថាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។[48]

#### ៣.៥.១.១.១. លក្ខខណ្ឌទទួលបានតាវលិកសោធន៍ជរាភាព

របបនេះត្រូវបានផ្តល់ដល់សមាជិកបាន លុះត្រាតែជាសមាជិកបានចុះបញ្ជិការផ្នែកសោធនហើយបានភាគទានយ៉ាងតិច ១២ខែហើយអាយុយ៉ាងតិច ៦០(ហុកសិប)ឆ្នាំ ទើបអាចទទួលបានសោធជរាភាព ដែលអាចទទួលបានប្រាក់សោធនប្រចាំខែ និងរបបថែប្រចាំខែ នឹងរបបថែទាំសុខភាពព្រមទាំងទទួលបានវិភាជន៍បូជាសព និងសោធនឧត្តរជីវី។

#### ៣.៥.១.១.៣. លក្ខខណ្ឌទទួលបានតាវលិកសោធន៍ទុព្វលភាព

របបនេះត្រូវបានផ្តល់ដល់សមាជិក ប.ស.ស. ដែលបានចុះបញ្ជីការក្នុងផ្នែកសោធន ដែលបង់ទានយ៉ាងតិច ៦០ខែ ដែលកំណត់អាយុគិតពីថ្ងៃទទួលទុព្វលភាព ដែលទទួលសោធនទុព្វលភាពដោយរបបនេះត្រូវបានផ្តល់ជាប្រចាំខែនិងរបបថែទាំសុខភាព និងអ្នកថែទាំ(តាមការវាយតម្លៃរបស់ក្រុមប្រឹក្សាវិជ្ជាសាស្ត្រ ព្រមទាំងបានវិភាជន៍បូជាសពដោយដោយទទួលសោធនឧត្តរជីវី។[49]

#### ៣.៥.១.១.៥. លក្ខខណ្ឌទទួលបានតាវលិកសោធន៍តាមរបបស្ម័គ្រចិត្ត

របបត្រូវបានផ្តល់ដល់សមាជិក ប.ស.ស. ដែលបានបំពេញលក្ខខណ្ឌណាមួយដូចខាងក្រោមមានសិទ្ធិស្នើសុំមក ប.ស.ស. ដើម្បីចូលរួមក្នុងផ្នែកសោធនតាមរបបភាគទាននេះមានដូចខាងក្រោម៖

១. បាត់បង់ការងារដែលមានប្រាក់ឈ្នួលមុនអាយុ៦០(ហុកសិប)ឆ្នាំ និងមានលទ្ធភាពបង់ភាគទានបន្ត។ ២. មានអាយុ៦០(ហុកសិប)ឆ្នាំ និងមានបំណងបង់ភាគទានបន្តដើម្បីទទួលបានសោធនជរាភាពខ្ពស់ជាងសោធនជរាភាពជាក់ស្តែង ដែលសាមីជាត្រូវបានទទួលបានតាមរបបភាគទានជាកាតព្វកិច្ច។ ៣.មានប្រាក់ចំណូលខ្ពស់ជាងប្រាក់ឈ្នួលពិតាន ដែលសាមីជនជាប់កាតព្វកិច្ចក្នុងរបបភាគទានជាកាតព្វកិច្ច។ ប្រាក់ឈ្នួលពិដានត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក។[50]

---

48 អនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកសោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ,លេខ៣២អនក្រ.កប ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ជំពូកទី៣ មាត្រា៥

49 អនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកសោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ,លេខ៣២អនក្រ.កប ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ជំពូកទី៣ មាត្រា

50 អនុក្រឹត្យស្តីពីរបបសន្តិសុខសង្គមផ្នែកសោធនសម្រាប់បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ,លេខ៣២អនក្រ.កប ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ជំពូកទី៦ មាត្រា១៨

### ៣.៥.១.១.៦. លក្ខខណ្ឌទទួលបានតាវលិកសោធន៍អយ្យកប្បញ្ញត្តិ

របបនេះត្រូវបានផ្តល់ជូនសមាជិកលុះត្រាតែ ជាសមាជិកបានចុះបញ្ជិការផ្នែកសោធន ដែលអាយុលើស៣០(សាមសិប)ឆ្នាំ ដែលបានបង់វិភាគទានបានយ៉ាងតិច២៤ខែក្នុងរយៈពេល៣៦ខែ ដោយគិតចាប់ពីកាលបរិច្ឆេទដំណើរការផ្នែកប្រាក់សោធន

៣.៥.២.របបថៃទាំសុខភាព

### ៣.៥.២.១.លក្ខខណ្ឌទទួលបានតាវលិកនិងការប្រើប្រាស់របបថៃទាំសុខភាព

ក្នុងការប្រើប្រាស់សេវាផ្នែកថៃទាំសុខភាពសមាជិក ប.ស.ស ត្រូវទៅប្រើប្រាស់សេវាបាននៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ឬឯកជនដែលបានចុះកិច្ចព្រមព្រមព្រៀងជាមួយ ប.ស.ស និងមានលើកផ្លាកឡូហ្គោ ប.ស.ស. ជាសម្គាល់។ ក្នុងករណីជួយសង្គ្រោះជីវិតជនរងគ្រោះបន្ទាន់សមាជិក ប.ស.ស. អាចទៅប្រើប្រាស់សេវានៅមន្ទីរពេទ្យដែលនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះមិនមានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ជនរងគ្រោះ ឬ អ្នកតំណាងត្រូវជូនដំណឹងជាបន្ទាន់មក ប.ស.ស. ។[51]

### ៣.៣.១.២.១. លក្ខខណ្ឌក្នុងការប្រើប្រាស់សេវា

កម្មករនិយោជិតកំពុងបម្រើការងារក្នុងសហគ្រាសដែលបានចុះបញ្ជិកាជាមួយ ប.ស.ស ផ្នែកថៃទាំសុខភាព និងមានប័ណ្ណសមាជិក ប.ស.ស ទោះបីជានិយោជកមិនទាន់បង់ភាគទានសម្រាប់ខែដំបូងក៏ដោយ (ត្រូវមានលិខិតបញ្ជាក់ពីសហគ្រាស គ្រឹះស្ថាន មកជាមួយ)។

និយោជិកបានបង់ភាគទាន ០៦ ខែ ក្នុងអំឡុង ១២ ខែចុងក្រោយ គិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព ឬមាតុភាព។និយោជិកបានបង់ភាគទាន ០២ (ពីរ) ខែ ជាប់គ្នា ប៉ុន្តែអស់កាតព្វកិច្ចបង់ភាគទាន សមាជិក ប.ស.ស មានសិទ្ធិទទួលសេវាព្យាបាល និងថៃទាំវេជ្ជសាស្ត្ររយៈពេល ២ (ពីរ) ខែ គិតពីកាលបរិច្ឆេទនៃការអស់កាតព្វកិច្ចបង់ភាគទាន។[52]

- **សមាជិក ប.ស.ស ត្រូវមានឯកសារភ្ជាប់ដូចជា៖**

- ប័ណ្ណសមាជិក ប.ស.ស
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ
- ប័ណ្ណបម្រើការងារក្នុងសហគ្រាស គ្រឹះស្ថាន[53]។

[51] ប្រកាសស្តីពីតាវកាលិកថៃទាំសុខភាព,លេខ ១០៩ ក.ប/ប្រ.ក, ១៧ មីនា ២០១៦, ប្រការ ១០ ថ្មី។

[52] ប្រកាសស្តីពី ការកែសម្រួល ប្រការ ២ ប្រការ ៤ ប្រការ ៥ ប្រការ ៦ ប្រការ ៧ និងប្រការ ១០ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីតាវកាលិកថៃទាំសុខភាព, លេខ ១៨៤ ក.ប/ប្រ.ក ប.ស.ស, ២៥ មេសា ២០១៨, ប្រការ ៦ ថ្មី ចំណុច ៦.១។

[53] ប្រកាសស្តី ពីតាវកាលិកថៃទាំសុខភាព,លេខ១០៩ ក.ប/ប្រ.ក, ១៧ មីនា ២០១៦, ប្រការ ៩ ។

នៅក្នុងមូលដ្ឋានសុខាភិបាលមួយចំនួន ប.ស.ស បានដាក់ភ្នាក់ងារប្រចាំការនៅក្នុងមន្ទីរពេទ្យ ដើម្បីជួយសម្រួលដល់សមាជិកដែលចូលទៅប្រើប្រាស់សេវា។ សមាជិក ប.ស.ស នៅពេលទៅប្រើប្រាស់សេវាចាំបាច់ត្រូវទៅជួបភ្នាក់ងារ ប.ស.ស ជាមុនសិន (ប្រសិនបើមាន) ដើម្បីធ្វើការកំណត់អត្តសញ្ញាណសមាជិកភាពមុននឹងទៅទទួលបានសេវាក្នុងមន្ទីរពេទ្យ។

### ៣.៣.១.២.២. មូលដ្ឋានសុខាភិបាលដែលភ្នាក់ងារ ប.ស.ស.ប្រចាំការ

ក្នុងមូលដ្ឋានសុខាភិបាលដែលមានដាក់ភ្នាក់ងារ ប.ស.ស ប្រចាំការក្នុងមន្ទីរពេទ្យ ភ្នាក់ងារត្រូវមានកាតព្វកិច្ចដូចជា ៖

- ស្នើសុំអត្តសញ្ញាណសម្គាល់ខ្លួនសមាជិក ប.ស.ស និងធ្វើការកំណត់សិទ្ធិនៃការប្រើប្រាស់សេវាសុខភាព ។
- ករណីមានសិទ្ធិ ភ្នាក់ងារ ប.ស.ស ត្រូវសួរនាំពីបញ្ហាសុខភាពរបស់សមាជិក។
- ធ្វើការបោះពុម្ពទម្រង់លិខិតប្រើប្រាស់សេវាសុខាភិបាលផ្នែកថែទាំសុខភាព។
- ពន្យល់ណែនាំដល់សមាជិករាល់ឯកសារវេជ្ជសាស្ត្រ ដែលទទួលបានពីគ្រូពេទ្យព្យាបាល ហើយតម្រូវត្រូវយកទៅដាក់ច្បាប់នៅកន្លែងធ្វើការជាចាំបាច់ នឹងត្រូវយកឯកសារទាំងនោះមកបោះត្រា ប.ស.ស នៅកន្លែងភ្នាក់ងារ ប.ស.ស។
- រក្សាប័ណ្ណសម្គាល់ខ្លួនសមាជិកទុកនៅកន្លែង ក្នុងករណីអ្នកជំងឺសម្រាកពេទ្យ និងផ្តល់ជូនទៅវិញពេលដែលអ្នកជំងឺចេញពីមន្ទីរពេទ្យ។
- ក្នុងករណីមានបញ្ហាណាមួយកើតឡើងទាក់ទង នឹងការផ្តល់សេវារបស់មន្ទីរពេទ្យចំពោះសមាជិក ភ្នាក់ងារត្រូវមានកាតព្វកិច្ចសម្របសម្រួលដោះស្រាយបញ្ហា ដែលកើតឡើងជូនសមាជិកឱ្យបានទាន់ពេលវេលា។

### ៣.៣.១.២.៣.មូលដ្ឋានសុខាភិបាលដែលគ្មានភ្នាក់ ប.ស.ស. ការប្រចាំការបូករួមទាំងមន្ទីរពេទ្យឯកជន

ក្នុងករណីសមាជិកទៅប្រើប្រាស់សេវានៅក្នុងមន្ទីរពេទ្យដែលគ្មានភ្នាក់ងារប.ស.ស. សមាជិកត្រូវទៅជួបបុគ្គលិកក្នុងមន្ទីរពេទ្យ ដើម្បីឱ្យបុគ្គលិកធ្វើការកំណត់អត្តសញ្ញាណសមាជិកភាពមុននឹងទៅទទួលសេវាក្នុងមន្ទីរពេទ្យ។

❖ **កាតព្វកិច្ចបុគ្គលិកក្នុងមន្ទីរពេទ្យរួមមាន ៖**

- ស្នើសុំអត្តសញ្ញាណសម្គាល់ខ្លួនសមាជិក ប.ស.ស និងធ្វើការកំណត់សិទ្ធិនៃការប្រើប្រាស់សេវាសុខភាព ។

- ករណីមានសិទ្ធិ បុគ្គលិកមន្ទីរពេទ្យត្រូវរៀបចំបំពេញឯកសារសមាជិកឱ្យទៅបញ្ជរបង់ប្រាក់ និងណែនាំសមាជិកឱ្យទៅទទួលបានសេវាព្យាបាលក្នុងមន្ទីរពេទ្យ។
- ធ្វើការបោះពុម្ពទម្រង់លិខិតប្រើប្រាស់សេវាសុខាភិបាលផ្នែកថែទាំសុខភាព។

ពន្យល់ណែនាំដល់សមាជិករាល់ឯកសារវេជ្ជសាស្ត្រ ដែលទទួលបានពីគ្រូពេទ្យព្យាបាល ហើយតម្រូវត្រូវយកទៅដាក់ច្បាប់នៅកន្លែងធ្វើការជាចាំបាច់ នឹង ត្រូវយកឯកសារទាំងនោះមកបោះត្រា ប.ស.ស.។

### ៣.៥.២.៣. កំណត់ប្រភេទសេវាសម្រាប់សមាជិកក្នុងវិស័យឯកជន

#### ៣.៥.២.៣.១. ការផ្តល់កញ្ចប់សម្រាប់សមាជិក ប.ស.ស.

ការប្រើប្រាស់សេវាផ្នែកថែទាំសុខភាពនៅមូលដ្ឋានសុខាភិបាលដែលជាដៃគូរ ប.ស.ស បានផ្តល់សេវាជាកញ្ចប់តាវកាលិកដល់សមាជិករបស់ខ្លួន។ សេវាជាកញ្ចប់តាវកាលិករួមមានតាវកាលិកសុខភាព នឹងសេវាបង្ការសុខភាព។ កញ្ចប់តាវលិកសុខភាពរួមមាន សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ និងសេវាបញ្ជូនសព និងប្រាក់បំណាច់ប្រចាំថ្ងៃ ។ ចំណែកសេវាបង្ការសុខភាពដែលផ្តល់ដោយ ប.ស.ស កម្មវិធីជាតិ អង្គភាព ឬស្ថាប័ន និងអង្គការទាក់ទងទៅនឹងបញ្ហាសុខភាពដទៃទៀត។[54]

#### ៣.៥.២.៣.២. សេវាដែលមិនរាប់បញ្ចូលក្នុងសេវាវេជ្ជសាស្ត្រ

សេវាដែល ប.ស.ស មិនរាប់បញ្ចូលក្នុងសេវាព្យាបាលវេជ្ជសាស្ត្ររួមមាន៖

- ការព្យាបាលដោយមិនគិតថ្លៃ ដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ
- ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)
- ការព្យាបាល និងការវះកាត់ប្តូរភេទ
- សេវាបង្កកំណើតដោយសិប្បនិម្មិត
- ការព្យាបាលដោយខ្លួនឯង
- ការព្យាបាល ឬការវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាងកាយ
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ
- ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន
- ការព្យាបាលអសមត្ថភាពផ្តល់កំណើត
- ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត

[54] ប្រកាសស្តីពីតាវកាលិកថែទាំសុខភាព,លេខ ១០៩ ក.ប/ប្រ.ក,១៧ មីនា ២០១៦,ប្រការ ៣។

- ការវះកាត់បេះដូង និងសសៃឈាមបេះដូង
- ការលាងឈាម
- ការពិនិត្យសុខភាពទូទៅ។

ក្នុងករណីសង្គ្រោះបន្ទាន់សេវាដូចមានកំណត់ខាងលើត្រូវបានផ្តល់ជូន[55]។ ចំណែកសេវាដែលមិនរាប់បញ្ចូលក្នុងសេវាព្យាបាលវេជ្ជសាស្ត្រសម្រាប់សមាជិក ប.ស.ស ជាមន្ត្រីសាធារណៈដូចគ្នាជាមួយកម្មករនិយោជិតក្នុងប្រព័ន្ធដែរ ដោយយោងតាមមាត្រា ១៧នៃអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ។

### ៣.៥.២.៣.៣. ការកំណត់ប្រភេទជំងឺរ៉ាំរ៉ៃ

ប្រភេទជំងឺរ៉ាំរ៉ៃ ដែលត្រូវកំណត់ដោយបេឡាជាតិរបបសន្តិសុខសង្គមរួមមាន៖

- ជំងឺខ្សោយបេះដូង (Cardiac Failure)
- ជំងឺសាច់ដុំបេះដូង (Cardiomyopathy)
- ជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ (Chronic Hepatitis B)
- ជំងឺរលាកថ្លើមប្រភេទសេរ៉ាំរ៉ៃ (Chronic Hepatitis C)
- ជំងឺតំរងនោមរ៉ាំរ៉ៃ (Chronic renal disease)
- ជំងឺក្រិនថ្លើម (Cirrhosis of the liver)
- ជំងឺសរសៃឈាមក្រហមបេះដូង (Coronary Artery Disease)
- ជំងឺទឹកនោមផ្អែមប្រភេទទី១ និងទី២ (Diabetes Mellitus Type 1 & 2)
- ជំងឺវិបត្តិចង្វាក់បេះដូង (Dysrhythmias)
- ជំងឺក្រិនសរីរាង្គ (Multiple Sclerosis)
- ជំងឺវិកលចរិត (Schizophrenia)
- ជំងឺលុយពុស (Systemic Lupus Erythematosus)
- ជំងឺលើសឈាម (Hypertension)

[55] ប្រកាសស្តីពីការកែសម្រួលប្រការ ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព,លេខ ១៨៤ ក.ប/ប្រ.ក.ប.ស.ស, ២៥ មេសា ២០១៨, ប្រការ ៤ ថ្មី។

- ជំងឺតាឡាសសឹមី (Thalassemia) [56]។

ការផ្តល់សេវាចំពោះជំងឺរ៉ាំរ៉ៃ ត្រូវធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ នឹងត្រូវប្រើប្រាស់ឱសថសារវន្តតែប៉ុណ្ណោះ។ ចំពោះឱសថព្យាបាលក្រៅពីបញ្ជីឱសថសារវន្ត ជាបន្ទុកចំណាយផ្ទាល់របស់អ្នកជំងឺ លើកលែងតែឱសថព្យាបាលទឹកនោមផ្អែម និងជំងឺលើសសម្ពាធឈាមមិនមាននៅក្នុងបញ្ជីឱសថសារវន្ត និងការព្យាបាលជំងឺមហារីកដោយសារធាតុគីមី ត្រូវទូទាត់តាមសេវាព្យាបាលនីមួយៗ[57]។ ចំពោះការកំណត់ជំងឺរ៉ាំរ៉ៃសម្រាប់មន្ត្រីរាជសាធារណៈដូចគ្នាជាមួយនឹងកម្មករនិយោជិតក្នុងប្រព័ន្ធដែរ (ដោយយោងតាមមាត្រា១៨ នៃអនុក្រឹត្យលេខ ១៣៤ អនក្រ.បកស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន)។

### ៣.៥.២.៣.៤. សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ

❖ **ការព្យាបាលដោយសម្រាកនៅក្នុងមន្ទីរពេទ្យ**

- សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- ឧបករណ៍ផ្នែកសល្យសាស្ត្រ និងសម្ភារបរិក្ខារផ្នែកវេជ្ជសាស្ត្រដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា
- បន្ទប់ (ធម្មតា) និងអាហារដែលផ្តល់ដោយមូលដ្ឋានសុខាភិបាល។

❖ **សេវាពិគ្រោះជំងឺក្រៅ**

- សេវាព្យាបាលថែទាំតាមបច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ
- សេវាធ្វើរោគវិនិច្ឆ័យ សេវាមន្ទីរពិសោធន៍ រូបភាពវេជ្ជសាស្ត្រ និងសេវាពិនិត្យវេជ្ជសាស្ត្រផ្សេងទៀត
- បរិក្ខារសល្យសាស្ត្រ និងវេជ្ជសាស្ត្រផ្សេងៗដែលជាតម្រូវការចាំបាច់សម្រាប់ការព្យាបាល
- ឱសថតាមវេជ្ជបញ្ជា។

❖ **សេវាសង្គ្រោះបន្ទាន់**

[56] ប្រកាសស្តីពីការកំណត់បញ្ជីជំងឺរ៉ាំរ៉ៃនៅក្នុងរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព,លេខ ២៣៨ ក.ប/ប្រ.ក, ២១ មិថុនា ២០១៦, ប្រការ២។

[57] ប្រកាសស្តីពីការកែសម្រួលប្រការ ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព,លេខ ១៨៤ ក.ប/ប្រ.ក.ប.ស.ស, ២៥ មេសា ២០១៨, ប្រការ ៥ ថ្មី។

សេវាសង្គ្រោះបន្ទាន់ គឺជាអន្តរាគមន៍ទាំងឡាយណា ដែលធ្វើឡើងក្នុងកាលៈទេសៈមួយដែលមិនបានគ្រោងទុក ហើយអន្តរាគមន៍ទាំងនោះអាចត្រូវធ្វើឡើងភ្លាមក្នុងគោលបំណងជួយសង្គ្រោះជីវិត ឬជួយការពារបាត់បង់អវៈយវៈណាមួយនៃសេរីរាង្គរបស់អ្នកជំងឺ ឬជនរងគ្រោះ។ ក្នុងករណីសង្គ្រោះបន្ទាន់អ្នកជំងឺអាចទៅព្យាបាលនៅមូលដ្ឋានសុខាភិបាលដែលនៅជិតបំផុត។ ប្រសិនបើមូលដ្ឋានសុខាភិបាលនោះមិនមានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ជនរងគ្រោះ ឬអ្នកតំណាងត្រូវជូនដំណឹងបន្ទាន់ដល់ ប.ស.ស ក្នុងអំឡុងពេលយ៉ាងយូរ ៤៨ ម៉ោង តាមរយៈលេខទូរស័ព្ទបន្ទាន់ ១២៨៦[58]។

- ❖ **សេវាព្យាបាលដោយស្ពំ និងចលនា ។**
- ❖ **សេវាសម្រាលកូន និងសេវាព្យាបាលថែទាំមុន និងក្រោយពេលសម្រាល។**
- ❖ **សេវាស្តារនីតិសម្បទា**

សេវាស្តារនីតិសម្បទា គឺជាសេវាព្យាបាលថែទាំវេជ្ជសាស្ត្រសម្រាប់របបថែទាំសុខភាពក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬធ្វើឱ្យប្រសើរឡើងវិញនូវសមត្ថភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទងដែលបានបាត់បង់ ឬខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។

### ៣.៥.២.៣.៥. សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ និងសេវាបញ្ជូនសព

សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ ប.ស.ស ផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬតាមមធ្យោបាយផ្សេងទៀតដែលទទួលស្គាល់ដោយ ប.ស.ស ។ ចំណែកសេវាបញ្ជូនសព ឬបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជា អាចធ្វើតាមមធ្យោបាយបញ្ជូនរបស់មូលដ្ឋានសុខាភិបាល ឬប្រភេទមធ្យោយបាយជាក់ស្តែងផ្សេងទៀត។[59]

### ៣.៥.២.៣.៦. សេវាបង្ការសុខភាព

សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះ ប.ស.ស ផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬតាមមធ្យោបាយផ្សេងទៀតដែលទទួលស្គាល់ដោយ ប.ស.ស ។ ចំណែកសេវាបញ្ជូនសព ឬបញ្ជូនអ្នកជំងឺធ្ងន់ធ្ងរព្យាបាលមិនជា អាចធ្វើតាមមធ្យោបាយបញ្ជូនរបស់មូលដ្ឋានសុខាភិបាល ឬប្រភេទមធ្យោយបាយជាក់ស្តែងផ្សេងទៀត[60]។

---

[58] ប្រកាសស្តីពីតាវកាលិកថែទាំសុខភាព,លេខ ១០៩ ក.ប/ប្រ.ក,១៧ មីនា ២០១៦,ប្រការ ៩ ចំណុច ៩.២។

[59] ប្រកាសស្តីពីការកែសម្រួលប្រការ ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព,លេខ ១៨៤ ក.ប/ប្រ.ក.ប.ស.ស,២៥ មេសា ២០១៨, ប្រការ ៧ ថ្មី។

[60] ប្រកាសស្តីពីការកែសម្រួលប្រការ ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព,លេខ ១៨៤ ក.ប/ប្រ.ក.ប.ស.ស,២៥ មេសា ២០១៨, ប្រការ ៧ ថ្មី។

### ៣.៥.២.៣.៧.តាវកាលិកថែទាំសុខភាពសម្រាប់មន្ត្រីរាជសាធារណៈ

សម្រាប់មន្ត្រីរាជការសាធារណៈសេវាដែលប.ស.ស. ធ្វើការផ្តល់ជូនរួមមានដូចជាសេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនអ្នកជំងឺឬជនរងគ្រោះនិងសេវាបញ្ជូនសព សេវាបង្ការសុភាព និងសេវាស្តារនីតិសម្បទា ដែលសេវាទាំងនេះមិនខុសគ្នាជាមួយកម្មករនិយោជិតក្នុងប្រព័ន្ធឡើយ។[61]

### ៣.៥.២.៣.៨. សេវាស្តារនីតិសម្បទា

សមាជិក ប.ស.ស ដែលទទួលរងគ្រោះថ្នាក់ ឬជំងឺ ក្រៅពីហានិភ័យការងារ ត្រូវទទួលបានតែសេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រប៉ុណ្ណោះ ។ សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រត្រូវបានផ្តល់ជូនសម្រាប់គាំទ្រទាំងដល់ការព្យាបាល និងថែទាំវេជ្ជសាស្ត្រ ឬបន្ទាប់ពីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ ហើយទទួលរងពិការភាព។[62]

### ៣.៥.២.៣.៩. ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់សមាជិកក្នុងវិស័យឯកជន

សមាជិក ប.ស.ស ដែលបានសម្រាកព្យាបាលជំងឺ ឬមុខរបួសនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ឬឯកជនដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ហើយបានអាក់ខានការងារដោយសារសម្រាកព្យាបាលនេះតាមវេជ្ជបញ្ជាមានរយៈពេលជាប់គ្នាលើសពី ០៧ (ប្រាំពីរ) ថ្ងៃ ដោយរាប់ចាប់ពីថ្ងៃទី ០១ ដែលសមាជិក ប.ស.ស បានចូលទៅមូលដ្ឋានសុខាភិបាល នោះគាត់នឹងទទួលប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% (ចិតសិបភាគរយ) នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំ ថ្ងៃរបស់គាត់ពីបេឡាជាតិរបបសន្តិសុខសង្គម។ ការផ្តល់ប្រាក់បំណាចនេះផ្តល់ជូនមិនលើសពី ១៨០ (មួយរយប៉ែតសិប) ថ្ងៃក្នុងរយៈពេល ១២ (ដប់ពីរ)ខែ ចុងក្រោយដោយមិនរាប់បញ្ចូលរយៈពេលសម្រាកមាតុភាព ៩០(កៅសិប) ថ្ងៃ។[63] ចំណែកបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈត្រូវបានរក្សាបានប្រាក់បៀវត្សដដែល ក្នុងរយៈពេលព្យាបាលថែទាំសុខភាពមុន និងក្រោយពេលសម្រាល ដូចមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន[64]។

### ៣.៥.២.៣.១០.ប្រាក់បំណាច់ពេលសម្រាប់មាតុភាពក្នុងវិស័យឯកជន

សមាជិក ប.ស.ស ដែលបានសម្រាលកូននៅតាមមូលដ្ឋានសុខាភិបាលជាដៃគូ ប.ស.ស នឹងបានបង់ភាគទានបាន ០៩ ខែ ក្នុងអំឡុងពេល ១២ ខែ ចុងក្រោយគិតរហូតទល់ខែដែលបានសម្រាលកូន នោះគាត់នឹងទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% (ចិតសិបភាគរយ) នៃប្រាក់ឈ្នួល

---

[61] អនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីរាជសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ,លេខ ១៣៤ អនក្រ.បក, ២៣ សីហា ២០១៧, មាត្រា ១៣,១៤, ១៥,១៦។

[62] ប្រកាសស្តីពីសេវាស្តារនីតិសម្បទាសម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, លេខ ៤៧៧ ក.ប/ប្រ.ក.ប.ស.ស, ១៦ តុលា ២០១៨,ប្រការ ៨។

[63] ប្រកាសស្តីពីការកែសម្រួលប្រការ ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព,លេខ ១៨៤ ក.ប/ប្រ.ក.ប.ស.ស, ២៥ មេសា ២០១៨, ប្រការ ៧ ថ្មី ចំណុច ៧.១។

[64] ច្បាប់ស្តីពីរបបសន្តិសុខសង្គម, លេខ ០១៨ នស/រកម/១១១៩, ០២ វិច្ឆិកា ២០១៩, មាត្រា ៥៩ ។

មធ្យមជាប់ភាគទានប្រចាំថ្ងៃរបស់គាត់សម្រាប់រយៈពេល ៩០ (កៅសិប) ថ្ងៃនៃការឈប់សម្រាកមុន និងក្រោយសម្រាលកូនពីបេឡាជាតិរបបសន្តិសុខសង្គម[65]។ ផ្ទុយមកវិញប្រសិនបើសមាជិក ប.ស.ស ទៅសម្រាលកូននៅមូលដ្ឋានសុខាភិបាលមិនមែនដៃគូរ អាចទាមទារប្រាក់ ៧០% ពី ប.ស.ស បាន លុះត្រាតែគាត់ត្រូវទៅពិនិត្យសុខភាពក្រោយពេលសម្រាលនៅមូលដ្ឋានសុខាភិបាលជាដៃគូរ។ ចំណែកបុគ្គលិកនៃវិស័យសាធារណៈជាស្ត្រីមានសិទ្ធិទទួលបានប្រាក់បៀវត្សពេញក្នុងរយៈពេល សម្រាកមាតុភាព ឬក្នុងរយៈពេលព្យាបាលថែទាំសុខភាពមុន និងក្រោយពេលសម្រាលដូចមានកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន។[66]

### ៣.៥.២.៣.១១. ប្រាក់ឧបត្ថម្ភរាជរដ្ឋាភិបាលក្នុងវិស័យឯកជន

កម្មនិយោជិតជាស្ត្រីទាំងអស់ ទាំងក្នុង និងក្រៅប្រព័ន្ធ ដែលសម្រាលកូននៅមូលដ្ឋានសុខាភិបាល សាធារណៈ ត្រូវទទួលបានប្រាក់ឧបត្ថម្ភដូចជា ៖

- សម្រាលកូនទោល (មួយ) ទទួលបាន ៤០០,០០០ (បួនសែន) រៀល។
- សម្រាលកូនភ្លោះ (ពីរ) ទទួលបាន ៨០០,០០០ (ប្រាំបីសែន) រៀល។
- សម្រាលកូនភ្លោះ (បី) ទទួលបាន ១,២០០,០០០ (មួយលានពីរសែន) រៀល។

ប្រាក់ឧបត្ថម្ភនេះ ត្រូវផ្តល់ជូនដោយផ្ទាល់ពី ប.ស.ស ក្រោយពេលសម្រាលកូនទោះបីទារករស់ ឬស្លាប់ក៏ដោយ[67]។

- **លក្ខខណ្ឌនៃការជូនដំណឹងជាមុនសម្រាប់ទទួលប្រាក់ឧបត្ថម្ភពេលសម្រាលកូន**

- សមាជិក ប.ស.ស ជាស្ត្រី ឬសាច់សញ្ញាតិរបស់ខ្លួន ក្នុងអំឡុងពេលយ៉ាងយូរ៣ (បី) ខែ មុនសម្រាលកូនត្រូវអញ្ជើញមកយកទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភ របស់រាជរដ្ឋាភិបាលពេល សម្រាលកូននៅស្នាក់ការ ប.ស.ស ក្នុងរាជធានី ខេត្ត/ខណ្ឌ។
- ក្រោយពេលសម្រាលកូនរួច សាមីខ្លួន ឬសាច់ញាតិរបស់ខ្លួន ត្រូវយកទម្រង់ស្នើសុំប្រាក់ឧបត្ថម្ភ បន្ថែមរបស់រាជរដ្ឋាភិបាលពេលសម្រាលកូនដែលមានហត្ថលេខា និងឈ្មោះរបស់គ្រូពេទ្យ បញ្ជាក់ថា សាមីខ្លួនពិតជាសម្រាលកូនពិតប្រាកដយកមកដាក់នៅទីស្នាក់ការប.ស.សក្នុងរាជ ធានី ខេត្ត/ខណ្ឌ។

សុពលភាពទទួលបានប្រាក់ឧបត្ថម្ភបន្ថែម របស់រាជរដ្ឋាភិបាលនេះមានរយៈពេល ១ ខែ បន្ទាប់ពីថ្ងៃសម្រាលកូនរួច។ ប្រាក់ឧបត្ថម្ភនេះ ប.ស.ស.នឹងផ្តល់ជូនតាមរយៈធនាគារអេស៊ីលីដា ភិ អិល ស៊ី

[65]ប្រកាសស្តីពីការកែសម្រួលប្រការ ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព,លេខ ១៨៤ ក.ប/ប្រ.ក.ប.ស.ស, ២៥ មេសា ២០១៨ការ ៧ ថ្មី ចំណុច ៧.១។

[66] ច្បាប់ស្តីពីរបបសន្តិសុខសង្គម, លេខ ០១៨ នស/រកម/១១១៩, ០២ វិច្ឆិកា ២០១៩, មាត្រា៥០ ។

[67]ប្រកាសអន្តរក្រសួងស្តីពី ការអនុវត្តថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាលសម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ និងការផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិតជាស្ត្រីនៅពេលសម្រាលកូន, លេខ ៤០៤ ក.ប/ប្រ.ក.ប.ស.ស,១១ តុលា ២០១៧, ប្រការ ៨។

តាមគណនីវីង និងគណនីលីហ្សូរវេលុយ ដែលភ្ជាប់ជាមួយលេខទូរស័ព្ទរបស់សាមីខ្លួនឱ្យបានច្បាស់លាស់។[68]

### ៣.៥.២.៤. យន្តការទូទាត់ថ្លៃថែទាំសុខភាព

ក្នុងការទូទាត់ថ្លៃសេវាព្យាបាលថែទាំវេជ្ជសាស្ត្រ ប.ស.ស បានកំណត់វិធីសាស្ត្រទូទាត់តាមប្រភេទករណី នឹងបានកំណត់យកប្រភេទករណីសរុបចំនួន ៥២ ដែលត្រូវបានបែងចែកចេញជា ៥ កម្រិតនៃសេវានេះ គឺកម្រិត MPA កម្រិត CPA1 កម្រិត CPA2 កម្រិត CPA3 និងកម្រិត NH ទៅតាមវិសាលភាព និងគុណភាពសេវារបស់មូលដ្ឋានសុខាភិបាល ។ ក្នុងការទូទាត់ថ្លៃសេវាតាមប្រភេទករណីនេះមានកំណត់ក្នុងប្រការអន្តរក្រសួងលេខ ៣២៧ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី ១៧ សីហា ២០១៧ ស្តីពីការសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ១៧៣ ក.ប/ប្រ.ក ចុះថ្ងៃទី 0៥ ឧសភា ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកទាំសុខភាព។

- **ប្រភេទកម្រិតមន្ទីរពេទ្យរួមមាន ៖**
  - MPA សម្រាប់មណ្ឌលសុខភាព។
  - CPA1 សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត ១។
  - CPA2 សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត ២។
  - CPA3 សម្រាប់មន្ទីរពេទ្យបង្អែកកម្រិត ៣។
  - NH មន្ទីរពេទ្យជាតិ ។

មូលដ្ឋានសុខាភិបាលមួយអាចទទួលកិច្ចព្រមព្រៀងសេវាកម្រិតចម្រុះបាន។ ឧទាហរណ៍៖

| ល.រ | កូដ | ប្រភេទករណី | តំលៃទូទាត់ គិតជារៀល(ប្រកាសលេខ ៣២៧) |
|---|---|---|---|
| **មណ្ឌលសុខភាព(MPA)** | | | |
| ១ | CON0 | ករណីពិគ្រោះជំងឺក្រៅ | ៦,000៛ |
| ២ | REF0 | ករណីសង្គ្រោះបន្ទាន់ និងបញ្ជូន | ២0,000៛ |
| ៣ | MIN0 | ករណីវះកាត់តូច | ១២,000៛ |
| ៤ | PRE0 | ករណីសេវាបង្ការ និងពន្យាកំណើតរយៈពេលខ្លី | ១0,000 ៛ |
| ៥ | BSL0 | ករណីពន្យាកំណើតរយៈពេលវែង | ៣0,000៛ |
| ៦ | DEL0 | ករណីសំរាលកូន | ៨0,000៛ |

[68] សេចក្តីជូនដំណឹងស្តីពី កែសម្រួលនីតិវិធីនៃការជូនដំណឹងជាមុនសម្រាប់ទទួលប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាល ជូនកម្មករនិយោជិតជាស្ត្រីក្នុង និងក្រៅប្រព័ន្ធពេលសម្រាលកូន,លេខ ០១៩/២០ ប.ស.ស, ២៩ មេសា ២០២០។

មណ្ឌលសុខភាព (កម្រិត MPA) មានសេវាព្យាបាល ៦ ករណី ដូចបានកំណត់ខាងលើតែមានមណ្ឌលសុខភាពខ្លះអាចមានសេវាព្យាបាលលើសពីកម្រិតមណ្ឌលសុខភាព លើសករណីវលូត ឬរំលូតកូន មួយករណី ហេតុដូច្នេះសេវាដែលលើសអាចចាត់ថ្នាក់ជាកម្រិត CPA1 ហើយទូទាត់តាមតម្លៃ CPA1។ ចំណែកសេវាដែលបានកំណត់នៅក្នុងមណ្ឌលសុខភាពជាកម្រិត MPA នៅតែទូទាត់តាមតម្លៃកម្រិត MPA ដដែរ[69] ។

### ៣.៥.២.៤.១. ការទូទាត់តាមប្រភេទករណី

វិធីសាស្ត្រទូទាត់តាមប្រភេទសេវាត្រូវអនុវត្តចំពោះប្រភេទករណីដូចមានក្នុងឧសម្ព័ន្ធ ប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.កចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព,លេខ ៣២៧ ក.ប/ប្រ.ក ប.ស.ស, ១៧ សីហា ២០១៧។ ហើយដែលត្រូវការសេវាពិសេសបន្ថែម ឬសេវាព្យាបាលនិងថែទាំបន្ត និងករណីពិសេសផ្សេងទៀតដែលគ្មាននៅឧបសម្ព័ន្ធ (ប្រកាសលេខ៣២៧) ។

❖ **ប្រភេទករណីដែលត្រូវការសេវាពិសេសបន្ថែម ឬសេវាព្យាបាល និងថែទាំបន្ត**

– ការលាងឈាម
– MRI (Magnetic Resonance Imaging)
– CT SCAN
– ការព្យាបាលដោយកាំរស្មីអ៊ិច
– ការវិភាគរកកោសិកាមហារីក
– MATERIEL SOTEOSYNTHESE
– បន្ទប់ម៉ាស៊ីនត្រជាក់
– សេវាបញ្ជូនអ្នកជំងឺ ឬជនរងគ្រោះសម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព
– ការបញ្ជូនសព
– សេវាស្តារនីតិសម្បទា។

❖ **ករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧសម្ព័ន្ធ (ប្រកាសលេខ៣២៧)**

– ការចោះ ឬដាប់ឆ្អឹងលលាដ៏ក្បាល
– ការវះកាត់បេះដូង និងសរសៃឈាម
– ការព្យាបាលសង្គ្រោះបន្ទាន់ជំងឺបេះដូង។

ប.ស.ស នឹងធ្វើការទូទាត់តាមប្រភេទសេវាសម្រាប់ករណីសេវាពិសេសបន្ថែមឬសេវាព្យាបាល និងថែទាំបន្តនេះ មូលដ្ឋានសុខាភិបាលនឹងទទួលការទូទាត់តាមប្រភេទសេវាសម្រាប់ថ្លៃ សេវាពិសេស

[69] ប្រកាសអន្តរក្រសួងស្តីពីការកែសម្រួលឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងលេខ ១៧៣ ក.ប/ប្រ.កចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៦ស្តីពីយន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព,លេខ ៣២៧ ក.ប/ប្រ.ក ប.ស.ស, ១៧ សីហា ២០១៧។

បន្ថែម ឬសេវាព្យាបាល និងថែទាំបន្តទៅតាមហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬតាមការព្រមព្រៀង។ ការទូទាត់នេះមិនរាប់បញ្ចូលការទូទាត់តាមករណី ដែលបានកំណត់ ក្នុងឧបសម្ព័ន្ធ(ប្រកាសលេខ៣២៧)ទេ ចំណែកករណីពិសេសផ្សេងទៀតដែលគ្មាននៅក្នុងឧសម្ព័ន្ធ (ប្រកាសលេខ៣២៧) មូលដ្ឋានសុខាភិបាលនឹងទទួលបានការទូទាត់សេវាតាមប្រភេទហិរញ្ញប្បទានផ្លូវការរបស់មូលដ្ឋានសុខាភិបាល ឬទៅតាមការព្រមព្រៀង[70]។

#### ៣.៥.២.៤.២.ការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការសាធារណៈ

ការផ្តល់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវធ្វើតាមយន្តការទូទាត់ថ្លៃសេវាដូចគ្នានឹងយន្តការទូទាត់ថ្លៃសេវាសម្រាប់ជនទាំងឡាយ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារលើកលែងតែការព្យាបាលជំងឺមហារីកដោយសារធាតុគីមី និងឱសថសារវន្តដែលត្រូវទូទាត់ថ្លៃសេវាព្យាបាលនីមួយៗ។[71]

## ៣.៥.៣. របបហានិភ័យការងារ

### ៣.៥.១. សេវាកម្មផ្នែកហានិភ័យការងារ

ការផ្តល់សេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ត្រូវធ្វើតាមយន្តការទូទាត់ថ្លៃសេវាដូចគ្នានឹងយន្តការទូទាត់ថ្លៃសេវាសម្រាប់ជនទាំងឡាយ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារលើកលែងតែការព្យាបាលជំងឺមហារីកដោយសារធាតុគីមី និងឱសថសារវន្តដែលត្រូវទូទាត់ថ្លៃសេវាព្យាបាលនីមួយៗ[72] ។

### ៣.៥.២. លក្ខខណ្ឌក្នុងការប្រើប្រាស់សេវាហានិភ័យការងារ

- កម្មករនិយោជិតកំពុងបម្រើការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកាផ្នែកហានិភ័យការងារ ។
- និយោជកត្រូវចេញលិខិតបញ្ជូនជនរងគ្រោះ ដោយគ្រោះថ្នាក់ការងារ។
- លិខិតព្យាបាលបន្ត (ព្យាបាលលើកទី២) ដែលចេញដោយ ប.ស.ស។

ក្នុងករណីសមាជិក ប.ស.ស. ទៅប្រើប្រាស់សេវា នៅមូលដ្ឋានសុខាភិបាលមិនមែនជាដៃគូរ ប.ស.ស. ពុំចាំបាច់មានលិខិតបញ្ជូនជនរងគ្រោះទេ ក៏ប៉ុន្តែបន្ទាប់ពីព្យាបាលរួចត្រូវមានលិខិតវេជ្ជបញ្ជារបស់គ្រូពេទ្យផ្លូវការដើម្បីធ្វើការទាមទារតាវលិកព្យាបាលពី ប.ស.ស.។

---

[70] ប្រកាសអន្តរក្រសួងស្តីពី យន្តការទូទាត់ថ្លៃសេវាផ្នែកថែទាំសុខភាព, លេខ១៧៣ ក.ប/ប្រ.ក, ០៥ ឧសភា ២០១៦, ឧបសម្ព័ន្ធ ២ ។

[71] អនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីរាជសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ,លេខ ១៣៤ អនក្រ.បក, ២៣ សីហា ២០១៧, មាត្រា ២១។

[72] អនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់តាវកាលិកផ្នែកថែទាំសុខភាព សម្រាប់មន្ត្រីរាជសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន ,លេខ ១៣៤ អនក្រ.បក, ២៣ សីហា ២០១៧, មាត្រា ២១។

### ៣.៥.៣. ការផ្តល់ព័ត៌មានហានិភ័យការងារទៅកាន់ប.ស.ស.

ជនរងគ្រោះដោយគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ក្នុងពេលធ្វើដំណើរ ឬជំងឺវិជ្ជាជីវៈ ឬក៏អ្នកតំណាងជនរងគ្រោះ ត្រូវជូនដំណឹងជាបន្ទាន់ទៅ ប.ស.ស និយោជក ឬអ្នកតំណាងនិយោជក អំពី គ្រោះថ្នាក់ដែលធ្លាក់មកលើខ្លួន លើកលែងតែក្នុងករណីប្រធានសក្តិ។

បែបបទនៃការជូនដំណឹងពីហានិភ័យការងារ ការអង្កេតហានិភ័យការងារ និងការត្រួតពិនិត្យការអនុវត្តកាតព្វកិច្ចរបស់និយោជក មូលដ្ឋានសុខាភិបាល និងជនរងគ្រោះថ្នាក់ការងារក្នុងពេលធ្វើដំណើរ និងជំងឺវិជ្ជាជីវៈ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គមតាមសំណើររបស់ក្រុមប្រឹក្សាភិបាលនៃ ប.ស.ស។[73]

### ៣.៥.៤. ការអង្កេតហានិភ័យការងារ

បន្ទាប់ពីទទួលបានរបាយការណ៍ហានិភ័យការងារ ការិយាល័យតាវកាលិក ឬការិយាល័យខេត្ត/ខណ្ឌ នៃ ប.ស.ស ត្រូវជូនដំណឹងជាបន្ទាន់ទៅអធិការ ឬអភិបាលសន្តិសុខសង្គម។ អធិការ ឬអភិបាលសុខសង្គមត្រូវធ្វើការអង្កេត និងផ្តល់លទ្ធផលលើករណីនីមួយៗមកការិយាល័យតាវកាលិកឱ្យបានឆាប់បំផុត។ ក្នុងករណីដែលមានលក្ខណៈស្មុគស្មាញ អធិការ ឬអភិបាលសន្តិសុខសង្គមអាចស្នើសុំជំនួយពីអ្នកឯកទេស ឬសុំកិច្ចសហការពីអធិការ ឬអភិបាលការងារ។

ការចំណាយសម្រាប់ផ្នែកនេះ គឺជាបន្ទុករបស់ ប.ស.ស ។ ចំពោះគ្រោះថ្នាក់ពេលធ្វើដំណើរ អធិការ ឬអភិបាលសន្តិសុខសង្គមត្រូវស្នើសុំព័ត៌មានដែលទាក់ទងនឹងទីកន្លែង ពេលវេលា មូលហេតុនៃគ្រោះថ្នាក់ពីសាក្សី ឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងទីកន្លែងកើតហេតុ[74]។

### ៣.៥.៥. ការទាមទារតាវកាលិក

ការទាមទារតាវកាលិកសម្រាប់ការថែទាំ និងព្យាបាលអាចត្រូវបានធ្វើឡើងដោយមូលដ្ឋានសុខាភិបាលដែលព្យាបាលជនរងគ្រោះ ឬនិយោជក ឬក៏កម្មករនិយោជិតជាជនរងគ្រោះតាមទម្រង់ "តាវកាលិកហានិភ័យការងារ" ។

ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ សម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នត្រូវធ្វើឡើងដោយជនរងគ្រោះ ឬតំណាងតាមទម្រង់ "តាវកាលិកហានិភ័យការងារ" ។ បែបបទនៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនូវវេជ្ជបញ្ជា និងលិខិតបញ្ជាក់ពីគ្រូពេទ្យព្យាបាលផ្លូវការ។

ការទាមទារតាវកាលិកសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវធ្វើឡើងដោយជនរងគ្រោះតាមទម្រង់ "តាវកាលិកហានិភ័យការងារ" ។ ក្នុងករណីដែលជនរងគ្រោះមិនអាចមាន

[73] ច្បាប់ស្តីពីរបបសន្តិសុខសង្គម, លេខ ០១៨ នស/រកម/១១១៩, ០២ វិច្ឆិកា ២០១៩, មាត្រា៦៦ ។

[74]ប្រកាសស្តីពីតាវកាលិកហានិភ័យការងារ,លេខ ១០៩ កប/ប្រ.ក, ១៦ មិថុនា ២០០៨, ប្រការ៣។

សមត្ថភាពក្នុងការទាមទារនេះអាចត្រូវធ្វើឡើងដោយអ្នកតំណាងជនរងគ្រោះ។ អ្នកតំណាងជនរងគ្រោះអាចជា ប្ដី ប្រពន្ធ កូន ឬជនដែលមានភារៈថែរក្សាដោយផ្ទាល់ចំពោះជនរងគ្រោះ។

ការទាមទារតាវកាលិកឧត្តរជីវី និងសោហ៊ុយបូជាសព ត្រូវធ្វើឡើងដោយសិទ្ធិវន្តនៃជនរងគ្រោះ ឬអ្នកតំណាងតាមទម្រង់ "តាវកាលិកហានិភ័យការងារ" ។ សមាជិក ប.ស.ស. មានសិទ្ធិនៃការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ហានិភ័យការងារ និងប្រាក់វិភាជន៍បូជាសពត្រូវអស់សុពលត្រឹមរយៈពេល ០១ (មួយ) ឆ្នាំ ។ ចំពោះសិទ្ធិក្នុងការទាមទារប្រាក់ធនលាភត្រូវអស់សុពលភាពត្រឹមរយៈពេល ០៥ ឆ្នាំ ហើយក្នុងការបើកប្រាក់ធនលាភត្រូវបើកជាប្រចាំខែ[75]។

### ៣.៥.១.ផ្ដល់ការទូរទាត់ត្រឡប់ទៅវិញសម្រាប់ករណីសង្គ្រោះបន្ទាន់

ក្នុងករណីសមាជិក ប.ស.ស ដែលគ្រោះថ្នាក់កើតនៅនឹងកន្លែងធ្វើការ និយោជកត្រូវផ្ដល់ការសង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យដែលនៅកន្លែងជិតបំផុត និងបន្ទាប់មកត្រូវបញ្ជូនជនរងគ្រោះទៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល ដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម។ ការចំណាយលើការសង្គ្រោះបន្ទាន់ និងការបញ្ជូនជនរងគ្រោះត្រូវស្ថិតនៅក្នុងបន្ទុករបស់ ប.ស.ស។ ក្នុងករណីសមាជិក ប.ស.ស ដែលគ្រោះថ្នាក់នៅពេលធ្វើដំណើរ ជនរងគ្រោះ ឬនិយោជកអាចទាមទារការទូទាត់សងលើការចំណាយសម្រាប់ការសង្គ្រោះនេះពីបេឡាជាតិរបបសន្តិសុខសង្គម[76] លើកលែងតែមូលដ្ឋានសុខាភិបាលដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស គឺតម្រូវឱ្យសមាជិក ប.ស.ស ចំណាយប្រាក់ក្នុងការសង្គ្រោះបន្ទាន់ បន្ទាប់មកពួកគាត់ត្រូវយកវិក្កយបត្រដែលទទួលស្គាល់ដោយគ្រូពេទ្យផ្លូវការដើម្បីធ្វើការទូទាត់ពី ប.ស.ស វិញ។

### ៣.៥.២. ការផ្ដល់ការថែទាំ និងការព្យាបាលវេជ្ជសាស្ត្រ

សមាជិក ប.ស.ស ដែលរងគ្រោះដោយហានិភ័យការងារ ត្រូវទៅព្យាបាលនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលដែលទទួលស្គាល់ដោយបេឡាជាតិរបបសន្តិសុខសង្គម ដោយផ្អែកលើកិច្ចព្រមព្រៀងរវាង ប.ស.ស ជាមួយនឹងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលសាមី នឹងមានសិទ្ធិទៅព្យាបាលនៅតាមបណ្ដាលមន្ទីរពេទ្យដែលមិនមែនជាដៃគូ ប.ស.ស បានផងដែរ។ ក្នុងករណីដែលគ្រូពេទ្យតម្រូវឱ្យទិញឱសថ ឬសំភារៈឧបករណ៍ដែលចាំបាច់សម្រាប់ការថែទាំ និងព្យាបាលដែលពុំមានចែងនៅក្នុងកិច្ចព្រមព្រៀង ប.ស.ស អាចទូទាត់ទៅជនរងគ្រោះ ឬអ្នកតំណាងវិញបានលុះណាតែមានវេជ្ជបញ្ជា និងវិក្កយបត្រត្រឹមត្រូវ[77]។ ប្រសិនបើការថែទាំ និងព្យាបាលធ្វើនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលផ្សេង

[75] ប្រកាសស្ដីពីការសម្រួលប្រការ ៦ ប្រការ ១១ និងប្រការ ១៣ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.កចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងារ,លេខ ៤៨០ ក.ប/ប្រ.ក.ប.ស.ស,១៨ តុលា ២០១៨,ប្រការ ១៣ ថ្មី។

[76] ប្រកាសស្ដីពីតាវកាលិកហានិភ័យការងារ,លេខ ១០៩ កប/ប្រ.ក, ១៦ មិថុនា ២០០៨,ប្រការ ៤។

[77] ប្រកាសស្ដីពីតាវកាលិកហានិភ័យការងារ,លេខ ១០៩ កប/ប្រ.ក, ១៦ មិថុនា ២០០៨,ប្រការ ៥។

ក្រៅពីការកំណត់របស់បេឡាជាតិរបបសន្តិសុខសង្គម ការទូទាត់សងវិញត្រូវធ្វើតាមអត្រាតម្លៃដែល ប.ស.ស បានកំណត់។

### ៣.៥.៣.ការផ្តល់ប្រាក់បំណាច់ជនរងគ្រោះ

កម្មករនិយោជិតដែលបានសម្រាកព្យាបាលមុខរបួស ឬជំងឺវិជ្ជាជីវៈនៅក្នុងមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល និងការសម្រាកព្យាបាលក្រោយពេលមុខរបួសជាសះស្បើយតាមវេជ្ជបញ្ជាចំពោះការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ន។

សមាជិក ប.ស.ស ដែលរងគ្រោះដោយហានិភ័យការងារ មានសិទ្ធិទទួលបានតាវកាលិកពី ប.ស.ស ដូចជា ៖

- ប្រាក់បំណាច់ប្រចាំថ្ងៃ ៧០% នៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្នដែលត្រូវផ្តល់ជូនគិតចាប់ពីថ្ងៃទីពីរ បន្ទាប់ពីកាលបរិច្ឆេទនៃការកើតឧបទ្ទវហេតុបណ្តាលឱ្យទទួលរងនូវហានិភ័យការងារ។
- ប្រាក់ឧបត្ថម្ភសម្រាប់អ្នកថែទាំនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាលត្រូវស្មើនឹង ៥០ % នៃប្រាក់បំណាច់ប្រចាំថ្ងៃរបស់ជនរងគ្រោះ ក្នុងរយៈពេលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមន្ទីរពហុព្យាបាល។
- ចំពោះប្រាក់ឈ្នួលថ្ងៃផ្អាកការងារដំបូងរបស់ជនរងគ្រោះថ្នាក់ការងារ ត្រូវនៅក្នុងបន្ទុករបស់និយោជក។

ប្រាក់បំណាច់ប្រចាំថ្ងៃសម្រាប់ការបាត់បង់សមត្ថភាពការងារបណ្តោះអាសន្ននេះ ត្រូវផ្តល់ជូនជនរងគ្រោះរហូតដល់មុខរបួសជាសះស្បើយ[78]។

ខ. ការផ្តល់តាវកាលិកអចិន្ត្រៃយ៍

សមាជិក ប.ស.ស ដែលទទួលរងហានិភ័យការងារ បណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍តិចជាង ២០% មានសិទ្ធិទទួលបានប្រាក់វិភាជន៍សម្រាប់ការបាត់បង់សមត្ថភាពការងារ។

តាមរូបមន្តដូចខាងក្រោម ៖

វបក = បឈម × កបក × ២០% មតប

- វបក : វិភាជន៍បាត់បង់សមត្ថភាពការងារ
- បឈម : ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់ជនរងគ្រោះ
- កបក : កម្រិតបាត់បង់សមត្ថភាពការងាររបស់ជនរងគ្រោះ

[78] ប្រកាសស្តីពីការកែសម្រួលប្រការ ៧ និងប្រការ ៩ នៃប្រកាសលេខ ១០៩ កប/ប្រក ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ,លេខ ១៤០ កប/ប្រ.ក, ១៥ មិថុនា ២០១០, ប្រការ ៧ ថ្មី។

- មតប : មេគុណតម្លៃបច្ចុប្បន្ន[79]។

គ. របៀបនៃការគណនាវិភាជន៍

លោក សម្បត្តិ មានអាយុ ២៥ ឆ្នាំ បានចុះកិច្ចសន្យាការងារជាមួយក្រុមហ៊ុន X Co.,Ltd ក្នុងរយៈពេល ២ ឆ្នាំ។ កិច្ចសន្យានេះបានចាប់ផ្តើមពីថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៩ រហូតដល់ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១ និងលោក វិបុល ទទួលបានប្រាក់ខែចំនួន ២,០០០,០០០ (ពីរលាន) រៀល ក្នុងមួយខែ ។ ក្រុមហ៊ុន X Co.,Ltd បានចុះបញ្ជិកាជាមួយ ប.ស.ស ផ្នែកហានិភ័យការងារក្នុងឆ្នាំ ២០១៨ នឹងបានបង់ភាគផ្នែកនេះរហូតមក។ នៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២០ លោក សម្បត្តិ បានជួបគ្រោះថ្នាក់ការងារនៅកន្លែងធ្វើការបណ្តាលឱ្យដាច់ម្រាមដៃចង្អុលដៃទាំងមូល។

ចូរគណនាវិភាជន៍ដែលលោកសម្បត្តិទទួលបានពី ប.ស.ស.?

**១. គណនាប្រាក់ឈ្នួលមធ្យមរបស់លោក សម្បត្តិ**

តាមសម្មតិកម្ម ៖ ប្រាក់ឈ្នួលរបស់លោក សម្បត្តិ ទទួលបានក្នុង ១ ខែ ចំនួន ២,០០០,០០០ (ពីរលាន) រៀល ថេរ ក្នុងរយៈពេល ៦ ខែមុនគ្រោះថ្នាក់ ហើយប្រាក់ឈ្នួលជាប់ភាគទានរបស់គាត់ គឺចំនួន ១,២០០,០០០ រៀល ។

ដោយប្រាក់ឈ្នួលមធ្យម $= \frac{១,២០០,០០០៛ \times ៦}{៦ \text{ ខែ}} = ១,២០០,០០០៛$

**២. គណនាប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ**

នាំឱ្យប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ $= \frac{១,២០០,០០០ ៛}{៣០ \text{ ថ្ងៃ}} = ៤០,០០០៛$

**៣. គណនាវិភាជន៍របស់ លោក សម្បត្តិ**

តាមរូបមន្ត វបក = បឈម × កបក × ២០% មតប

ដោយបឈម = ៤០,០០០ ៛ ,កបក (ដាច់ម្រាមដៃចង្អុលទាំងមូល) = ១៤%

មតប (អាយុ ២៥ឆ្នាំ ) = ១០,៤៧០

នាំឱ្យ វបក = ៤០,០០០៛ × ០.១៤ × ០.២ × ១០,៤៧០ = ១១,៧២៦,៤០០៛

ដូចនេះ ប្រាក់វិភាជន៍ដែលលោក សម្បត្តិ ទទួលបានពី ប.ស.ស ស្មើ ១១,៧២៦,៤០០៛ គឺបើកបានតែម្តងគត់។

[79] ប្រកាសស្តីពីការកែសម្រួលប្រការ ៨ និងប្រការ ១០ នៃប្រកាសលេខ ១០៩ កប/ប្រកចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ, លេខ ២៣៣ ក.ប/ប្រ.ក, ០៧ វិច្ឆិកា ២០១១,ប្រការ ៨ ថ្មី កថាខណ្ឌទី ១។

### ៣.៥.៤ ករណីបាត់បង់សមត្ថភាពការងារលើស ២០%

កម្មករនិយោជិតដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារចាប់ពី ២០% ភាគរយឡើង មានសិទ្ធិទទួលបានធនលាភសម្រាប់ការបាត់បង់សមត្ថភាពភាពការងារអចិន្ត្រៃយ៍តាមរូបមន្តដូចខាងក្រោម ៖

ធល = បឈម× [កបក-១/៥កបក]

ធល : ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារ

ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ ត្រូវចាត់ទុកជាបណ្តោះអាសន្នជានិច្ច។ ប.ស.ស ត្រូវរៀបចំឱ្យមានការពិនិត្យសុខភាព និងសមត្ថភាពការងារ អ្នករងគ្រោះឡើងវិញក្នុងរយៈពេល ១(មួយ)ឆ្នាំយ៉ាងយូរ។ ជនរងគ្រោះដែលទទួលបានធនលាភត្រូវមានកាតព្វកិច្ចមកពិនិត្យតាមការកំណត់របស់ ប.ស.ស.។ ប្រាក់ធនលាភសម្រាប់ការបាត់បង់សមត្ថភាព ការងារជាអចិន្ត្រៃយ៍ត្រូវបានពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ដោយអនុលោមតាមអត្រាអតិផរណា ដែលចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[80]

### ក. ការផ្តល់ប្រាក់ឧបត្ថម្ភ ៥០% ចំពោះអ្នកមើលថែជនរងគ្រោះ

ក្នុងករណីសមាជិក ប.ស.ស ដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដែលតម្រូវឱ្យមានអ្នកចាំថែរក្សា នោះអ្នកមើលថែមានសិទ្ធិទទួលបានការឧបត្ថម្ភបន្ថែមស្មើនឹង ៥០ (ហាសិប) ភាគរយនៃប្រាក់ធនលាភរបស់ជនរងគ្រោះ។ សិទ្ធិទទួលបានរបស់អ្នកចាំថែរក្សាត្រូវសម្រេច ដោយនាយកបេឡាជាតិរបបសន្តិសុខសង្គមអនុលោមទៅតាមការវាយតម្លៃរបស់គណៈកម្មការវេជ្ជសាស្ត្រ[81]។

### ខ. សេវាបុននីតិសម្បទា

សមាជិក ប.ស.ស ដែលទទួលរងហានិភ័យការងារបណ្តាលឱ្យបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍មានសិទ្ធិទទួលបានសេវាស្តារ នីតិសម្បទាផ្នែកវេជ្ជសាស្ត្រ ឬសេវាស្តារនីតិសម្បទាផ្នែកបណ្តុះបណ្តាលវិជ្ជាជីវៈឡើងវិញ ឬសេវាស្តារនីតិសម្បទាផ្នែកសង្គម[82] ដោយឥតគិតថ្លៃ។

---

[80] ប្រកាសស្តីពីការកែសម្រួលប្រការ ៨ និងប្រការ ១០ នៃប្រកាសលេខ ១០៩ កប/ប្រកចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ, លេខ ២៣៣ ក.ប/ប្រ.ក, ០៧ វិច្ឆិកា ២០១១,ប្រការ ៨ ថ្មី ។

[81] ប្រកាសស្តីពីការកែសម្រួលប្រការ ៨ និងប្រការ ១០ នៃប្រកាសលេខ ១០៩ កប/ប្រកចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ, លេខ ២៣៣ ក.ប/ប្រ.ក, ០៧ វិច្ឆិកា ២០១១,ប្រការ៩ ថ្មី។

[82] ប្រកាសស្តីពីសេវាស្តារនីតិសម្បទាសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ, លេខ ៤៧៧ ក.ប/ប្រ.ក.ប.ស.ស, ១៦ តុលា ២០១៨,ប្រការ ៨។

### ៣.៥.៥. ការផ្តល់តាវកាលិកគ្រោះថ្នាក់ការងាររហូតបាត់បង់ជីវិត

ក្នុងករណីសមាជិក ប.ស.ស ទទួលរងហានិភ័យការងាររហូតបណ្តាលឱ្យបាត់បង់ជីវិត នោះ ប.ស.ស នឹងផ្តល់សេវាដឹកជញ្ជូនសពអាចធ្វើតាមមធ្យោបាយបញ្ជូនរបស់មូលដ្ឋានសុខាភិបាល ឬប្រភេទមធ្យោបាយជាក់ស្តែងផ្សេងទៀត។ ហើយ ប.ស.ស នឹងផ្តល់ប្រាក់វិភាជន៍ជាសោហ៊ុយបូជាសពដែលមានចំនួន ៤,000,000 (បួនលាន)រៀលដល់ក្រុមគ្រួសារសព ឬអ្នកទទួលរ៉ាប់រងក្នុងការចាត់ចែងបូជាសព។ ប្រាក់វិភាជន៍នេះត្រូវផ្តល់ជូនអ្នកដែលទទួលបន្ទុកផ្ទាល់ក្នុងការចាត់ចែងបូជាសពជនរងគ្រោះ[83]។

### ក. តាវិកាលិកចំពោះឧត្តរជីវី

ឧត្តរជីវី សំដៅដល់បុគ្គលដែលនៅរស់ក្នុងបន្ទុកផ្ទាល់នៃសមាជិក ប.ស.ស មុនកាលបរិច្ឆេទដែលសាមីជនបានទទួលមរណភាព ស្របតាមលក្ខខណ្ឌដែលកំណត់នៅក្នុងបទប្បញ្ញត្តិនៃច្បាប់។ ឧត្តរជីវី នៃជនរងគ្រោះដោយហានិភ័យការងារ ដូចមានចែងក្នុងមាត្រា ៣៤ នៃអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គមមានសិទ្ធិទទួលបានតាវកាលិកឧត្តរជីវី។

តាវកាលិកឧត្តរជីវី គឺជាប្រាក់ធនលាភដែលត្រូវផ្តល់សិទ្ធិឱ្យសិទ្ធិវន្តនៃជនរងគ្រោះតាមអត្រាដែលបានកំណត់ដូចខាងក្រោម ៖

- ក្នុងករណីសិទ្ធិវន្ត មានរួមទាំងប្រពន្ធ ឬប្តី កូន និងឪពុកម្តាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុក
  - ប្រពន្ធ ឬប្តី = ៣/៥ × ៦៣% បឈម
  - ធនលាភសុបេសម្រាប់កូនក្នុងបន្ទុក =២/៥ × ៦៣% បឈម
  - ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ក្នុងបន្ទុក =៧% បឈម
- ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្តី និង/ឬកូន
  - ប្រពន្ធ ឬប្តី =៣/៥ × ៧០% បឈម
  - ធនលាភសរុបសម្រាប់កូនក្នុងបន្ទុក = ២/៥ × ៧០ % បឈម
- ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្តី និង/ឬកូន
  - ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ៣៥%
- ក្នុងករណីសិទ្ធិវន្តមានតែកូន និងឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក
  - ធនលាភសសរុបសម្រាប់កូនក្នុងបន្ទុក =២៨ % បឈម
  - ធនលាភសរុបសម្រាប់ឪពុកម្តាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បឈម
- ក្នុងករណីសិទ្ធិវន្តមានតែប្រពន្ធ ឬប្តី និងឪពុកម្តាយ ឬមនុស្សចាស់ជរា

[83] ប្រកាសស្តីពីការកែសម្រួលប្រការ ៨ និងប្រការ ១០ នៃប្រកាសលេខ ១០៩ កប/ប្រកចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៨ ស្តីពីតាវកាលិកហានិភ័យការងារ, លេខ ២៣៣ ក.ប/ប្រ.ក, ០៧ វិច្ឆិកា ២០១១,ប្រការ ១០ ថ្មី។

- ○ ប្រពន្ធ ឬប្ដី = ២៨% បលឈម
- ○ ធនលាភសរុបសម្រាប់ឪពុកម្ដាយ ឬមនុស្សចាស់ជរាក្នុងបន្ទុក = ២៨% បលឈម

- ក្នុងករណីសិទ្ធិវន្តមានតែប្ដី ឬប្រពន្ធ ឬកូន ក្នុងបន្ទុក = ៥៦%[84]។

## ខ. សិទ្ធិវន្តនៃធនលាភឧត្តរជីវី

សិទ្ធិវន្តនៃធនលាភឧត្តរជីវី រួមមានសហព័ន្ធ និងកូន ព្រមទាំងឪពុកម្ដាយ ឬមនុស្សចាស់ជរាដែលរស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនមុនពេលទទួលមរណភាព និងត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

- សម្រាប់ប្ដី ឬប្រពន្ធ ត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍មុនកាលបរិច្ឆេទ នៃហានិភ័យការងារ ឬ មុនពេលទទួលមរណភាពដោយហានិភ័យការងារ។
- ចំពោះកូនត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖

○មិនទាន់រៀបអាពាហ៍ពិពាហ៍

○ជាកូនបង្កើត

○ក្នុងងករណីដែលមានការលែងលះ ឬករណីមរណភាពនៃប្ដី ឬប្រពន្ធ កូននៃគូស្រករក្រោយដែលនៅក្នុងបន្ទុកផ្ទាល់របស់សាមីជន ក៏មានសិទ្ធិដូចកូននៃអាពាហ៍ពិពាហ៍មុនដែរ

○កូនសុំរបស់សាមីជនរងគ្រោះ ដែលបានសុំស្របតាមបទប្បញ្ញត្តិជាធរមាន ឬក្មេងកំព្រារស់នៅក្នុងបន្ទុកផ្ទាល់របស់សាមីជនជនរងគ្រោះ

○មានអាយុមិនលើសពី ២១ (ម្ភៃមួយ) ឆ្នាំ។

កូនពិការ ឬមានជំងឺរ៉ាំរ៉ៃ ហើយមិនអាចប្រកបការងារ ឬមុខរបរដែលមានប្រាក់ចំណូលត្រូវផ្ដល់ធនលាភឧត្តរជីវីអស់មួយជីវិត។ ការកំណត់ស្ថានភាពពិការ ឬជំងឺរ៉ាំរ៉ៃត្រូវបញ្ជាក់ដោយគ្រូពេទ្យ ឯកទេស និងមានការយល់ព្រមពីក្រុមប្រឹក្សាវេជ្ជសាស្ត្រនៃ ប.ស.ស. ។

- ឪពុកម្ដាយ ឬមនុស្សចាស់ជរានៅក្នុងបន្ទុកផ្ទាល់របស់ជនរងគ្រោះដែលមានអាយុយ៉ាងតិច ៦០ (ហុកសិប) ឆ្នាំ គិតត្រឹមកាលបរិច្ឆេទនៃការទទួលមរណភាពរបស់ជនរងគ្រោះ និងមិនមានប្រកបមុខរបរដែលមានប្រាក់ចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាព។ ចំពោះឪពុកម្ដាយ ឬមនុស្សចាស់ជរាដែលមានជំងឺរ៉ាំរ៉ៃ ព្យាបាលមិនជា ឬមានទុព្វលភាព និងមិនមានប្រាក់ចំណូល ឬប្រាក់សោធននិវត្តន៍ ឬសោធនជរាភាពមិនត្រូវបានកំណត់អាយុឡើយ។
- សិទ្ធិទទួលបានធនលាភឧត្តរជីវីត្រូវផុតរលត់ក្នុងករណីដូចខាងក្រោម ៖

○សាមីជនទទួលមរណភាព។

[84] ប្រកាសស្ដីពីការកែសម្រួលប្រការ៦ ប្រការ ១១ និងប្រការ ១៣ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.កចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ២០០៨ ស្ដីពីតាវកាលិកហានិភ័យការងារ,លេខ ៤៨០ ក.ប/ប្រ.ក. ប.ស.ស, ១៨ តុលា ២០១៨,ប្រការ ១១ថ្មី។

○ប្តី ឬប្រពន្ធរៀបអាពាហ៍ពិពាហ៍ជាថ្មី ស្របតាមនីតិវិធីច្បាប់ដែលមានជាធរមាន។ ក្នុងករណីនេះ សាមីជនត្រូវជូនដំណឹងមក ប.ស.ស. យ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការរៀបអាពាហ៍ពិពាហ៍ថ្មី[85] ។

○សាមីជនដល់នីតិភាព។

[85] ច្បាប់ស្តីពីរបបសន្តិសុខសង្គម, លេខ នស/រកម/១១១៩/០១៨, ០២ វិច្ឆិកា ២០១៩, មាត្រា៦៨។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីយើងខ្ញុំបានចុះកម្មសិក្សានៅក្នុងស្ថាប័ន និងធ្វើការសិក្សាលើទិន្នន័យប្រចាំឆ្នាំ ព្រមទាំងច្បាប់បទដ្ឋានគតិយុត្តិផ្សេងៗ ជាមួយបេឡាជាតិសន្តិសុខដោយផ្ទាល់ស្តីពីដំណើរការវិវត្តន៍របស់របបសន្តិសុខសង្គមរួមទាំងស្វែងយល់ពីសកម្មភាពដែលស្ថាប័ននេះ បានអនុវត្តការងាររបស់គណៈគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ មន្ត្រី បុគ្គលិករបស់បេឡាជាតិសន្តិសុខសង្គម យើងអាចធ្វើការសន្និដ្ឋានបានថា បេឡាជាតិសន្តិសុខសង្គមគឺជាស្ថាប័នមួយដែលផ្តល់សេវាកម្មលើធានារ៉ាប់រងផ្នែកថែហានិភ័យការងារ ផ្នែកថែទាំសុខភាព ផ្នែកប្រាក់សោធន៍និវត្តន៍ ដែលសម្រួលដល់ជីវិតភាពកម្មករនិយោជិត មន្ត្រីរាជការក្នុងវិស័យសាធារណៈ ព្រមទាំងអតីតមន្ត្រីរាជការ និងអតីតយុទ្ធជនដែលជួបសម្របសម្រួលដល់ជីវភាពគ្រួសារក្នុងការសម្រាកព្យាបាលជំងឺ ទទួលបានការពារពេលមានគ្រោះថ្នាក់ការងារនឹងសម្រាកព្យាបាលដោយទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃដែលជួយជំរុញដល់សេដ្ឋកិច្ចគ្រួសារ និងសង្គមឱ្យបានកាន់តែល្អប្រសើរ ដោយប្រកបស្តង់ដាសង្គមធម្យមកម្រិតទាប។

លើសពីនេះរហូតមកដល់បច្ចុប្បន្នបេឡាជាតិសន្តិសុខសង្គម ក៏បន្តគ្រប់ដណ្តប់លើវិសាលយ៉ាងធំទូលាយ ក្នុងកម្ពុជាដែលសបញ្ជាក់ថាការវិត្តន៍ប្រព័ន្ធសន្តិសុខសង្គមនូវកម្ពុជាបន្តជួយសម្រួលជាច្រើនដល់និយោជក បន្ទាប់ពីសហគ្រាសបានបំពេញកាតព្វកិច្ចក្នុងបង់ភាគទាន និងទូទាត់ភាគទានជូនបេឡាជាតិសន្តិសុខសង្គមទាន់ពេលវេលា។ លើសពីទៀតវិស័យសន្តិសុខសង្គមបាននឹងបន្តជួយសម្របសម្រួល ព្រមទាំងកែតម្រូវដល់មូលដ្ឋានសុខាភិបាលដើម្បីឱ្យសមាជិកខ្លួនបានទទួលសេវាកម្មដូចអតិថិជនដែលបង់ប្រាក់ក្នុងតម្លៃពេញឬទូទាត់ភ្លាមៗ ព្រមទាំងផ្តល់អត្ថប្រយោជន៍ជាសាច់ជាច្រើនដល់សមាជិក ឬអ្នកក្នុងបន្ទុក។ក្នុងករណីមានគ្រោះថ្នាក់ការងាររហូតដល់ពិការភាព ប.ស.ស. និង ផ្តល់អត្ថប្រយោជន៍ដល់សមាជិកដូចជាឧបករណ៍សប្បនិមត្ត ព្រមទាំងមានការបង្ហាត់បង្រៀនវិជ្ជាជីវៈ ឬស្តារនីតិសម្បទាឡើងវិញជូនដល់ពួកគាត់។លើសពីនេះស្ថាប័នមួយនេះបានបម្រើសមាជិករបស់ខ្លួនប្រកបដោយសីលធម៌ ពោលពេញដោយសមត្ថភាព ចំណេះដឹង នឹងកាយវិការល្អដល់សមាជិក ដើម្បីសម្រេចគោលដៅរួមរបស់ស្ថាប័ន។លើសពីនេះទៅទៀតប៉ុន្មានឆ្នាំចុងក្រោយនេះបេឡាជាតិសន្តិសុខបានវិវត្តន៍ខ្លួន ឥតឈប់ឈរបង្ហាញខ្លួនយ៉ាងសម្បើម លើរបបសន្តិសុខសង្គមនៅកម្ពុជាដោយបានក្តាប់ដណ្តប់លើរបបចំនួនពីរគឺ របបហានិភ័យការងារ និងរបបថែទាំសុខភាព ហើយនាពេលខាងនេះមុខនឹងដាក់ដំណើរនៅរបបសោធន នៅក្នុងវិស័យឯកជន និងមន្ត្រីរាជការសាធារណៈ។ ទោះបីជាក្នុងរបបប្រល័យពូជរបបនេះត្រូវបានបំបាត់ចោលទាំងស្រុង និងព្រមបានបំផ្លាញចោល ក៏នាពេលបច្ចុប្បន្នដោយបានគាំទ្រពីរដ្ឋាភិបាលបានធ្វើវិសោធនកម្មច្បាប់ជាថ្មីម្តងទៀត បានធ្វើរបបសន្តិសុខសង្គមបានរះជាថ្មីលើដែនដីចាស់។

ជារួមការអនុវត្តរបបសន្តិសុខសង្គមនៅកម្ពុជា បានបំពេញតម្រូវទាន់ពេលវេលាជូនសមាជិកខ្លួនដែលបានចុះបញ្ជិការ ជាមួយដោយចំណែកការកាត់បន្ថយភាពក្រីក្រក្នុងសង្គមជាតិខ្លួននាបច្ចុប្បន្ន

ព្រមទាំងបានជួយជំរុញ និងកែប្រែវិស័យសុខាភិបាលនៅកម្ពុជាប្រកបភាពមិនលំអៀង ប្រកាន់អ្នកក្រ ឬមាន ដោយប្រកបភាពវិសមភាពសម្រាប់សមាជិកទូទៅ។ ព្រមទាំងបន្តរីកចម្រើន និងបន្តដំណើរទៅមុខជានិច្ចជាសមាជិកខ្លួន។

សរុបសេចក្តីមកបានបង្ហាញឱ្យកាន់តែឃើញ ដំណើរការវិវត្តន៍នៃរបបសន្តិសុខសង្គមនូវបានបន្តនូវលក្ខណៈកាន់តែប្រសើរឡើង ក្នុងដំណើរបម្រើប្រជាជនខ្លួនឱ្យពីលទ្ធភាពដោយក្រោយការដឹកដ៏ឆ្លាតវៃរបស់ថ្នាក់ដឹកប្រទេស ព្រមទាំងគណៈគ្រប់គ្រង ប.ស.ស. ទាំងអស់ ដោយចូលរួមដោះស្រាយបញ្ហាដើម្បីបំពេញសេចក្តីត្រូវការរបស់សមាជិកខ្លួនកាន់ប្រសើរ លើសពីបាននឹងកំពុងបន្តពង្រីក និងពង្រឹងវិសាលភាពឱ្យគ្រប់លើគ្រប់វិស័យ ជាហេតុនាំស្ថាប័ននេះមួយបាននឹងបន្តពង្រីកខ្លួនយ៉ាងសម្បើមព្រមទាំងភាពជោគជ័យរហូតដល់បច្ចុប្បន្ន។

## ២. ការផ្តល់អនុសាសន៍

ជាការពិតណាស់ បេឡាជាតិសន្តិសុខសង្គម មានចំណុចខ្លាំងជាច្រើននៅក្នុងការប្រតិបត្តិការរបស់ខ្លួន ដែលបានធ្វើឱ្យស្ថាប័នមួយនៅបន្តឈរជើងយ៉ាងសង្ហាព្រមទាំងមានការរីកចម្រើនជាលំដាប់ទៅមុខយ៉ាងរហ័ស។ ប៉ុន្តែស្ថាប័នមួយនេះនូវតែមានចំណុចខ្វះខាតបន្តិចបន្តួចសម្រាប់ការកែតម្រូវឱ្យមានជឿលឿនជាងនេះទៅទៀត។ដូចក្នុងការចូលរួមជាមតិយោបលដើម្បីស្ថាបនទៅលើគ្រប់សកម្មភាពនៃដំណើរវិវត្តន៍នៃរបបសន្តិសុខសង្គម យើងខ្ញុំសូមចូលរួមចំណែកផ្តល់អនុសាសន៍ និងសំណូមពរមួយចំនួនដើម្បីឱ្យស្ថាប័នមួយនេះពិចារណាក្នុងការកែលម្អដែលមានដូចជា៖

- ពង្រឹងការអនុវត្តច្បាប់ដែលពាក់ព័ន្ធទៅនឹងរបបសន្តិសុខសង្គមឱ្យកាន់តែមានភាពប្រសិទ្ធភាព
- ពង្រឹងសមត្ថភាព មន្ត្រី និងបុគ្គលិកតាមការិយាល័យជំនាញនីមួយៗឱ្យកាន់តែមានភាពជំនាញ និងយល់ដឹកការងាររបស់ខ្លួនឱ្យតែច្បាស់លាស់
- ប្រើប្រាស់មន្ត្រី និងបុគ្គលិកឱ្យត្រូវនឹងជំនាញរបស់គាត់មាន
- គួរតែមានវិធានការណ៍នានា រឹតបន្តឹងចំពោះមន្ត្រី និងបុគ្គលិកដែលមិនគោរពតាមគោលការណ៍ និងបទបញ្ជាផ្ទៃរបស់អង្គភាព
- ចុះពន្យល់ណែនាំ ដល់គ្រឹះស្ថានសហគ្រាសខ្នាត ដែលមិនទាន់យល់ពីការចុះបញ្ជិការនឹង អត្ថប្រយោជន៍ដែលខ្លួនត្រូវបានទទួលពី ប.ស.ស.
- ផ្តល់សេវាសុខាភិបាល និងអត្ថប្រយោជន៍ដល់សមាជិកឱ្យបានទាន់ពេលវេលានិងឆាប់រហ័ស
- រឹតបន្តឹងមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. ដើម្បីផ្តល់សេវាកម្មសុខាភិបាលឱ្យកាន់តែមានប្រសិទ្ធិភាពដល់សមាជិកខ្លួន។
- គួរតែមានការផាកពិន័យឱ្យបានតឹងរឹងចំពោះ និយោជិក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដែលគេចវះ ឬមិនព្រមចុះបញ្ជិកា ឬបង់ភាគទានមកកាន់ ប.ស.ស. ឱ្យទាន់ពេលវេលា។

# ឯកសារយោង

## ឯកសារជាសៀវភៅ និងច្បាប់


- ឯកឧត្តម អ៊ុក សមវិទ្យា របាយការណ៍សមិទ្ធផលរយៈពេល១០ឆ្នាំ (២០០៨ដល់ឆ្នាំ២០១៧) បន្តទិសដៅអនុវត្តទិសដៅការងារឆ្នាំ២០១៨ ប.ស.ស. ភ្នំពេញ ថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៨។
- សៀវភៅក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម (២០១៦ដល់ឆ្នាំ២០២៥) ឯកសារទទួលបានពីទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៧។
- អនុក្រឹត្យលេខ ០១អនក្រ.កបចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- អនុក្រឹត្យលេខ ៣២អនក្រ.កប ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០២១ ស្តីពីការបង្កើតរបបសន្តិសង្គមផ្នែកប្រាក់សោធនសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- ព្រះរាជក្រឹត្យ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈ
- ព្រះរាជក្រម នស/រកម/១១១៩/០១៨ ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៩ ស្តីពីច្បាប់សន្តិសង្គមនៅកម្ពុជា
- ប្រកាសលេខ ២១៦/២០ កប/ប្រ.ក.ប.ស.ស. ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ ២០២០ ស្តីពីការអនុញ្ញាតឱ្យប្រើប្រាស់និមិត្តសញ្ញាសម្គាល់របស់បេឡាជាតិសន្តិសុខសង្គម
- អ៊ុក សមវិទ្យា. របាយការណ៍ស្តីពី លទ្ធផលការងារសម្រេចបាន ឆ្នាំ ២០១៩ និងទិសដៅអនុវត្តបន្តរបស់បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស). ភ្នំពេញ ឆ្នាំ២០២០។
- សៀវភៅ Global Challenges 10 for social security ប្រទេស អាមេរិក ឆ្នាំ២០១៧


## ឯកសារគេហទំព័រ


- ដកស្រង់ចេញពី Website (http://www.nssf.gov.kh/default/) របស់បេឡាជាតិសុខសន្តិសង្គម ឆ្នាំ២០១៩ (ភ្នំពេញ)
- ដកស្រង់ចេញពី Website https://en.wikipedia.org/wiki/National_Social_Security_Fund_ ប្រទេស (Kenya)# ដកស្រង់ចេញថ្ងៃទី២១ ខែមេសា ឆ្នាំ ២០២១
- ដកស្រង់ចេញពី Website https://en.wikipedia.org/wiki/Health_system ដកស្រង់ចេញថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០២១)
- ដកស្រង់ចេញពី Website https://www.investopedia.com/terms/d/disability-insurance.asp ប្រទេសបារាំង ដកស្រង់ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២១

## ឧបសម្ព័ន្ធ ១ ក្រុមបច្ចេកទេសនៃបេឡាសន្តិសុខសង្គម

### ១.១. ក្រុមបច្ចេកទេសនៃក្រុមប្រឹក្សាជាតិគាំពារសង្គម

រាល់ប្រត្តិបត្តិការសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមការសម្របសម្រួល តាមដាន និងតម្រង់ទិស ក្នុងកម្រិតគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រុមប្រឹក្សាជាតិគាំពារសង្គម។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិគាំពារសង្គមត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

### ១.២. ក្រុមបច្ចេកទេសនៃនិយ័តករសន្តិសុខសង្គម

ត្រូវបានបង្កើតនិយ័តករសន្តិសុខសង្គមដែលតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ❖ កំណត់បទប្បញ្ញត្តិប្រុងប្រយ័ត្ន ស្តង់ដារប្រតិបត្តិការ វិធានចាំបាច់នានា និងគោលការណ៍ណែនាំស្តីពីវិនិយោគមូលនិធិសន្តិសុខសង្គម។
- ❖ តាមដានស្ថានភាពហរិញ្ញវត្ថុរបស់ស្ថាប័នប្រតិបត្តិករសន្តិសុខសង្គម។
- ❖ បង្កើតយន្តការការពារសមាជិក និងផ្សះផ្សាវិវាទនៅពេលមានទំនាស់។
- ❖ ត្រួតពិនិត្យអនុលោមភាពដើម្បីធានាថាប្រតិបត្តិការ នៅក្នុងការផ្តល់សេវាសន្តិសុខសង្គមប្រព្រឹត្តទៅដោយតម្លាភាព គណនេយ្យភាព និងចីរភាពហរិញ្ញវត្ថុ។

ការរៀបចំ និង ការប្រព្រឹត្តទៅរបស់និយ័តករសន្តិសុខសង្គមត្រូវកំណត់ដោយអនុក្រឹត្យ។

### ៣.១.៣. ក្រុមបច្ចេកទេសនៃក្រុមប្រឹក្សាភិបាលរបស់បេឡាសន្តិសុខសង្គម

ប.ស.ស. ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពដូចខាងក្រោម៖

| | |
|---|---|
| ❖ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យរបបសន្តិសុខសង្គម | ប្រធាន |
| ❖ តំណាងក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ១រូប | សមាជិក |
| ❖ តំណាងក្រសួងមុខងារសាធារណៈ១រូប | សមាជិក |
| ❖ តំណាងក្រសួងសុខាភិបាល១រូប | សមាជិក |
| ❖ តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា១រូប | សមាជិក |
| ❖ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី១រូប | សមាជិក |
| ❖ តំណាងនិយោជក២រូប | សមាជិក |
| ❖ តំណាងសមាជិក ប.ស.ស. ២រូប | សមាជិក |
| ❖ អគ្គនាយក ប.ស.ស. | សមាជិកអចិន្ត្រៃយ៍។ |

### ១.៤. ក្រុមបច្ចេកទេសនៃអង្គភាពប្រតិបត្តិកររបស់បេឡាសន្តិសុខសង្គម

ប.ស.ស. ត្រូវចាត់ចែង គ្រប់គ្រងការងារប្រចាំថ្ងៃដោយអគ្គនាយក១(មួយ)រូប ដែលត្រូវតែងតាំងដោយដោយព្រះរាជក្រឹត្យ និងអគ្គនាយករងមួយចំនួនជាជំនួយការ អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ការត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ ប.ស.ស. ដែលមានកំណត់ក្នុងច្បាប់នេះ ជាសមត្ថកិច្ចរបស់អធិការសន្តិសុខសង្គម។ការតែងតាំង និងតួនាទីភារកិច្ចរបស់អធិការសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

បុគ្គលិករបស់ ប.ស.ស. ជាមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ ដែលត្រូវបានផ្ទេរ ឬជ្រើសរើសថ្មីតាមសំណើររបស់អគ្គនាយកនៃ ប.ស.ស. និងបុគ្គលិកកិច្ចសន្យាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈបុគ្គលិកនៃ ប.ស.ស. ស្របតាមច្បាប់ស្ដីពីការងារ។

## ឧបសម្ព័ន្ធ ២ ក្រុមបច្ចេកទេសនៃការគ្រប់គ្រងមូលនិធិសន្តិសុខសង្គម

### ២.៥. ក្រុមបច្ចេកទេសនៃការគ្រប់គ្រងមូលនិធិសន្តិសុខសង្គម

ការគ្រប់គ្រងមូលនិធិរបស់នីមួយៗ នៃរបបសន្តិសុខសង្គមត្រូវស្ថិតនៅក្រោមក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ ប.ស.ស.។ ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ ប.ស.ស. ត្រូវបានរៀបចំគោលការណ៍នៃការគ្រប់គ្រងមូលនិធិ ការគ្រប់គ្រងការវិនិយោគ ផែនការវិនិយោគ និងកញ្ចប់វិនិយោគ ដាក់ជូនក្រុមប្រឹក្សានៃ ប.ស.ស. ពិនិត្យ និងអនុម័តដោយអនុលោមតាមគោលការណ៍ណែនាំស្តីពីការវិនិយោគរបស់និយ័តករសន្តិសុខសង្គម ដើម្បីស្នើសុំការសម្រេចចុងក្រោយពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្នុងការបំពេញតួនាទីរបស់ខ្លួន ក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គមនៃ ប.ស.ស. ត្រូវធ្វើរបាយការណ៍ស្តីពីការរក្សា និងការគ្រប់គ្រងមូលនិធិសុខសង្គមគ្រប់ ផ្នែកជូនក្រុមប្រឹក្សាភិបាលនៃ ប.ស.ស. និយ័តករសន្តិសុខសង្គម និងអគ្គនាយកនៃ ប.ស.ស. ជាទៀងទាត់។

សមាសភាព គុណវុឌ្ឍិ ការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធនាភិបាលសន្តិសុខសង្គម ត្រូវកំណត់ដោយអនុក្រឹត្យ។

ឧបសម្ព័ន្ធ ៣

## ២.២. ការពង្រឹង និងពង្រីកសក្តានុពលដើម្បីប្រយោជន៍សាធារណៈជន

### ២.២.១.ការពង្រឹងនិងការពង្រីកសក្តានុពលនៃការអនុវត្តផ្នែកហានិភ័យការងារ (ការងារស្តារនីតិសម្បទា)

សម្រាប់នេះត្រូវរួមបញ្ចូលនៅការស្តារនីតិសម្បទា ដើម្បីផ្តល់នូវឧបករណ៍ ឬអវៈយវៈសិប្បនិម្មិត និងសេវាសម្របសម្រួលមុខងារនិង បណ្តុះបណ្តាលវិជ្ជាជីវៈឡើងឱ្យពេញលេញ សម្រាប់ឆ្នាំ២០១៧ នេះសម្រេចដូចខាងក្រោម៖

- ❖ សហការជាមួយមជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មតាមបណ្តារាជធានីខេត្ត ផ្តល់សេវាស្តារនីតិសម្បទា ដល់សមាជិកដែលទទួលរងគ្រោះថ្នាក់ការងាររហូតដល់ពិការភាពបានជាមួយ
- ❖ សហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលជនពិការបន្ទាយព្រាប ចុះសម្ភាសសមាជិកដែលទទួលរងពិការភាពដល់លំនៅស្ថាន និងផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ❖ តាមដាន ទំនាក់ទំនង សួរសុខទុក្ខ និងពិនិត្យស្ថានភាពរបួសសមាជិក ដើម្បីផ្តល់សេវាស្តារនីតិសម្បទា
- ❖ សហការជាមួយក្រុម Exceed ផ្តល់សេវាកម្មស្តារនីតិសម្បទា ដល់សមាជិក ប.ស.ស.
- ❖ សហការជាមួយមូលនិធិជនពិការ និងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការផ្តល់សេវាស្តារនីតិសម្បទាដល់សមាជិកឱ្យបានកាន់តែមានប្រសិទ្ធភាព។

- ➢ ការអនុវត្តនូវការងារស្តារនីតិសម្បទា

❖ រៀបចំសេចក្ដីព្រាងប្រកាស ស្ដីពីសេវាស្ដារនីតិសម្បទាសម្រាប់របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ

❖ សហការជាមួយអង្គការអន្តរជាតិខាងការងារ(ILO) អង្គការសុខភាពពិភពលោក(WHO)និងទីស្នាក់ការសហប្រតិបត្តិការអន្តរជាតិអាឡឺម៉ង់(GIZ) ដើម្បីរៀបចំយន្តការផ្ដល់សេវាស្ដារនីតិសម្បទា

❖ ចូលរួមវគ្គបណ្ដុះបណ្ដាល និងទស្សនៈកិច្ចសិក្សា ស្ដីពីការផ្ដល់សេវាស្ដារនីតិសម្បទានៅក្រៅប្រទេស

❖ សិក្សាស្រាវជ្រាវ និងរៀបចំបែបបទ នីតិវិធី ដាក់ឱ្យដំណើរការការផ្ដល់សេវាស្ដារនីតិសម្បទា

## ២.២.២.ការពង្រឹងនិងការពង្រីកសក្ដានុពលនៃការអនុវត្តផ្នែកថែទាំសុខភាព

❖ ការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពចេញ ដោយអនុក្រឹត និងប្រកាស និងមានការចូលរួមពីដៃគូអភិវឌ្ឍៈ ILO AFD GIZ និង WHO។

❖ ការចុះសម្របសម្រួលឱ្យអធិការចុះបើកផ្លូវមុខពេលមានក្រុមអត្តសញ្ញាណចុះកំណត់ (ចុះសម្របសម្រួល, សហការចុះ ពន្យល់ណែនាំពីនីតិវិធីចុះបញ្ជិការ សហការចុះចែកលិខិតឱ្យសហគ្រាសគ្រឹះស្ថានជាប់ភាគទាន សហការចុះទៅពន្យល់នាំ ពីគាវលិកថែទាំសុខភាព និងការបង់ភាគទានមកកាន់ ប.ស.ស.។

❖ ដោយគិតត្រឹមខែ កុម្ភៈ ឆ្នាំ២០១៨ នេះបានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលសរុបចំនួន ១.៣០០ មូលសុខាភិបាលទូទាំងរាជធានីខេត្ត។

## ២.២.៣. ការជំរុញ និងរៀបចំ ព្រមទាំងពង្រីកសក្ដានុពលនៃផ្នែកសោធន

ការជំរុញដាក់ដំណើការ ព្រមទាំងពង្រីកវិសាលភាពឱ្យបានទូលំទូលាយ ដើម្បីក្ដោងក្ដាប់យកទាំងវិស័យឯកជន នឹងវិស័យមន្ត្រីរាជការស៊ីវិលព្រមទាំងមន្ត្រីរាជការចូលនិវត្តន៍ទាំងអស់នូវក្នុងប្រទេសកម្ពុជាមានដូចជា៖

- ❖ បាន និងកំពុងចុះកំណត់អត្តសញ្ញាណកម្មករនិយោជិតឡើងវិញសម្រាប់ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព ដែលជាមូលដ្ឋានសម្រាប់ផ្នែកប្រាក់សោធនផងដែរ។
- ❖ រៀបចំប្រព័ន្ធព័ត៌មានវិទ្យា
- ❖ សហការជាមួយដៃគូពាក់ព័ន្ធ និងអង្គការអន្តរជាតិខាងការងារដើម្បីបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាជាច្រើនលើក
- ❖ កំពុងសិក្សាសមិទ្ធិលទ្ធភាពដាក់ឱ្យដំណើរការ ដោយការរំពឹងទុក និងគ្មានផលប៉ះពាល់ ដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិ(ILO,AFD)
- ❖ រៀបចំសេចក្ដីព្រាងលិខិតគតិយុត្ត
- ❖ រៀបចំសេចក្ដីព្រាងច្បាប់ដើម្បីស្នើសុំវិសោធកម្មច្បាប់ស្ដីពី របបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្ដីពីការងារ

- ❖ នឹងរៀបចំប្រជុំពិគ្រោះយោបល់ជាមួយជំនាញការ Hatichi, JICA, ILO រដ្ឋាករស្វ័យតរាជធានីភ្នំពេញ អគ្គិសនីជាតិកម្ពុជា ធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា
- ❖ នឹងឱ្យដំណើរការនៅឆ្នាំ ២០១៩ ប៉ុន្តែដោយស្ថានភាពកូវីតបាននឹងបន្តអូសបន្លាយរហូតដល់ ២០២១ នៅតែបន្តទាន់បានដំណើរការនូវឡើយ

### ២.២.៤. ការអនុវត្តរបបសន្តិសុខសម្រាប់មន្ត្រីសាធារណៈអតីតមន្ត្រីរាជការ និងអតីតយុទ្ធជន

❖ លិខិតគតិយុត្តៈ

- ព្រះរាជក្រឹត្យលេខ នស/រកត/0២១៧/0៧៨ ចុះថ្ងៃទី0១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីរាជការសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការ សាធារណៈ អតីតយុទ្ធជន
- អនុក្រឹត្យ លេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០១៧ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិនៃការផ្តល់តាវលិកផ្នែកហានិភ័យការងារសម្រាប់មន្ត្រីរាជការសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន
- រៀបចំសេចក្តីព្រាងលិខិតគតិយុត្តផ្សេងៗ

❖ ផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីរាជការសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៨។ គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៨ មានអ្នកទៅទទួលសេវា ៨២០ករណី ក្នុងនោះស្ត្រីសម្រាលកូន មានចំនួន ៨៧នាក់។

❖ ដោយឡែកផ្នែកហានិភ័យការងារមន្ត្រីសាធារណៈ បច្ចុប្បន្នក្រុមការងាររៀបចំ បាននិងកំពុងសិក្សាបទដ្ឋានគតិយុត្តដែលឈានដល់ការរៀបចំសមិទ្ធិលទ្ធភាពដាក់ឱ្យអនុវត្តនៅឆ្នាំ២០១៩ខាងមុខ។

### ២.២.៥. ការបើកប្រាក់ឧបត្ថម្ភបន្ថែមពេលសម្រាលកូន

ការបើកប្រាក់ឧបត្ថម្ភបន្ថែមសម្រាប់កម្មករនិយោជិកជាស្ត្រីនៅពេលសម្រាលកូន ទាំងក្នុង និងក្រៅប្រព័ន្ធត្រូវដាក់ឱ្យអនុវត្តនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ ដែលក្នុងនោះមានដូចជាៈ

- ❖ ក្នុងប្រព័ន្ធ(ចំនួនម្តាយ៨.២៨៤, ចំនួនទារក៨.៣៣៨, ចំនួនថវិកាផ្តល់ជូន(ប៊ីលាន)៣.៣៤)
- ❖ ក្រៅប្រព័ន្ធ(ចំនួនម្តាយ២៧, ចំនួនទារក២៨, ចំនួនថវិកាផ្តល់ជូន(ប៊ីលាន)0.0១)
- ❖ សរុប(ចំនួនម្តាយ៨.៣១១, ចំនួនទារក៨.៣៦៦, ចំនួនថវិកាផ្តល់ជូន(ប៊ីលាន)៣.៣៥)

ក្នុងនោះស្ត្រីសម្រាលបានកូនភ្លោះចំនួន ៥៥នាក់។

# ឧបសម្ព័ន្ធ៣ យន្តការផ្សព្វផ្សាយ និង បង្ការ

## ៣.១.១ ការងារផ្សព្វផ្សាយ និងបង្ការ

### ១. សហការជាមួយក្រុមការងារពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍវិស័យការងារ

ក្រុមការងារនេះមានភារកិច្ចផ្សព្វផ្សាយដល់កម្មករនិយោជិតតាមរោងចក្រ សហគ្រាស គ្រឹះស្ថាននីង លំនៅស្ថាន ដោយផ្អែកលើ៖

- ❖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រដ្ឋាភិបាល
- ❖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៏វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ❖ ច្បាប់ និងលិខិតបទដ្ឋានគតិតយុត្តពាក់ព័ន្ធវិស័យការងារ
- ❖ វិធានការទប់ស្កាត់វិវាទការងារ កូដកម្ម បាតុកម្ម និងគ្រោះថ្នាក់ការងារ
- ❖ វិធានការទប់ស្កាត់គ្រោះថ្នាក់ចរាចរណ៍លើមធ្យោបាយដឹកជញ្ជូន និងសុវត្ថិភាពធ្វើដំណើររបស់កម្មករ
- ❖ វិធានការទប់ស្កាត់ករណីសន្លប់របស់កម្មករនិយោជិកតាមសហគ្រាស
- ❖ អត្ថប្រយោជន៍របបសន្តិសុខសង្គម
- ❖ កម្មវិធីនិយោបាយ និងគោលនយោបាយនានារបស់រដ្ឋាភិបាល

### ២. ក្រុមការងារទប់ស្កាត់ករណីកម្មករសន្លប់ និងបង្ការគ្រោះថ្នាក់ការងារ(ទ.ស.ប.ក.)

មូលហេតុដែលបណ្តាលឱ្យសន្លប់មកពី៖

- សាយភាយថ្នាំគីមីដែលប្រជាជនបាញ់ដាក់ស្រែ
- ផ្តិតទឹកដែលប្រើប្រាស់មានធូលីដី
- បរិយាកាសការណ៍កម្តៅក្នុងអគារផលិតកម្មក្តៅ និងហប់
- តានតឹងអារម្មណ៍ និងស្លន់ស្លក័យតៗគ្នា

ក្រុមការងារបានចុះផ្សាយព្វផ្សាយផ្ទាល់នៅហ្នឹងកន្លែងជូនកម្មករនិយោជិកតាមបណ្តារោងចក្រ សហគ្រាស នៃវិស័យកាត់ដេរ និងផលិតស្បែកជើង ដូចភ្លៀងរលឹមលើប្រធានបទដូចខាងក្រោម៖

- ❖ លក្ខខណ្ឌការងារ
- ❖ លក្ខខណ្ឌអនាម័យ និងសុវត្ថិភាព ការងារ(វិធានការការពារ និងទប់ស្កាត់ករណីសន្លប់)
- ❖ អត្ថប្រយោជន៍របបសន្តិសុខសង្គម។

### ៣. ក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិក

ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយ ក៏ដូចជាទប់ស្កាត់ករណីគ្រោះថ្នាក់ចរាចរណ៍នេះ ប.ស.ស. តាមរយៈការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិតហៅកាត់ថា (ស.ផ.ក) ដែលមានសមាសមកពីក្រសួងពាក់ព័ន្ធ តំណាងភាគីនិយោជក កម្មករនិយោជិក និងអង្គការជនពិការអន្តរជាតិ(HI)។

- ❖ ផ្សព្វផ្សាយអំពីច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក

- ❖ ផ្សព្វផ្សាយឱ្យយល់ដឹងអំពីការត្រួតពិនិត្យបច្ចេកទេសក្នុងការបើកបរ និងការត្រួតពិនិត្យថៃទាំយានយន្ត
- ❖ ការបណ្តុះបណ្តាលត្រៀមប្រលងយកបណ្ណបើកបរ
- ❖ ផ្សព្វផ្សាយអំពីផ្លាកសញ្ញា សិទ្ធិអាទិភាព ការកំណត់ល្បឿន និងការផាកពិន័យ។

### ៣.១.២. ការងារគាំទ្រការអនុវត្ត

**❖ ការងាររដ្ឋបាល**

គ្រប់គ្រងឯកសារចេញ ចូល

ផ្គត់ផ្គង់ លំហែទាំបរិក្ខា និងយានយន្ត...

តាមដានការអនុវត្តបទបញ្ជាផ្ទៃក្នុងស្របក្នុងច្បាប់ស្តីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

**❖ ការងារហិរញ្ញវត្ថុ**

រៀបចំផែនការ និងរបាយការណ៍ចំណូល ចំណាយប្រចាំឆ្នាំ

គ្រប់គ្រងចំណូល ចំណាយ ដោយសហប្រតិបត្តិការតាមរយៈប្រព័ន្ធធនាគារជាអាទិ៍៖

- ការប្រមូលភាគទាន និងប្រាក់ពិន័យ
- ការចំណាយតាវកាលិក និងចំណាយរដ្ឋបាល

**❖ ការងារក្នុងប្រទេស**

រៀបចំវគ្គបណ្តុះបណ្តាលការងារផ្ទៃក្នុងដល់មន្ត្រី បុគ្គលិក និងចាត់មន្ត្រី ព្រមទាំងបុគ្គលិកឱ្យទៅចូលរួមឱ្យចូលរួមវគ្គបណ្តាល ទស្សនកិច្ចសិក្សា និងសិក្ខាសាលា។

**❖ ការងារក្រៅប្រទេស**

បានចាត់ ឬត្រូវបានដៃគូអភិវឌ្ឍអញ្ជើញមន្ត្រី ឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាល ទស្សនកិច្ច និងសិក្ខាសាលាក្រៅប្រទេស។

➢ ការគ្រងបណ្តុះបណ្តាលផ្នែកផ្សេងនៃស្ថាប័ន

**❖ ផ្នែកព័ត៌មានវិទ្យា**

- Programming

កម្មវិធីបោះពុម្ពកាតសមាជិក ប.ស.ស. កម្មវិធីកំណត់អត្តសញ្ញាសមាជិក ប.ស.ស.

កម្មវិធីតាវលិក កម្មវិធីស្នើសុំសេវាស្តារលទ្ធភាពពលកម្ម

កម្មវិធីរដ្ឋបាល កម្មវិធីប្រឡងអង្កេតសមត្ថភាព កម្មវិធីអធិការកិច្ច កម្មវិធីអង្កេតគ្រោះថ្នាក់ការងារបឋម កម្មវិធី HSPIS កម្មវិធី NSSF Program v7.01

កម្មវិធី(E-form Web Application) សម្រាប់មន្ត្រីសាធារណៈ

កម្មវិធីបញ្ជិការ និងភាគទាន សម្រាប់មន្ត្រីសាធារណៈ និងកម្មករនិយោជិតក្រៅប្រព័ន្ធ

- Networking
- Maintenance

❖ **ការងារសវនកម្មផ្ទៃក្នុង**

ក្នុងន័យលើកកម្ពស់ប្រសិទ្ធិភាពរបស់គ្រឹះស្ថាន សវនផ្ទៃក្នុងបានទទួលអនុវត្តចង្កោមសកម្មភាព ទី០៥ ការអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង"មានសកម្មភាពចំនួន ០៣គឺ"៖

សកម្មភាពទី១ ពង្រឹងនឹង ពង្រីកអភិបាលកិច្ចសវនដ្ឋានផ្ទៃក្នុង

សកម្មភាពទី២ គ្រប់គ្រងធនធានមនុស្សរបស់សវនកម្មផ្ទៃក្នុង

សកម្មភាពទី៣ ពង្រឹងការអនុវត្តមុខងារសវនកម្មផ្ទៃក្នុង

❖ ការងារដោះស្រាយវិវាទ ឬបណ្តឹងផ្សេងៗនៃប.ស.ស.(ដ.វ.ប)

គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹងនៃ ប.ស.ស. ត្រូវបានបង្កើតឡើងដោះស្រាយវិវាទ ឬប បណ្តឹងដែលទាក់ទងទៅនឹងការអនុវត្តបទប្បញ្ញត្តិ និងបទបញ្ហាខាងវិស័យសន្តិសុខសង្គមរវាង សមាជិកប.ស.ស. និយោជក និងប.ស.ស. ដែលគណៈកម្មការនេះមានការចូលរួមត្រីភាគីរួមមាន តំណាងនិយោជក និងកម្មករនិយោជិត។

## ៣.២. បញ្ហាប្រឈម និងដំណោះស្រាយនៃបេឡាសន្តិសុខសង្គម

### ៣.២.១. បញ្ហាប្រឈមនៃបេឡាសន្តិសុខសង្គម

ជាក់ស្តែងគ្រប់ដំណើរការនៃរបបសន្តិសុខសង្គមដែលគ្រប់ដណ្តប់ដោយបេឡាជាតិសន្តិសុខ សង្គមបានបង្កឱ្យមានបញ្ហាប្រឈមជាច្រើនដល់ស្ថាប័នមួយនេះដូចតទៅ៖

#### ៣.២.១.១. បញ្ហាប្រឈមជាមួយសហគ្រាសគ្រឹះស្ថាន

❖ សហគ្រាសគ្រឹះស្ថានមួយចំនួនមិនទាន់បានចុះបញ្ជិកាបង់ភាគទាន និងផ្នែកទិន្នន័យកម្មករ មិនទាន់មានច្បាស់តាមខែនីមួយៗ

❖ សហគ្រាសគ្រឹះស្ថាននៅមានការបង់ភាគទានយឺតយ៉ាវ

❖ ពិបាកជួបផ្ទាល់ជាមួយម្ចាស់សហគ្រាស (ភោជនីយដ្ឋាន ក្លឹបកំសាន្ត ខារ៉ាអូខេ....)

❖ បិទទ្វារ ផ្អាកសកម្មភាព ប្តូរអាសយដ្ឋាន ប្តូររដ្ឋបាលថ្មី ប្តូរម្ចាស់ ប្តូរយីហោថ្មី ដោយមិនបាន ជូនដំណឹងមក ប.ស.ស.

❖ ប្រភេទសិប្បកម្មមិនរៀបរយគ្មានឯកសារគតិយុត្តមិនត្រឹមត្រូវ

❖ និយោកជកសហគ្រាស គ្រឹះស្ថានមួយចំនួនតូចធ្វើការពន្យាពេលក្នុងចុះកំណត់អត្តសញ្ញាណ កម្មករនិយោជិក ខ្លាចប៉ះពាល់ដល់សង្វាក់ផលិតកម្មដោយបញ្ជូនកម្មករនិយោជិកមកតិច ព្រមទាំងខ្លាច ILO រករឿងរាយការណ៍ទៅអ្នកបញ្ជាទិញ

❖ មិនបានរាយការណ៍ពីចំនួនបុគ្គលិកចូលថ្មី និងលាឈប់ពីការងារ និងមួយចំនួនទៀតបានរាយ ការណ៍ដែរ តែមិនមានភាពច្បាស់លាស់

#### ៣.២.១.២. បញ្ហាប្រឈមជាមួយសមាជិកនៃបេឡាសន្តិសុខសង្គម

❖ កម្មករនិយោជិកមួយចំនួនតូច មិនទាន់យល់ច្បាប់ពីអត្តសញ្ញាណច្បាប់លាស់ និងទាមទារ តាវកាលិកមិនមែនគ្រោះថ្នាក់ការងារ

❖ មិនចុះសំបុត្រអាពាហ៍ពិពាហ៍

- ទៅទទួលការព្យាបាលនៅមន្ទីរពេទ្យដែលមិនបានចុះកិច្ចព្រមព្រៀងជាមួយប.ស.ស.
- កម្មករនិយោជិកមួយចំនួនតូចបានខ្ចីឯកសារគេប្រើប្រាស់ មិនហានប្រាប់ខ្លាចគេបញ្ឈប់ពីការងារ មិនទាន់យល់ច្បាស់ពីអត្ថប្រយោជន៍ផ្នែកថែទាំសុខភាព ខ្លាចបាត់បង់អតីតភាពការងារពេលប្តូរឈ្មោះត្រឹមត្រូវវិញ
- ព្យាយាមលាក់បាំងមិនព្រមបង្ហាញកាតដោយយល់ថា គ្រូពេទ្យផ្តល់សេវាល្អទាល់តែបង់ប្រាក់ប្រាក់ភ្លាមៗ
- កម្មករនិយោជិកជាស្ត្រីមិនមានអត្តសញ្ញាណប័ណ្ណ ឬអត្តសញ្ញាណប័ណ្ណមិនច្បាស់លាស់
- ការប្រើប្រាស់កម្រិតទូរស័ព្ទទំនើបមិនមានភាពច្បាស់ច្បាស់លាស់
- កម្មករនិយោជិតមិនទាន់យល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធធនាគារ
- ទូរស័ព្ទមិនមែនជាប្រភេទស្មាតហ្វូនទើបការផ្សព្វផ្សាយមិនទូលំទូលាយ
- និយោជក និងកម្មករនិយោជិតមួយចំនួនមិនយល់ថា ឬស្គាល់ថា ប.ស.ស.

### ៣.២.១.៣. បញ្ហាប្រឈមជាមួយមូលដ្ឋានសុខាភិបាលដែលជាដៃគូរ

- គុណភាពនៃការផ្តល់សេវាព្យាបាលផ្នែកថែទាំវេជ្ជសាស្ត្ររបស់មូលដ្ឋានមួយចំនួនតូចនៅមានកម្រិត
- មូលដ្ឋានសុខាភិបាលមួយចំនួនតូចមានគ្រូពេទ្យមួយចំនួនដែលមិនទាន់យល់ច្បាប់អំពីលំហូរនៃការផ្តល់សេវាជូនសមាជិកដោយរលូន(បញ្ជូនអ្នកជំងឺមួយទៅមួយ) និងផ្តល់ឱសថសារវ័ន្តដល់សមាជិកមិនគ្រប់គ្រាន់
- ប្រព័ន្ធគ្រប់គ្រងទិន្នន័យសុពលភាពសមាជិកមិនទាន់រលូនដែលនាំឱ្យការផ្តល់សេវាមានភាពយឺតយ៉ាវ
- កម្មករនិយោជិកនៅតែមានបញ្ហាសន្លប់នៅតែបន្តកើនឡើង
- កម្មករនិយោជិតនៅតែមានគ្រោះចរារណ៍បង្កឡើង ដោយអ្នកបើកបរដឹកកម្មករមានការកើនឡើង

### ៣.៣.១.៤. បញ្ហាប្រឈមជាមួយការអនុវត្តជាក់នៃស្ថាប័នមានសមត្ថកិច្ច

បញ្ហាដែលស្ថាប័នមានសមត្ថភាពធ្វើឱ្យមានបញ្ហាប្រឈមដូចជា:

- ការចុះបញ្ជីមន្ត្រីរាជការសាធារណៈមិនទាន់ឆ្លើយតបទៅនឹងមន្ត្រីរាជការសរុប
- មន្ត្រីរាជការសាធារណៈមិនទាន់បានយល់បានច្បាស់ពីអត្ថប្រយោជន៍ដែលខ្លួនទទួលបាន
- ការផ្សព្វផ្សាយជូនមន្ត្រីរាជការមិនទាន់ទូលំទូលាយ
- បញ្ហាធនធានមនុស្សនៅមានកម្រិត
- ការអនុវត្តរបបសន្តិសុខសង្គមមិនទាន់ទូលំទូលាយ
- ពិបាករកជំនាញវេជ្ជបណ្ឌិត

### ៣.៣.១. ដំណោះស្រាយនៃបេឡាសន្តិសុខសង្គម

#### ៣.៣.១.១. ដំណោះស្រាយជាមួយសហគ្រាសគ្រឹះស្ថាន

- ស្នើសុំសូមនិយោជកសហគ្រាស គ្រឹះស្ថាន ដើម្បីចុះធ្វើការផ្សព្វផ្សាយ នឹងពន្យល់ណែនាំយន្តការអនុវត្តជាធរមាន
- ជម្រុញ ពន្លឿនការប្រមូល បង់ភាគទាន
- បន្តព្យាយាមសម្របសម្រួលណាត់ជួបនៅពេលរសៀល និងពន្យល់ឱ្យអស់លទ្ធភាពមុននឹងចាត់វិធានការ
- ចុះពិនិត្យទីតាំងសហគ្រាសផ្ទាល់ ដើម្បីកំណត់ស្ថានភាពសហគ្រាសដំណើរ ឬមិនដំណើរការ
- ព្យាយាមទំនាក់ទំនងផ្ទាល់ដើម្បីជួយបង្រៀនឱ្យចេះរៀបចំឯកសារបង់ភាគទាន និងឯកសារទាមទារតាវកាលិក
- បន្តពន្យល់ពីនីតិវិធីនៃការកំណត់អត្តសញ្ញាណសមាជិក និងការផ្តល់សេវាជូនសហគ្រាសគ្រឹះស្ថានដល់និយោជិកឱ្យយល់ដឹងកាន់តែប្រសើរ
- ណែនាំប្រាប់ពីរបៀបនៃការរៀបចំរបាយការណ៍ពិសេសមានកម្មករនិយោជិតគ្រប់ចំនួនមិនមានការលាក់បាំងធ្វើឱ្យមានសុក្រឹត្យភាព

#### ៣.៣.១.២. ដំណោះស្រាយជាមួយសមាជិកនៃបេឡាសន្តិសុខសង្គម

- ការចុះសម្របសម្រួល និងពន្យល់ផ្ទាល់ពីគោលការណ៍អនុវត្តជាធរមានដល់កម្មករនិយោជិត
- បន្តជំរុញ និងដាស់តឿនឱ្យអញ្ជើញឱ្យទៅចុះសំបុត្រអាពាហ៍ពិពាហ៍
- បន្តណែនាំឱ្យទៅទទួលយកសេវាកម្មមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. វិញ
- បន្តចុះពន្យល់ពីនីតិវិធីនៃការកំណត់អត្តសញ្ញាណសមាជិកថ្មី (ផ្សព្វផ្សាយសេចក្តីជូនដំណឹងលេខ១២៧ ក.ប/ស.ជ.ណ ស្តីពីការចុះបញ្ជិកាកម្មករនិយោជិតក្នុងប.ស.ស.)
- បន្តចុះណែនាំ និងផ្សព្វផ្សាយពីតាវកាលិកថែទាំសុខភាព និងសម្របសម្រួលសមាជិកឱ្យប្រើប្រាស់សេវាតាមរយៈភ្នាក់ងារ ប.ស.ស. នៅមូលដ្ឋានសុខាភិបាលជាដៃគូ
- ព្យាយាមពន្យល់ដល់កម្មករនិយោជិតដោយផ្ទាល់នៅពេលកម្មករនិយោជិតមកបំពេញទម្រង់ឯកសារស្នើសុំប្រាក់ឧបត្ថម្ភនៅទីស្នាក់ការកណ្តាល និងសាខារាជធានីខេត្តរបស់ ប.ស.ស.
- បន្តពន្យល់ណែនាំការប្រើប្រាស់លេខទូរស័ព្ទយល់ពីលេខទូរស័ពបន្ទាប់ ១២៨៦
- បន្តពន្យល់ និងជម្រុញឱ្យមានអត្តសញ្ញាណប័ណ្ណច្បាស់លាស់
- បង្កើនការផ្សព្វផ្សាយពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ វិធានការទប់ស្កាត់ករណីសន្លប់

#### ៣.៣.១.៣. ដំណោះស្រាយជាមួយមូលដ្ឋានសុខាភិបាលដែលជាដៃគូរ

- ចុះប្រជុំសម្របសម្រួលជាមូលដ្ឋានសុខាភិបាលដែលបានចុះ កិច្ចព្រមព្រៀងដោយផ្តល់សេវាបឱ្យកាន់តែប្រសើរ ដើម្បីរកចំណុចក្តៅក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលបានជួប
- បន្តប្រជុំពិភាក្សា ដើម្បីស្វែងរកដំណោះស្រាយក្នុងការផ្តល់ឱសថស និងសេវាឱ្យរលូន

- ធ្វើរួមបញ្ចូលសហការជាមួយការិយាល័យពាក់ព័ន្ធ និងអនុញ្ញាតឱ្យក្រុមហ៊ុន Nokor IT រៀបចំ និងសាកល្បងប្រព័ន្ធព័ត៌មានវិទ្យា

### ៣.៣.១.៤. ដំណោះស្រាយជាមួយការអនុវត្តជាក់នៃស្ថាប័នមានសមត្ថកិច្ច

- ជំរុញការចុះបញ្ជីមន្ត្រីរាជការសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័ន អង្គភាពសាមី
- ត្រូវបង្កើនការផ្សព្វផ្សាយគ្រប់វិធីសាស្ត្រតាមរយៈ ការប្រជុំផ្សព្វផ្សាយដោយផ្ទាល់ ផ្សព្វផ្សាយតាមរយៈទូរទស្សន៍ វិទ្យុកាសែត Facebook website និងតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា
- សហការជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធជម្រុញឱ្យអ្នកបើកបររថយន្តដឹកកម្មករត្រូវមានការផ្លាស់ប្តូរ មកប្រើប្រាស់រថយន្តដឹកជញ្ជូនអ្នកដំណើរដែលមានកៅអីត្រឹមត្រូវ ព្រមទាំងចុះបង្រៀនអំពីច្បាប់ស្តីពីចរាចរណ៍ដល់អ្នកបើកបររថយន្តដឹកកម្មករ
- បង្កើនការផ្សព្វផ្សាយពីគោលនយោបាយរបបសន្តិសុខសង្គមដល់និយោជក និងកម្មករនិយោជិតឱ្យបានកាន់ទូលំទូលាយ

### ៣.៣.១.៥. ការបណ្តុះបណ្តាល និងរៀបចំបទដ្ឋានគតិយុត្ត

- បណ្តុះបណ្តាលរៀបចំធ្វើវិសោធនកម្មច្បាប់របបសន្តិសុខសម្រាប់ជន ទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ(ព្រោះការចែងការចូលនិវត្តន៍ ពីអាយុនៅ ៥៥ឆ្នាំ គឺជាបញ្ហាអាចនឹងជិះឥទ្ធិពលដល់ការអនុវត្ត)
- រៀបចំសេចក្តីព្រាងប្រកាស
- សិក្សាកែសម្រួលលក្ខខណ្ឌ និងសិទ្ធិទទួលបានសេវា
- រៀបចំលំហូរការងារសម្រាប់អនុវត្តដោយការទទួលខុសត្រូវ
- សិក្សាយន្តការសម្រាប់ធ្វើស្វ័យប្រកាសសម្រាប់កម្មករនិយោជិត
- រៀបចំប្រព័ន្ធស្វ័យត្រួតពិនិត្យបង់ភាគទាន
- រៀបចំដាក់ឱ្យដំណើរការផ្នែកសោធននៅឆ្នាំ ២០១៩
- បន្តរៀបចំវគ្គបណ្តុះបណ្តាល ស្នើសុំដៃគូអភិវឌ្ឍនូវវគ្គបណ្តុះបណ្តាលទាំងខាងក្នុងនិងក្រៅ ព្រមទាំងរៀបយុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់រយៈពេលវែងទៅធនធានមនុស្សក្នុងស្ថាប័នឱ្យល្អបំផុត
- បន្តរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បន្តរៀបចំឡើងវិញនូវលក្ខន្តិកៈដោយឡែកសម្រាប់ ការលើកទឹកចិត្តបន្ថែមលើជំនាញវេជ្ជបណ្ឌិត

# ឧបសម្ព័ន្ធ ៤ កម្រងសំណួរ

១.   តើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីការងារមានសារៈសំខាន់ដូចម្តេចខ្លះសម្រាប់កម្មករនិយោជិត?

២.  តើតាវកាលិកសំខាន់ៗមានប៉ុន្មាន យោងតាមអនុសញ្ញាអន្តរជាតិលេខ ១០២ ស្តីពីរបបសន្តិសុខសង្គមរបស់អង្គការអន្តរជាតិខាងការងារ (ILO) ចូររៀបរាប់ពីតាវកាលិកនីមួយៗ។

៣.   យោងតាមច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ តើតាវកាលិកហានិភ័យការងារមានអ្វីខ្លះ?

៤. ដូចម្តេចដែលហៅថា ហានិភ័យការងារ(គ្រោះថ្នាក់ការងារ)?

របបសន្តិសុខសង្គមផ្នែកប្រាក់សោធនសម្រាប់កម្មករនិយោជិតដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារមានតាវកាលិកអ្វីខ្លះ? ចូររៀបរាប់តាវកាលិកនីមួយៗ។

៥.   ចូររៀបរាប់ពីវិសាលភាព   និងដែនអនុវត្តនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ?

៦. របបសន្តិសុខសង្គមផ្នែកថែទាំសុខភាពមានតាវកាលិកអ្វីខ្លះ? ចូររៀបរាប់ពីតាវកាលិកនីមួយៗ។

៧.  តើបេឡាជាតិរបបសន្តិសុខសង្គមស្ថិតនៅក្រោមអាណាព្យាបាលក្រសួងណាខ្លះ? ហើយសមាសភាពក្រុមប្រឹក្សាភិបាលមានតំណាងមកពីក្រសួង ស្ថាប័ន ឬអង្គភាពណាខ្លះ?

៨.តើបេឡាជាតិរបបសន្តិសុខសង្គមស្ថិតនៅក្រោមអាណាព្យាបាលក្រសួងណាខ្លះ?   ហើយសមាសភាពក្រុមប្រឹក្សាភិបាលមានតំណាងមកពីក្រសួង ស្ថាប័ន ឬអង្គភាពណាខ្លះ?

៩.  តើអត្ថប្រយោជន៍ នៃរបបសន្តិសុខសង្គមមានអ្វីខ្លះ?

១០.      តើអ្នកយល់យ៉ាងណាចំពោះគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបង្កើតរបបសន្តិសុខសង្គម?

១១. ដូចម្តេចដែលហៅថាហានិភ័យសង្គម? ចូររៀបរាប់? មានគោលការណ៍គ្រឹះប៉ុន្មានចំណុច?

១២.  ចូររៀបរាប់ពីទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០១៦ របស់បេឡាជាតិរបបសន្តិសុខសង្គម?

១៣. ចូររៀបរាប់ពីប្រភពធនធានរបស់បេឡាជាតិរបបសន្តិសុខសង្គម?

១៤. ឧត្តរជីវីគឺជាជនប្រភេទណាខ្លះ? ចូរឲ្យឧទាហរណ៍?

១៥.  ដើម្បីទទួលបានតាវកាលិកឧត្តរជីវី តើត្រូវមានលក្ខខណ្ឌអ្វីខ្លះ?

១៦. ដូចម្តេចដែលហៅថាជម្ងឺវិជ្ជាជីវៈ?

១៧. ចូលរៀបរាប់ភារកិច្ចសំខាន់របស់បេឡាជាតិរបបសន្តិសុខសង្គម?

១៨. តើអ្នកគិតយ៉ាងថាសន្តិសុខសង្គមជួយអ្វីខ្លះដល់អ្នក?

១៩.តើបេឡាជាតិសន្តិសុខសង្គម មានបុព្វសិទ្ធិនៃអំណាចសាធារណៈអ្វីខ្លះ?

២០. តើសេវាស្តានីតិសម្បទាមានអ្វីខ្លះ?